Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized
Public Disclosure Authorized

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែមិថុនា ឆ្នាំ២០២៥

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# ពុះពារ ភាពមិនប្រាកដប្រជា

**អត្ថបទផ្តោតពិសេស**

## ពង្រឹងចំណូលសម្រាប់អនាគតរបស់កម្ពុជា



## បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែមិថុនា ឆ្នាំ២០២៥

# ពុះពារ
# ភាពមិនប្រាកដប្រជា

## អត្ថបទផ្តោតពិសេស

ពង្រឹងចំណូលសម្រាប់អនាគតរបស់កម្ពុជា

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific

# តារាងមាតិកា

**កិច្ចថ្លែងអំណរគុណ** . . . . . . . . . . . . . . . . . . . . . . . . . . . . . v

**អក្សរកាត់** . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . vi

**សេចក្តីសង្ខេប** . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 1

**ជំពូកទី ១ ការវិវត្តសេដ្ឋកិច្ចនាពេលថ្មីៗ និងចក្ខុវិស័យ** . . . . . . . . . . . . . 5

ការវិវត្តថ្មីៗ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 6

បរិយាកាសកលលោកកាន់តែស្មុគ្រស្មាញ . . . . . . . . . . . . . . . . . . . . . 6

សកម្មភាពសេដ្ឋកិច្ចនៅតែមានភាពស្វាហាប់ ប៉ុន្តែមិនស្មើគ្នា . . . . . . . . . . . . 6

ការនាំចេញបង្អន់ល្បឿន ចំពេលមានការផ្លាស់ប្តូរគោលការណ៍ពាណិជ្ជកម្មសកលបង្កឧបសគ្គបន្ថែម . . . . 7

ការចំណាយរបស់ភ្ញៀវទេសចរបរទេសកើនឡើង ប៉ុន្តែនៅតែទាបជាងកម្រិតឆ្នាំ២០១៩ . . . . . 8

ការងារក្នុងផ្នែកកម្មន្តសាលកើនខ្លាំងមែន ប៉ុន្តែការបង្កើតការងារទូទៅនៅមានកម្រិត . . . . . 9

គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័តកើនឡើង ប៉ុន្តែការវិនិយោគក្នុងស្រុកធ្លាក់ចុះខ្លាំង . . . . 12

ការនាំចេញកសិផលមានទិដ្ឋភាពចម្រុះ ទោះបីជាផលិតកម្មស្រូវកើនឡើងក៏ដោយ . . . . . 13

ទំនុកចិត្តអ្នកប្រើប្រាស់មានភាពប្រសើរ លើកកម្ពស់ការប្រើប្រាស់ . . . . . . . . . . 13

អតិផរណាបានងើបឡើងបន្តិច ដោយសារការឡើងថ្លៃនៃស្បៀងអាហារ . . . . . . . . . 13

នៅពេលដែលការនាំចូលបានស្ទុះងើបឡើង ឱនភាពនៃគណនីចរន្តរីកកាន់តែធំ . . . . . . 14

ប្រាក់រៀលបានឡើងថ្លៃបន្តិច រីឯអត្រាការប្រាក់បានធ្លាក់ចុះ . . . . . . . . . . . . 14

ការផ្តត់ផ្គង់សាច់ប្រាក់កើនឡើង រីឯកំណើនឥណទានស្រុតចុះបន្តិច . . . . . . . . . . 15

ការបង្រួមសារពើពន្ធបានចាប់ផ្តើម . . . . . . . . . . . . . . . . . . . . . . . 15

ស្តុកបំណុលសាធារណៈកើនដល់ ២៥,៩ ភាគរយនៃ ផ.ស.ស. ត្រឹមចុងឆ្នាំ២០២៤ . . . . . 18

**ផ្នែកទី២ ការពង្រឹងចំណូលសម្រាប់អនាគតរបស់កម្ពុជា** . . . . . . . . . . . . . . 21

១. សេចក្តីផ្តើម . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 22

២. បរិការណ៍ចំណូល . . . . . . . . . . . . . . . . . . . . . . . . . . . . . . 23

៣. ផលជះនៃការចំណាយផ្នែកអនុលោមភាពពន្ធដារ ទៅលើបរិយាកាសធុរកិច្ច . . . . . . . 30

៤. សមធម៌ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 33

៥. អនុសាសន៍គោលនយោបាយ . . . . . . . . . . . . . . . . . . . . . . . . . . 34

**ឧបសម្ព័ន្ធ៖ កម្ពុជា - សូចនាករសំខាន់ៗ** . . . . . . . . . . . . . . . . . . . . 39

**គន្ថនិទ្ទេស** . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 41

# ប្រអប់


**ប្រអប់ទី១ ៖** ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើប្រាក់ចំណូល និងការចំណាយរបស់គ្រួសារ៖ ភស្តុតាងពីការអង្កេតសេដ្ឋកិច្ច-សង្គមរបស់កម្ពុជាថ្មីៗនេះ . . . 10

**ប្រអប់ទី២ ៖** កម្មវិធីមិនដំណើរការក្នុងវិស័យធនាគាររបស់កម្ពុជា . . . 15


# រូបភាព


**រូប ES.1 ៖** ទិដ្ឋភាពសង្ខេបនៃការវិវត្តថ្មីៗនៃសេដ្ឋកិច្ចរបស់កម្ពុជា . . . 4

**រូបទី១ ៖** សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញជាសាកល (PMI)៖ ការបញ្ជាទិញថ្មីសម្រាប់នាំចេញ . . . 6

**រូបទី២ ៖** កំណើនពាណិជ្ជកម្មទំនិញ . . . 6

**រូបទី៣ ៖** សកម្មភាពសេដ្ឋកិច្ចមានកម្រិតមធ្យម . . . 7

**រូបទី៤ ៖** ការរួមចំណែកដល់កំណើនការនាំចេញតាមមុខផលិតផល . . . 7

**រូបទី៥ ៖** ចំនួនភ្ញៀវមកដល់ និងចំណូលពីថ្លៃសំបុត្រចូលឧទ្យានអង្គររយៈពេល ១២ ខែ . . . 9

**រូបទី៦ ៖** កំណើនការងារប្រចាំឆ្នាំ . . . 9

**រូប B1.1 ៖** ការប្រើប្រាស់ប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់ . . . 11

**រូបទី៧ ៖** លំហូរចូលនៃ FDI តាមវិស័យ . . . 12

**រូបទី៨ ៖** FDI ពីប្រទេសចិនកើនឡើងក្នុងចំណោមប្រទេស ៦ លើគេ . . . 12

**រូបទី៩ ៖** អតិផរណាកើនឡើង . . . 14

**រូបទី១០ ៖** រូបិយវត្ថុទូទៅធីបឡើងវិញ . . . 14

**រូបទី១១ ៖** ចំណូលរដ្ឋបាលកណ្តាល . . . 17

**រូបទី១២ ៖** ប្រតិបត្តិការចំណាយរដ្ឋបាលទូទៅ . . . 17

**រូប S.1 ៖** សមិទ្ធផលពន្ធដារធ្លាក់ចុះក្រោយពីមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ . . . 22

**រូប S.2 ៖** ការងើបឡើងវិញមិនស្មើគ្នានូវចំណូលពន្ធនាមករណ៍ បានជួយលាក់បាំងភាពទន់ខ្សោយនៃរចនាសម្ព័ន្ធចំណូល . . . 23

**រូប S.3 ៖** រចនាសម្ព័ន្ធពន្ធនៅតែលម្អៀងទៅរកពន្ធប្រយោល . . . 24

**រូប S.4 ៖** ចំណូលពន្ធដែលប្រមូលបានពីមូលដ្ឋានប្រើប្រាស់ (ពន្ធប្រយោល) គឺខ្ពស់ជាងនៅប្រទេសជិតខាង . . . 24

**រូប S.5 ៖** ពន្ធលើប្រាក់ចំណូល . . . 25

រូប S.6 ៖ ប្រទេសកាន់តែមាន កាន់តែពឹងផ្អែកលើប្រាក់ចំណូល . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .25
រូប S.7 ៖ ចំណូលពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) កើនក្នុងល្បឿនយឺតជាងមុន បន្ទាប់ពីកើនឡើងខ្លាំងអស់ពេលជាច្រើនឆ្នាំ . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 26
រូប S.8 ៖ VAT សម្រេចសមិទ្ធកម្មបានល្អ ដោយចំណូលភាគច្រើនបានមកពីការនាំចូល . . . . . . . . . . . . . . . . 27
រូប S.9 ៖ ចំណូលអាករពិសេសបានធ្លាក់ចុះ និងពឹងផ្អែកលើការនាំចូល. . . . . . . . . . . . . . . . . . . . . . . . . . . . 28
រូប S.10 ៖ ចំណូលអាករពិសេសស្ថិតក្នុងចំណោមចំណូលធំជាងគេក្នុងតំបន់ ជា % នៃផ.ស.ស . . . . . . . . . . . . . 28
រូប S.11 ៖ ចំណូលមួយភាគធំត្រូវបានប្រមូលពីផលិតផលមួយចំនួនតូច . . . . . . . . . . . . . . . . . . . . . . . . . 29
រូប S.12 ៖ កម្ពុជាមានអត្រា VAT ក្នុងចំណោមអត្រាទាបបំផុតបើធៀបនឹងបណ្ដាប្រទេស មានចំណូលមធ្យមកម្រិតទាប. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 30
រូប S.13 ៖ ចំនួនម៉ោងដែលបានចំណាយលើការអនុលោមតាមកាតព្វកិច្ចពន្ធប្រចាំឆ្នាំ . . . . . . . . . . . . . . . . . . . 31
រូប S.14 ៖ អត្រាភាពក្រីក្រនៅមុន និងក្រោយពេលមានអន្តរាគមន៍សារពើពន្ធ. . . . . . . . . . . . . . . . . . . . . . . . 33
រូប S.15 ៖ មេគុណជីនី (Gini) នៅមុន និងក្រោយពេលមានអន្តរាគមន៍សារពើពន្ធ នៅកម្ពុជា. . . . . . . . . . . . . . . 33
រូប S.16 ៖ អត្រាមរណៈ (ផ្ទាំង A) និងឆ្នាំអាយុដែលបាត់បង់ដោយសារពិការភាព (DALYs) (ផ្ទាំង B) ដែលបណ្ដាលមកពីការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់ ក្នុងឆ្នាំ២០១៩ . . . . . . . . . . . . . . . . . . 34
រូប S.17 ៖ ផលចំណេញដែលអាចបានពីកំណែទម្រង់អាករលើតម្លៃបន្ថែម (VAT). . . . . . . . . . . . . . . . . . . . . 35
រូប S.18 ៖ គំនូសតាងអំពីចំណូលបានមកពីអាករលើបារី . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 38
រូប S.19 ៖ ផលចំណេញសម្រាប់ចំណូលសុទ្ធពីកំណែទម្រង់អាករលើថ្នាំជក់. . . . . . . . . . . . . . . . . . . . . . . . 38

# តារាង

តារាង ES.1 ៖ ទីផ្សារនាំចេញ ប្រភព FDI និងការងាររបស់កម្ពុជា. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 2
តារាង ES.2 ៖ ចក្ខុវិស័យម៉ាក្រូសេដ្ឋកិច្ច. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . 2
តារាងទី១ ៖ ទីផ្សារនាំចេញ, ប្រភពការវិនិយោគផ្ទាល់ពីបរទេស និងការងារនៅកម្ពុជា . . . . . . . . . . . . . . . . . . . . 8
តារាងទី២ ៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចបង្ហាញពីសកម្មភាពសេដ្ឋកិច្ចកម្រិតមធ្យម. . . . . . . . . . . . . . . . . . . 19

# កិច្ចថ្លែងអំណរគុណ

របាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា (CEU) ខែមិថុនា ឆ្នាំ២០២៥ នេះ ត្រូវបានរៀបចំឡើងដោយលោក លី សូដេត និងលោក Ildrim Valley ដោយមានការចូលរួមពីលោក Evan Harold Blecher, លោកស្រី Hana Ross, លោកស្រី Wollela Yesegat, លោក តុង គឹមស៊ុន, លោកស្រី Benu Bidani, លោក Tim L. De Vann, និងលោក Francesco Strobbe។ លោកស្រី ហ៊ាវ ចាន់កេសី ជាជំនួយការក្នុងកិច្ចការស្រាវជ្រាវ។ កញ្ញា អ៊ុំ ស៊ីណា ផ្តល់ការគាំទ្រផ្នែករដ្ឋបាល។ លោក ប៊ូ សារឿន បានជួយផ្នែកសេចក្តីប្រកាសព័ត៌មាន ការចុះផ្សាយលើគេហទំព័រ និងព្រឹត្តិការណ៍ផ្សព្វផ្សាយនានា។

ក្រុមការងារបានអនុវត្តកិច្ចការនេះក្រោមការណែនាំរួមរបស់លោក Sebastian Eckardt និងលោក Oleksii Balabushko។ ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដំបូន្មាន និងមតិយោបល់របស់លោកស្រី Lalita M. Moorty, លោកស្រី Mariam Sherman, និងលោកស្រី Tania Meyer។ សហសេវិកជាច្រើនរូប រួមមានលោក Aaditya Mattoo, លោក Ergys Islamaj, លោក Aiden Benedict Glendinning, និងលោកស្រី Ngan Hong Nguyen បានចូលរួមផ្តល់មតិយោបល់លើសេចក្តីព្រាងដែរ។

ក្រុមការងារសូមថ្លែងអំណរគុណចំពោះអាជ្ញាធរកម្ពុជា ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា សម្រាប់កិច្ចសហប្រតិបត្តិការ និងការគាំទ្ររបស់ពួកគេ។ របាយការណ៍នេះក៏ទទួលបានអត្ថប្រយោជន៍ពីដំបូន្មាន មតិយោបល់ និងទស្សនៈពីភាគីពាក់ព័ន្ធផ្សេងៗនៅកម្ពុជា រួមទាំងអ្នកអានប្រកបដោយទឹកចិត្តសោមនស្សរីករាយ និងអ្នករិះគន់ផងដែរ។

ផលិតឡើងពីរដងក្នុងមួយឆ្នាំ របាយការណ៍នេះផ្តល់ព័ត៌មានថ្មីៗអំពីការវិវត្តម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា។ វាត្រូវបានចែកចាយ និងពិភាក្សាយ៉ាងទូលំទូលាយ រួមទាំងក្នុងចំណោមអាជ្ញាធរកម្ពុជា ដៃគូអភិវឌ្ឍន៍ វិស័យឯកជន ស្ថាប័នស្រាវជ្រាវ អង្គការសង្គមស៊ីវិល និងអ្នកសិក្សាជាន់ខ្ពស់។

ប្រសិនបើលោក លោកស្រីចាប់អារម្មណ៍ចង់បានរបាយការណ៍នេះ និងការបោះពុម្ពផ្សាយដែលពាក់ព័ន្ធផ្សេងទៀត សូមទាក់ទងកញ្ញា អ៊ុំ ស៊ីណា (soum1@worldbank.org) ដើម្បីសុំបញ្ចូលអ៊ីមែលទៅក្នុងបញ្ជីចែកចាយរបាយការណ៍នេះ។ សម្រាប់សំណួរអំពីខ្លឹមសារនៃការបោះពុម្ពផ្សាយនេះ សូមទាក់ទងលោក ប៊ូ សារឿន (sbou@worldbank.org)។

រាល់គំហើញ ការបកស្រាយ និងសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍នេះ មិនសុទ្ធតែឆ្លុះបញ្ចាំងអំពីទស្សនៈរបស់នាយកប្រតិបត្តិធនាគារពិភពលោក ឬរដ្ឋាភិបាលដែលតំណាងដោយធនាគារពិភពលោកឡើយ។ ធនាគារពិភពលោកមិនធានានូវភាពត្រឹមត្រូវរបស់ទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះទេ។ ព្រំដែន ពណ៌ ការកំណត់ឈ្មោះ និងព័ត៌មានផ្សេងទៀតដែលបង្ហាញនៅលើផែនទីណាមួយក្នុងរបាយការណ៍នេះ មិនបង្កប់ន័យថាជាការវិនិច្ឆ័យពាក់ព័ន្ធស្ថានភាពផ្លូវច្បាប់របស់ដែនដីណាមួយ ឬជាការគាំទ្រ ឬការទទួលយកពីសំណាក់ធនាគារពិភពលោក នូវព្រំដែនទាំងនោះឡើយ។

# អក្សរកាត់

| | |
|---|---|
| **ASEAN** | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| **CEU** | បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា |
| **CIT** | ពន្ធលើប្រាក់ចំណូលក្រុមហ៊ុន |
| **CMT** | កាត់ ដេរ និងតម្រឹម |
| **COVID-19** | ជំងឺកូវីដ-១៩ |
| **CPI** | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ |
| **CSES** | ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |
| **DALYs** | ចំនួនឆ្នាំនៃជីវិតដែលបាត់បង់ដោយសារពិការភាព |
| **EAP** | តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក |
| **EMDE** | តំបន់ទីផ្សារកំពុងលេចឡើង និងសេដ្ឋកិច្ចកំពុងអភិវឌ្ឍ |
| **EU** | សហភាពអឺរ៉ុប |
| **FDI** | ការវិនិយោគផ្ទាល់ពីបរទេស |
| **Fed** | ធនាគារកណ្តាលសហរដ្ឋអាមេរិក |
| **FTA** | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី |
| **GDCE** | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា |
| **GDP** | ផលិតផលក្នុងស្រុកសរុប |
| **GTF** | សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង |
| **MEF** | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **NPL** | ឥណទានមិនដំណើរការ |
| **PDR** | សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យ |
| **PIT** | ពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ |
| **PMI** | សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញ |
| **QIP** | គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ |
| **RCG** | រាជរដ្ឋាភិបាលកម្ពុជា |
| **SDR** | សិទ្ធិដកប្រាក់ពិសេស |
| **SSBs** | ភេសជ្ជៈមានជាតិស្ករ |
| **UK** | ចក្រភពអង់គ្លេស |
| **U.S.** | សហរដ្ឋអាមេរិក |
| **US$** | ដុល្លារអាមេរិក |
| **VAT** | អាករលើតម្លៃបន្ថែម |
| **y/y** | ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន |

# សេចក្ដីសង្ខេប

## *ការវិវត្តថ្មីៗ*

**ដំណើរការនៃសេដ្ឋកិច្ចរបស់កម្ពុជានៅតែមានសភាពស្វាហាប់គួរសម ប៉ុន្តែមិនស្មើគ្នា។** សកម្មភាពនៃការនាំចេញ ជាពិសេសក្នុងវិស័យកាត់ដេរ និងទេសចរណ៍ នៅរក្សាបានស្ថិរភាព ដោយសារកំណើន និងការបង្កើតការងារក្នុងវិស័យកម្មន្តសាល និងសេវាកម្ម ដែលជាលទ្ធផលបានធ្វើឱ្យទំនុកចិត្ត និងការចំណាយរបស់អ្នកប្រើប្រាស់ មានភាពប្រសើរឡើង ទោះបីជាការកើនឡើងនូវភាពមិនប្រាកដប្រជាសកល និងការផ្លាស់ប្ដូរគោលនយោបាយពាណិជ្ជកម្មនាពេលថ្មីៗនេះ បង្កភាពអាប់អួរខ្លះដល់ចក្ខុវិស័យសម្រាប់ការវិស័យនាំចេញទៅពេលអនាគតក៏ដោយ។ ទន្ទឹមគ្នានេះ ការវិនិយោគក្នុងស្រុកនៅតែប្រឈមបញ្ហាសំខាន់ៗ ដែលភាគច្រើនបណ្ដាលមកពីការធ្លាក់ចុះយូរក្នុងវិស័យអចលនទ្រព្យ និងវដ្ដឥណទានដែលកំពុងរឹតបន្តឹង។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចមានសមិទ្ធកម្មមិនស្មើគ្នាទេ ដែលជាហេតុនាំឱ្យមានវិសមភាពក្នុងការលើកកម្ពស់សុខុមាលភាពគ្រួសារនៅតាមក្រុមចំណូលផ្សេងៗគ្នា។

**ទោះបីជាថមថយខ្លះក៏ដោយ ការនាំចេញទំនិញ — ជាពិសេស សម្លៀកបំពាក់ ទំនិញធ្វើដំណើរ ស្បែកជើង និងកង់ — ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក** និងសហភាពអឺរ៉ុប នៅតែរឹងមាំដដែល ដោយកើនឡើង ១១,៦ ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (y/y) ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥។ លើសពីនេះ ការនាំចេញសេវាកម្ម ដែលភាគច្រើនជាវិស័យទេសចរណ៍បានបន្តពង្រីក ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើង ១៦,១ ភាគរយ (y/y) ក្នុងអំឡុងពេលនេះ។ ទោះបីជាដំណើរមកដល់របស់ភ្ញៀវអន្តរជាតិមានការកើនឡើងជាបន្តបន្ទាប់ក៏ដោយ ក៏ចំនួនភ្ញៀវទេសចរអន្តរជាតិ (ក្រោយពេលដកអ្នកកាន់ទិដ្ឋាការធុរកិច្ច និងពលករឆ្លងដែនចេញ) នៅតែទាបជាងកម្រិតឆ្នាំ២០១៩ នៅឡើយ។ ការនាំចេញផ្នែកកម្មន្តសាលបានធ្វើឱ្យទំនុកចិត្តអ្នកប្រើប្រាស់មានភាពប្រសើរឡើង ដោយធ្វើឱ្យការនាំចូលទំនិញមិនសូវជាប់បានយូរ និងទំនិញជាប់បានយូរ (nondurable and durable goods) ងើបឡើងវិញ។ ឆ្លុះបញ្ចាំងពីការកើនឡើងនៃការប្រើប្រាស់ឯកជន ការនាំចូលគ្រឿងឧបភោគបរិភោគ និងសម្លៀកបំពាក់ បានកើនឡើង ២៥,៣ ភាគរយ និង ២៩,១ ភាគរយ ខណៈការនាំចូលរថយន្ត និងម៉ូតូបានកើនឡើងយ៉ាងគំហុក ៧៩,១ ភាគរយ និង ១៩,0 ភាគរយក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥។

**ផ្ទុយទៅវិញ ការវិនិយោគក្នុងស្រុកនៅតែងើបមិនរួចដោយសារការបន្តធ្លាក់ចុះនៅក្នុងវិស័យអចលនទ្រព្យ និងវដ្ដឥណទាន។** ត្រង់នេះគេអាចឃើញបានតាមរយៈការធ្លាក់ចុះយ៉ាងគំហុកនៃការវិនិយោគក្នុងស្រុកដែលត្រូវបានអនុម័តក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) ដែលបានធ្លាក់ចុះយ៉ាងខ្លាំង គឺ ៩៦,៧ ភាគរយក្នុងត្រីមាសទីមួយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ជាលទ្ធផល ការវិនិយោគក្នុងស្រុកឥឡូវនេះមានត្រឹមតែ ២,១ ភាគរយនៃការវិនិយោគសរុបដែលបានអនុម័ត ដែលជាការថយចុះយ៉ាងខ្លាំងពីចំណែកមួយភាគបីដែលមាននៅក្នុងសម័យមុនកូវីដ។ តាមរយៈនេះ កំណើនឥណទានក្នុងស្រុកបានធ្លាក់ចុះយ៉ាងខ្លាំងបន្ទាប់ពីមានកំណើនឆាប់រហ័សអស់រយៈយូរក្រែលដែរ។ នៅខែមីនា ឆ្នាំ២០២៥ កំណើនឥណទានបានថយចុះយ៉ាងខ្លាំង ដោយមានកម្រិត ៥ ភាគរយប៉ុណ្ណោះ ដែលជាការកើនឡើងបន្តិចពី ៤ ភាគរយដូចបានកត់ត្រាក្នុងអំឡុងពេលដូចគ្នា ក្នុងឆ្នាំ២០២៤។ ការបន្តធ្លាក់ចុះនៃការសាងសង់អចលនទ្រព្យ — ដែលជាកត្តាជំរុញដ៏ខ្លាំងនាំឱ្យមានតម្រូវការឥណទាន ការវិនិយោគឯកជន និងកំណើនសេដ្ឋកិច្ចកាលពីអតីតកាល — បានបន្តសង្កត់ទៅលើសកម្មភាពសេដ្ឋកិច្ចទាំងមូល។

**វិស័យកសិកម្ម ដែលនៅតែជាប្រភពការងារសំខាន់មួយ — គាំទ្រការងារ ៣,១ លាននាក់ ឬមួយភាគបីនៃកម្លាំងពលកម្ម — មានសមិទ្ធកម្មចម្រុះ។** ផលិតកម្មស្រូវប្រាំងបានពង្រីកយ៉ាងខ្លាំង ដោយសារការកើនឡើងនៃផ្ទៃដីដាំដុះ ដែលរួមចំណែកដល់ការកើនឡើង ១១ ភាគរយលើទិន្នផលស្រូវសរុបក្នុងឆ្នាំ២០២៤។ ទោះបីជាទិន្នផល និងផលិតកម្មស្រូវកើនឡើងក៏ដោយ ការរួមចំណែករបស់វិស័យកសិកម្មចំពោះកំណើន ផ.ស.ស. ពិតប្រាកដនៅតែមានកម្រិត និងនៅទ្រឹង ត្រឹមតែ ០,២ ចំណុចភាគរយក្នុងឆ្នាំ២០២៤។ វិស័យនេះបន្តប្រឈមនឹងបញ្ហារចនាសម្ព័ន្ធរួមទាំងការពឹងផ្អែកលើលក្ខខណ្ឌអាកាសធាតុ និងតម្លៃទំនិញដែលមិនស្ថិតស្ថេរ ដែលរារាំងសក្ដានុពលរបស់ខ្លួនក្នុងការដើរតួជាកត្តាជំរុញកំណើនសេដ្ឋកិច្ចឱ្យបានទូលំទូលាយ។

**ផ្នែកខាងក្រៅ ចំណូលពីការផ្ញើប្រាក់ចូល និងចំណូលពីទេសចរណ៍ដែលកើនឡើង បានដើរតួយ៉ាងសំខាន់ក្នុងការប៉ះប៉ូវបំពេញដល់ឱនភាពធំគួរសមនៅក្នុងពាណិជ្ជកម្មទំនិញ។** ជាមួយនឹងលំហូរចូលជាបន្តបន្ទាប់នៃការវិនិយោគផ្ទាល់ពីបរទេស និងតុល្យភាពទូទាត់ខាងក្រៅដែលមានអតិរេក ទុនបម្រុងអន្តរជាតិសរុបបានឈានដល់ ២៤,៧ ពាន់លានដុល្លារអាមេរិក ក្នុងខែមីនា ឆ្នាំ២០២៥ — ដែលជាការកើនឡើង ២៦,៤ ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន — គ្រប់គ្រាន់សម្រាប់បំពេញសេចក្ដីត្រូវការនៃការនាំចូលបានប្រហែលប្រាំពីរខែ។

**លក្ខខណ្ឌរូបិយវត្ថុមានលក្ខណៈអំណោយផលជាងមុន** ដែលជាមួយគ្នានឹងការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស បានជំរុញកំណើនរូបិយវត្ថុទូទៅឱ្យដល់ ១៩ ភាគរយក្នុងខែមីនា ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ អតិផរណាបានកើនឡើងដល់ ៣,៧ ភាគរយ ក្នុងខែមីនា ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលភាគច្រើនបណ្ដាលមកពីតម្លៃស្បៀងអាហារកើនឡើង។

**ចំពេលដែលវិស័យអចលនទ្រព្យកំពុងធ្លាក់ចុះ គុណភាពទ្រព្យសកម្មក្នុងវិស័យហិរញ្ញវត្ថុ បានបង្ហាញសញ្ញាកាន់តែយ៉ាប់យ៉ឺនដែរ។** នៅចុងឆ្នាំ២០២៤ អនុបាតប្រាក់កម្ចីដែលមិន

ដំណើរការដែលបានរាយការណ៍ឱ្យដឹង បានកើនឡើងដល់ ៧,៩ ភាគរយសម្រាប់វិស័យធនាគារ និង ៩ ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ធៀបនឹង ៥,៤ ភាគរយ និង ៦,៧ ភាគរយ ក្នុងឆ្នាំ ២០២៣ រៀងគ្នា។

**គោលនយោបាយសារពើពន្ធត្រូវបានរឹតបន្តឹង។** ចំណូលក្នុងស្រុកបានស្ទុះងើបឡើងវិញ ដោយសារតែការកើនឡើងច្រើននៃអាករលើតម្លៃបន្ថែម (VAT) និងអាករពិសេសលើការនាំចូល រួមជាមួយនឹងការកើនឡើងនៃចំណូលមិនមែនសារពើពន្ធ។ និន្នាការវិជ្ជមាននេះក្នុងការប្រមូលចំណូល ភាគច្រើនបណ្តាលមកពីការពង្រឹងការនាំចូលទំនិញ និងការរស់រានឡើងវិញនៃសកម្មភាពទេសចរណ៍។ ចំណូលរដ្ឋបាលកណ្តាលបានកើនឡើង ១១,២ ភាគរយ ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (សូមមើលអត្ថបទផ្តោតពិសេសនៃរបាយការណ៍នេះ ដែលមានចំណងជើងថា "ពង្រឹងចំណូលសម្រាប់អនាគតរបស់កម្ពុជា")។ ផ្ទុយទៅវិញ ការចំណាយសាធារណៈបានបន្តរត់នៅលើបន្ទាត់ធ្លាក់ចុះ ដោយបានថយយ៉ាងខ្លាំង ៣៥,២ ភាគរយ (y/y) ក្នុង អំឡុងពេលដូចគ្នា។ ជាលទ្ធផល ឱនភាពសារពើពន្ធត្រូវបានព្យាករថានឹងធ្លាក់ចុះបន្ថែមទៀតដល់ ២,៧ ភាគរយនៃ ផ.ស.ស. នៅឆ្នាំនេះ ពីកម្រិតប្រមាណ ៣ ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ២០២៤។ បំណុលសាធារណៈនៅតែមានកម្រិតទាប គឺមាន ២៥,៩ ភាគរយនៃ ផ.ស.ស. គិតត្រឹមចុងឆ្នាំ២០២៤។

**ដំណើរងើបឡើងវិញមិនស្មើគ្នានៃសេដ្ឋកិច្ចបន្ទាប់ពីកូវីដ-១៩ បង្កឱ្យមានវិសមភាពនៅក្នុងកិច្ចខិតខំកែលម្អសុខុមាលភាពគ្រួសារ។** ខណៈដែលមិនមានទិន្នន័យថ្មីៗ នៅចន្លោះឆ្នាំ២០២១ និង២០២៣ ការទទួលទានប្រើប្រាស់គ្រួសារសម្រាប់មនុស្សម្នាក់ៗ បានកើនឡើង ៨ ភាគរយសរុប ដែលឆ្លុះបញ្ចាំងពីការកើនឡើងសេដ្ឋកិច្ចបន្តិចម្តងៗ។ ទោះជាយ៉ាងណាក៏ដោយ អត្ថប្រយោជន៍ទាំងនេះមានការចែកចាយមិនស្មើគ្នាទេ៖ ក្រុមគ្រួសារក្រីក្របំផុត (quintile) មានការប្រើប្រាស់សម្រាប់មនុស្សម្នាក់កើនឡើង ៧ ភាគរយ ចំណែកឯក្រុមគ្រួសារមានបំផុត (quintile) មានការប្រើប្រាស់សម្រាប់មនុស្សម្នាក់កើនឡើង ១០ ភាគរយ។ វិសមភាពទាំងនេះ មួយផ្នែកគឺបណ្តាលមកពីការជាប់គាំងនៃសំណង់អចលនទ្រព្យ ដែលប៉ះពាល់ដល់អាជីវកម្មខ្នាតតូច និងពលករតាមរដូវកាល រួមទាំងកសិករដែលពឹងផ្អែកលើការងារសំណង់ និងការងារក្រៅផ្លូវការ ក្នុងអំឡុងពេលទំនេរពីរដូវធ្វើស្រែ។ វិស័យកសិកម្ម ដែលមានសារៈសំខាន់សម្រាប់ការងារ និងជីវភាពនៅជនបទ មានកំណើនបន្តិចបន្តួច ជាមួយនឹងអត្រាកំណើនពិតប្រចាំឆ្នាំជាមធ្យមត្រឹមតែ ១ ភាគរយប៉ុណ្ណោះ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤។

## ចក្ខុវិស័យ

**ក្នុងនាមជាប្រទេសតូច និងមានសេដ្ឋកិច្ចបើកចំហ កម្ពុជាងាយរងគ្រោះពីការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មពិភពលោក។** កម្មន្តសាលដែលតម្រង់ទិសនាំចេញមានចំនួនជាង ៤០ ភាគរយនៃកំណើនសេដ្ឋកិច្ច និង ១៩ ភាគរយនៃការងារមានប្រាក់ឈ្នួលសរុបនៅក្នុងប្រទេស។ សហរដ្ឋអាមេរិកជាទីផ្សារនាំចេញដ៏ធំបំផុតរបស់កម្ពុជា ដែលរួមមាន ៣៧,២ ភាគរយនៃការនាំចេញទំនិញសរុប និងគាំទ្រ ៣០,៩ ភាគរយ នៃការងារផលិតកម្មផ្លូវការ ដោយមានប្រទេសចិនជាប្រភពសំខាន់នៃការវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជា (FDI) ដែលមានចំនួន ៦៥,៥ ភាគរយនៃលំហូរ FDI សរុប (តារាង ES.1)។

**ប្រឈមមុខនឹងបញ្ហាពិភពលោក និងក្នុងស្រុក កំណើនពិតប្រាកដរបស់កម្ពុជាត្រូវបានព្យាករថានឹងថយមកនៅត្រឹម ៤ ភាគរយ នៅឆ្នាំ២០២៥ និង ៤,៥ ភាគរយ នៅឆ្នាំ២០២៦** (តារាង ES2)។ ចំពេលមានការធ្លាក់ចុះតម្រូវការខាងក្រៅ និងភាពមិនប្រាកដប្រជាខ្ពស់ ជាពិសេសជុំវិញគោលនយោបាយពាណិជ្ជកម្ម ការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យកម្មន្តសាលសម្រាប់នាំចេញដែលប្រើកម្លាំងពលកម្មច្រើន — ជាពិសេសនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង — ត្រូវបានរំពឹងថានឹងធ្លាក់ចុះ។

**តារាង ES.1 ៖ ទីផ្សារនាំចេញ ប្រភព FDI និងការងាររបស់កម្ពុជា (ភាគរយ)**

| ទំនិញនាំចេញ | | លំហូរចូល FDI (សុទ្ធ) | | ការងារវិស័យកម្មន្តសាល | |
|---|---|---|---|---|---|
| ស.រ.អា | 37.2 | ចិន | 65.5 | ស.រ.អា | 30.9 |
| អាស៊ាន | 19.0 | សិង្ហបុរី | 6.9 | អឺរ៉ុប២៧ | 22.2 |
| អឺរ៉ុប២៧ | 16.5 | សា. កូរ៉េ | 5.6 | ជប៉ុន | 8.3 |
| ចិន | 6.6 | ជប៉ុន | 4.2 | ចក្រ.អង់គ្លេស | 5.4 |
| ជប៉ុន | 5.3 | ថៃ | 3.5 | ចិន | 2.4 |
| ចក្រ.អង់គ្លេស | 3.6 | ចិនតៃវ៉ាន់ | 3.3 | អាស៊ាន | 1.3 |

*ប្រភព៖ អាជ្ញាធរកម្ពុជា* និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក
*សម្គាល់៖ ក្នុងឆ្នាំ២០២៤* ការនាំចេញទំនិញសរុប = ២៦,៦៧៣ លានដុល្លារអាមេរិក; លំហូរចូល FDI (សុទ្ធ) = ៤,៣០៦.៩ លានដុល្លារអាមេរិក; និងការងារក្នុងវិស័យកម្មន្តសាល៖ ១,១៦ លាននាក់។

**តារាង ES.2 ៖ ចក្ខុវិស័យម៉ាក្រូសេដ្ឋកិច្ច**

| គិតជា % នៃផ.ស.ស ដរាបណាមានការបញ្ជាក់ផ្ទុយពីនេះ | | | | | |
|---|---|---|---|---|---|
| | ការព្យាករ | | | ការប្រែប្រួលចាប់ពីខែធ្នូ ២០២៤ | |
| | 2025 | 2026 | 2027 | 2025 | 2026 |
| កំណើនពិតប្រាកដ (ភាគរយ) | 4.0 | 4.5 | 5.1 | -1.5 | -1.0 |
| សន្ទស្សន៍ថ្លៃទំនិញ (រយៈមធ្យម, ភាគរយ) | 4.0 | 4.0 | 4.1 | 1.8 | 1.8 |
| សមតុល្យចរន្ត | -5.2 | -4.6 | -4.6 | -3.7 | -2.8 |
| សមតុល្យសារពើពន្ធរួម | -2.7 | -2.5 | -2.0 | 0.5 | 0.6 |
| បំណុលសាធារណៈ | 26.3 | 26.2 | 26.0 | -1.1 | -1.2 |

*ប្រភព៖ អាជ្ញាធរកម្ពុជា* និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

**ផ្ទុយទៅវិញ ឧស្សាហកម្មធ្វើដំណើរ ទេសចរណ៍ និងបដិសណ្ឋារកិច្ច ត្រូវបានរំពឹងថានឹងបន្តមានស្ថានភាពកាន់ប្រសើរឡើង** មួយផ្នែកដោយសារការកែលម្អជាបន្តបន្ទាប់នៅក្នុងការតភ្ជាប់អន្តរជាតិ និងក្នុងស្រុក។ នៅក្នុងប៉ុន្មានឆ្នាំខាងមុខ ផលិតកម្មកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផលអាចទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ជាពិសេស បើបញ្ហាប្រឈមរចនាសម្ព័ន្ធមួយចំនួនក្នុងវិស័យនេះត្រូវបានដោះស្រាយ។

**សេដ្ឋកិច្ចរបស់កម្ពុជាដែលទូទាត់ជាប្រាក់ដុល្លារ ដើរនៅគន្លងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក** ដែលនាំឱ្យមានការកើនឡើងអតិផរណាតាមការគិតទុកជាមុន ដោយសារការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្មសកលដែលប៉ះពាល់ដល់អត្រាប្តូរប្រាក់ និងថ្លៃនៃការនាំចូលជាប្រាក់ដុល្លារ។ នៅក្នុងពេលដែលការនាំចេញថយល្បឿន ឱនភាពគណនីចរន្តត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងរយៈពេលខ្លី។ កិច្ចខិតខំប្រឹងប្រែងការរឹតបន្តឹងសារពើពន្ធដែលកំពុងដំណើរការ ដែលរួមមានវិធានការកែលម្អការប្រមូលពន្ធ និងការក្បិតក្បៀត ចំណាយមិនចាំបាច់ ត្រូវបានព្យាករថានឹងកាត់បន្ថយឱនភាពសារពើពន្ធទាំងមូល។

**ខណៈដែលកំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងជួយដល់ការកាត់បន្ថយភាពក្រីក្រ** អត្រានៃការកាត់បន្ថយភាពក្រីក្រនឹងថយចុះល្បឿន ស្របគ្នានឹងកំណើនយឺត ហើយបន្តមានភាពខុសគ្នានៅតាមតំបន់ និងវិស័យផ្សេងៗ។

## បញ្ហាប្រឈម និងហានិភ័យ

**នៅខាងក្រៅ កំណើនសេដ្ឋកិច្ចពិភពលោកយឺតជាងការរំពឹងទុក អាចបណ្តាលឱ្យមានការថយចុះយ៉ាងខ្លាំងនៃការនាំចេញ និងលំហូរវិនិយោគផ្ទាល់ពីបរទេស។** លទ្ធភាពនៃការរឹតត្បិតជាងមុនសម្រាប់ការចូលទៅកាន់ទីផ្សារសំខាន់ៗ ដូចជាសហរដ្ឋអាមេរិក ក៏បង្កហានិភ័យបន្ថែមផងដែរ។

**នៅក្នុងស្រុក បំណុលឯកជនកម្រិតខ្ពស់ គួបផ្សំនឹងការកើនឡើងលឿនជាងការរំពឹងទុកនៃកម្ចីមិនដំណើរការ និងហានិភ័យដែលកើតមកពីអតិផរណានាំចូល** - ដោយសារការកើនឡើងនៃអតិផរណានៅសហរដ្ឋអាមេរិក - អាចប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ និងជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ។

## ជម្រើសគោលនយោបាយ

**វិធានការគោលនយោបាយគួរតែផ្តល់អាទិភាពដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងផ្នែកហិរញ្ញវត្ថុ ដោយជំរុញកំណែទម្រង់ពាណិជ្ជកម្ម និងការវិនិយោគ និងការពង្រឹងសំណាញ់សុវត្ថិភាពសង្គម ដើម្បីការពារគ្រួសារដែលងាយរងគ្រោះ។** វិធានការទាំងនេះគួរតែរួមបញ្ចូលការធ្វើឱ្យស៊ីជម្រៅនូវកំណែទម្រង់បទប្បញ្ញត្តិ និងការលើកកម្ពស់អាជីវកម្មខ្នាតតូច ដែលការងារភាគច្រើនត្រូវបានបង្កើត និងកាត់បន្ថយថ្លៃដើមពាណិជ្ជកម្មតាមរយៈការសម្របសម្រួលពាណិជ្ជកម្ម និងការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ និងការដឹកជញ្ជូន។

**កម្ពុជាក៏អាចប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងតំបន់ (FTA)** រួមទាំងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងអាស៊ានបូក ដើម្បីជួយសម្រួលដល់ការទទួលបានទីផ្សារ និងធ្វើពិពិធកម្មភាពជាដៃគូពាណិជ្ជកម្មរបស់ខ្លួន រួមទាំងនៅក្នុងតំបន់អាស៊ានផងដែរ។

**ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ គេចាំបាច់ត្រូវអនុវត្តយុទ្ធសាស្ត្រក្នុងការដោះស្រាយទ្រព្យសកម្មដែលមានបញ្ហា ឱ្យបានគ្រប់ជ្រុងជ្រោយ** (សូមមើលប្រអប់ទី ២ ស្តីពីសំណើគោលនយោបាយ)។ ការពង្រឹងក្របខ័ណ្ឌក្ស័យធន គឺសំខាន់សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មប្រកបដោយប្រសិទ្ធភាព ធានាឱ្យបាននូវការដោះស្រាយកម្ចីមិនដំណើរការប្រកបដោយតម្លាភាព និងយុត្តិធម៌។ ក្របខ័ណ្ឌដំណោះស្រាយតាមផ្លូវធនាគារដែលរៀបចំបានល្អ គួរត្រូវបានដាក់ចេញជាឧបករណ៍សម្រាប់គ្រប់គ្រងប្រកបដោយរបៀបរៀបរយលើធនាគារដែលរកស៊ីខាត ដើម្បីកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចឱ្យនៅតិចបំផុត។ ក្នុងនេះរួមមានយន្តការ និងឧបករណ៍អន្តរាគមន៍បឋម ដូចជាការលក់ទ្រព្យសកម្ម និងការបង្កើតស្ថាប័នហិរញ្ញវត្ថុបណ្តោះអាសន្នមួយ សម្រាប់ចាត់ចែងទ្រព្យសកម្មរបស់ធនាគារដែលរកស៊ីខាត។ ការធានារ៉ាប់រងលើប្រាក់បញ្ញើ ក៏ជាធាតុផ្សំមួយទៀតនៃសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុរបស់ប្រទេស ដែលគួរត្រូវបានដាក់ចេញដែរ ដើម្បីការពារម្ចាស់ប្រាក់បញ្ញើ និងដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ។

**ក្នុងរយៈពេលមធ្យម កម្ពុជាត្រូវបង្វែរទិសនៃបែបផែនកំណើនសេដ្ឋកិច្ចរបស់ខ្លួន ឱ្យងាកចេញពីការពឹងផ្អែកលើសំណង់អចលនទ្រព្យ និងការនាំចេញសម្លៀកបំពាក់។** ការផ្លាស់ប្តូរនេះពាក់ព័ន្ធការលើកកម្ពស់វិស័យផលិតកម្ម និងសេវាកម្មដែលមានតម្លៃបន្ថែមខ្ពស់ រួមជាមួយការលើកកម្ពស់ផលិតភាពក្នុងវិស័យកសិកម្មផងដែរ។ ដើម្បីរក្សាបាននូវកំណើនប្រកបដោយចីរភាពយូរអង្វែង វាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងមូលធនមនុស្ស កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់តម្លាភាព និងប្រសិទ្ធភាពនៃបទប្បញ្ញត្តិ។ ទន្ទឹមនឹងនោះ ការបង្កើនការកៀរគរប្រាក់ចំណូលក្នុងស្រុកនឹងជួយទ្រទ្រង់ដល់ស្ថិរភាពម៉ាក្រូសារពើពន្ធ នាពេលបច្ចុប្បន្ន។

**ដូចដែលបានពិភាក្សានៅក្នុងអត្ថបទផ្តោតពិសេស ការបង្កើនធនធានឱ្យបានច្រើន គឺជាការចាំបាច់ដើម្បីឈានទៅសម្រេចតាមគោលបំណងអភិវឌ្ឍន៍** និងមហិច្ឆតានៃការចំណាយរបស់រដ្ឋាភិបាល ដូចដែលបានចែងនៅក្នុងយុទ្ធសាស្ត្របញ្ចកោណរួចហើយ។ ការពង្រឹងការកៀរគរចំណូល មានសារៈសំខាន់ណាស់នៅក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ដ៏ទូលំទូលាយរបស់កម្ពុជា និងមានសារៈសំខាន់ជាពិសេសក្នុងការឆ្លើយតបទៅនឹងតម្រូវការវិនិយោគក្នុងវិស័យសង្គម ជាពិសេសការថែទាំសុខភាព និងការអប់រំ ដែលការចំណាយនៅតែមានកម្រិតទាបនៅឡើយ ធៀបជាមួយប្រទេសដែលមានចំណូលមធ្យមកម្រិតទាបដូចគ្នា។ ប្រាក់ចំណូលកាន់តែខ្ពស់នឹងបង្កលក្ខណៈឱ្យរដ្ឋាភិបាលកែលម្អគុណភាពនៃសេវាសាធារណៈ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

## រូប ES.1 ៖ ទិដ្ឋភាពសង្ខេបនៃការវិវត្តថ្មីៗនៃសេដ្ឋកិច្ចរបស់កម្ពុជា

**សេដ្ឋកិច្ចកំពុងប្រឈមមុខនឹងភាពមិនប្រាកដប្រជាក្នុងគោលការណ៍ពាណិជ្ជកម្មសកល ...**

*កំណើនជាក់ស្តែង (ភាគរយ)*




**... សេដ្ឋកិច្ចនៅមានសកម្មភាពរឹងមាំមែន ប៉ុន្តែការនាំចេញទំនិញថយល្បឿន ...**

*ការនាំចេញទំនិញ (ដើមឆ្នាំមកដល់បច្ចុប្បន្ន, ភាគរយប្រែប្រួលធៀបនឹងឆ្នាំកន្លងទៅ)*




**... ទោះជាយ៉ាងណា ការនាំចេញសេវាកម្មបន្តមានភាពប្រសើរឡើង ...**

*ការមកដល់នៃភ្ញៀវអន្តរជាតិ (លាននាក់)*




**... អតិផរណាឡើង ...**

*(ភាគរយប្រែប្រួលធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន)*




**... កំណើនរូបិយវត្ថុទូទៅ (M2) ងើបឡើងវិញ ...**

*បំណុលរូបិយវត្ថុទូទៅ (ភាគរយប្រែប្រួលធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន)*




**... ខណៈដែលការប្រមូលចំណូលក្នុងស្រុកមានភាពប្រសើរខ្លះៗ**

*(ភាគរយប្រែប្រួលធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន)*




*ប្រភព៖ អាជ្ញាធរកម្ពុជា, ការព្យាកររបស់បុគ្គលិកធនាគារពិភពលោក។*

*សម្គាល់៖* e = ការប៉ាន់ប្រមាណ; p = ការព្យាករ; y/y = ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន

# ជំពូកទី ១

## ការវិវត្តសេដ្ឋកិច្ចនាពេលថ្មីៗ និងចក្ខុវិស័យ






*ប្រភព៖ Haver;* ធនាគារពិភពលោក។
*សម្គាល់៖ បង្ហាញសមាសភាគសន្ទស្សន៍* PMI សកល, ផ្នែកកម្មន្តសាល និងសេវាកម្ម។ តួលេខលើសបន្ទាត់បង្ហាញពីការពង្រីក ហើយតួលេខក្រោមបន្ទាត់បង្ហាញពីការធ្លាក់ចុះ។




*ប្រភព៖ ការិយាល័យវិភាគគោលនយោបាយសេដ្ឋកិច្ច* CPB នៃប្រទេសហូឡង់។
*សម្គាល់៖ រូបភាពនេះបង្ហាញពីការផ្លាស់ប្តូរគិតជាភាគរយ* (y/y) នៃបរិមាណពាណិជ្ជកម្មទំនិញ។ ពាណិជ្ជកម្មទំនិញត្រូវបានវាស់វែងជាមធ្យមនៃបរិមាណនាំចេញនិងនាំចូល។ ការសង្កេតចុងក្រោយ ខែសីហា ឆ្នាំ២០២៤។
*Q* = ត្រីមាស

*ការវិវត្តថ្មីៗ*

# បរិយាកាសកលលោកកាន់តែស្មុគ្រស្មាញ

**ចក្ខុវិស័យសម្រាប់សកម្មភាពសេដ្ឋកិច្ចសកលបានចុះខ្សោយ ដែលឆ្លុះបញ្ចាំងពីភាពមិនប្រាកដប្រជាដែលកំពុងកើនឡើងចំពេលមានការផ្លាស់ប្តូរគោលការណ៍ពាណិជ្ជកម្មធំៗ។**[1] នៅក្នុងបរិបទនេះ ការព្យាករជាកុងសង់ស៊ុសសម្រាប់កំណើនសកលនៅឆ្នាំនេះបានធ្លាក់ចុះគួរឱ្យកត់សម្គាល់។ អារម្មណ៍វិនិយោគិនក៏បានបង្ហាញសញ្ញាថាចុះខ្សោយផងដែរ។ សូចនាករសកម្មភាពសកលដែលមានប្រេ្យកង់ខ្ពស់ មានទិដ្ឋភាពចម្រុះ និងផ្ទុយគ្នាខ្លះរវាងការអង្កេតទៅលើផ្នែកកម្មន្តសាល និងសេវាកម្ម។ ថ្លៃទំនិញប្រើប្រាស់បានធ្លាក់ចុះជារួម នៅខែមីនា និងចូលខែមេសា ដោយសារតម្លៃថាមពល និងវត្ថុធាតុដើមទាបជាងមុន។

**នៅចុងឆ្នាំ២០២៤ សន្ទស្សន៍អ្នកគ្រប់គ្រងការបញ្ជាទិញជាសាកល (PMI) សម្រាប់សេវាកម្មលើការបញ្ជាទិញថ្មីសម្រាប់នាំចេញ បានបង្ហាញថាការងើបឡើងវិញនៃពាណិជ្ជកម្មសេវាកម្មមានស្ថិរភាព** ដែលឆ្លុះបញ្ចាំងពីការថយចុះនៃកំណើនសេវាកម្មទេសចរណ៍ (រូបទី១)។[2] ទិន្នន័យថ្មីៗស្តីពីការមកដល់របស់ភ្ញៀវទេសចរ បង្ហាញថា សកម្មភាពទេសចរណ៍បានងើបឡើងវិញ ដល់កម្រិតមុនពេលមានជំងឺរាតត្បាតនៅស្ទើរតែគ្រប់តំបន់លើកលែងតែតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដែលនៅអនុវត្តវិធានការត្រួតពិនិត្យជំងឺរាតត្បាតដ៏តឹងរ៉ឹងនៅឡើយ។ ជាលទ្ធផលសន្ទុះខ្សល់ពីការងើបឡើងវិញនៃវិស័យទេសចរណ៍សកលបានរសាត់បាត់ទៅវិញ លើកលែងតែនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។

**ការងើបឡើងវិញនៃការជួញដូរទំនិញសកលក្នុងឆ្នាំមុនមិនដូចគ្នាទេនៅតាមក្រុមប្រទេសផ្សេងៗគ្នា។** ពាណិជ្ជកម្មទំនិញបានពង្រីកជាលំដាប់នៅតាមប្រទេសដែលជាទីផ្សារថ្មី និងមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍ (EMDEs) ប៉ុន្តែនៅតែខ្សោយនៅប្រទេសសេដ្ឋកិច្ចជឿនលឿនភាគច្រើន ដោយសារតែកំណើនមានភាពយឺតយ៉ាវ លើកលែងតែសហរដ្ឋអាមេរិក (រូបទី២)។ ទោះជាយ៉ាងណាក៏ដោយ នៅទូទាំងពិភពលោក គោលនយោបាយរឹតបន្តឹងពាណិជ្ជកម្មថ្មីដែលបានដាក់ចេញនៅឆ្នាំ២០២៤ មានចំនួនច្រើន គឺខ្ពស់ជាងមធ្យមភាគឆ្នាំ២០១០-១៩ ដល់ទៅប្រាំដង ហើយឡើងជិតដល់កម្រិតខ្ពស់បំផុតដែលបានកត់ត្រាក្នុងឆ្នាំ២០២៣។

# សកម្មភាពសេដ្ឋកិច្ចនៅតែមានភាពស្វាហាប់ ប៉ុន្តែមិនស្មើគ្នា

**ទិន្នន័យដែលមានប្រេ្យកង់ខ្ពស់សម្រាប់ត្រីមាសទីមួយនៃឆ្នាំនេះបង្ហាញថា សកម្មភាពសេដ្ឋកិច្ចនៅតែមានភាពស្វាហាប់**ជាចម្បងដោយសារមានការជំរុញពីកំណើនខ្លាំងគួរសមនៅ

---
1 “Global Monthly” 2025.
2 ធនាគារពិភពលោក 2025a.

**រូបទី៣ ៖ សកម្មភាពសេដ្ឋកិច្ចមានកម្រិតមធ្យម**

*ការរួមចំណែកដល់កំណើនផ.ស.សពិត (ភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា* និងការព្យាករដោយបុគ្គលិកធនាគារពិភពលោក

*សម្គាល់៖ e* = ការប៉ាន់ប្រមាណ; p = ការព្យាករ។

**រូបទី៤ ៖ ការរួមចំណែកដល់កំណើនការនាំចេញតាមមុខផលិតផល**

*(ពីដើមឆ្នាំដល់បច្ចុប្បន្ន, ភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ GTF* = សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង; YTD = ពីដើមឆ្នាំដល់បច្ចុប្បន្ន។

ក្នុងវិស័យកម្មន្តសាលផ្នែកសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF) អមដោយការពង្រីកនៅក្នុងវិស័យកម្មន្តសាលមិនមែន GTF និងសេវាកម្ម ជាពិសេសផ្នែកទេសចរណ៍ និងការធ្វើដំណើរ។ ការដាំដុះនិងផលិតកម្មស្រូវប្រាំងក៏បានកើនផងដែរក្នុងអំឡុងពេលនេះ។ ការវាយតម្លៃបឋមរបស់អាជ្ញាធរកម្ពុជាបង្ហាញថា កំណើនពិតប្រាកដបានពង្រីកដល់ ៦ ភាគរយនៅឆ្នាំ២០២៤ (រូបទី៣)។

**បើមើលពីជ្រុងនៃការចំណាយវិញ កំណើនសេដ្ឋកិច្ចបានមកដោយសារការនាំចេញទំនិញមានភាពស្វាហាប់** ដោយក្នុងនោះ ការនាំចេញទៅកាន់ទីផ្សារអាមេរិកមានទំហំស្មើនឹង ៣០ ភាគរយនៃ ផ.ស.ស, ការស្ទុះងើបឡើងវិញនៃសេវាកម្មការនាំចេញ - ជាពិសេសចំណូលទេសចរណ៍ - និងការងើបឡើងវិញខ្លះៗនៃការប្រើប្រាស់ឯកជន ដែលទាំងអស់នេះបានរួម ចំណែកដល់កំណើនរហូតដល់ត្រីមាសទី១ ឆ្នាំ២០២៥។ ទំនុកចិត្តរបស់អ្នកប្រើប្រាស់ បានកើនឡើង ដោយសារការនាំចេញផលិតកម្មមានភាពរឹងមាំ ដែលធ្វើឱ្យការប្រើប្រាស់ឯកជនងើបឡើងវិញនៅតាមផ្នែកមួយចំនួន ដូចដែលបានបង្ហាញតាមរយៈការងើបឡើងវិញដំបូងនៅក្នុងការនាំចូលទំនិញដែលប្រើប្រាស់ជាប់មិនបានយូរ និងទំនិញដែលប្រើប្រាស់ជាប់បានយូរ។

**ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចមានសមិទ្ធកម្មមិនស្មើគ្នាទេនៅតាមវិស័យផ្សេងៗ។** ខណៈដែលវិស័យផ្លូវការនៅតែមានសភាពស្វាហាប់ ជាពិសេសការនាំចេញផលិតផលកម្មន្តសាលមានការជំរុញខ្លាំងពីផ្នែកកាត់ដេរសម្លៀកបំពាក់ ទំនិញធ្វើដំណើរ ស្បែកជើង និងកង់ ទៅកាន់ទីផ្សារអាមេរិក និងសហភាពអឺរ៉ុប, វិស័យក្រៅផ្លូវការដែលមានទំហំធំ - ជាពិសេសការលក់រាយបែបប្រពៃណី និងសេវាកម្មក្រៅផ្លូវការ - នៅតែមានដំណើរការយឺតយ៉ាវ ដោយសារការធ្លាក់ចុះយ៉ាងខ្លាំងនៃកំណើនឥណទានក្នុងស្រុក និងការកែប្រែប្រួលនៃទីផ្សារអចលនទ្រព្យ។ ការធ្លាក់ចុះជាបន្តបន្ទាប់នៃការសាងសង់អចលនទ្រព្យ - ដែលជាកត្តាជំរុញដ៏ខ្លាំងនៃតម្រូវការឥណទាន ការវិនិយោគឯកជន និងកំណើនកន្លងមក - បានបន្តសង្កត់លើសកម្មភាពសេដ្ឋកិច្ចទាំងមូល។

# ការនាំចេញបង្កើនល្បឿន ចំពេលមានការផ្លាស់ប្តូរគោលការណ៍ពាណិជ្ជកម្មសកលបង្កឱបសគ្គបន្ថែម

**ការនាំចេញទំនិញសរុប — ជាពិសេសសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ទៅកាន់ទីផ្សារអាមេរិក** និងសហភាពអឺរ៉ុប — នៅតែមានសភាពស្វាហាប់ ប៉ុន្តែក៏បានបង្ហាញសញ្ញានៃការបង្កើនល្បឿនជាលំដាប់ដែរ ដោយទទួលបានកំណើន ១១,៦ ភាគរយ ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន(រូបទី៤)។ ការនាំចេញសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង បានរួមចំណែកដល់កំណើននៃការនាំចេញទំនិញសរុប ក្នុងកម្រិត ៦,៤, ១,០ និង ១,៨ ចំណុចភាគរយរៀងៗខ្លួន។ ក្នុងចំណោមផលិតផលកម្មន្តសាលមិនមែនសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង, ការនាំចេញរួមគ្នានៃគ្រឿងបន្លាស់យានយន្ត គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់និងគ្រឿងបង្គុំអគ្គិសនី បានរួមចំណែក ១,៣ ចំណុចភាគរយដល់កំណើននៃការនាំចេញទំនិញសរុប រីឯការ

នាំចេញកង់រួមចំណែកបាន ០,៥ ចំណុចភាគរយ។ ការរួមចំណែកនៃការនាំចេញទំនិញកសិកម្មដល់កំណើនការនាំចេញសរុប គឺអវិជ្ជមាន ១,១ ចំណុចភាគរយ។

**ឆ្លុះបញ្ចាំងពីការនាំចូលខ្ពស់នូវវត្ថុធាតុដើមសម្រាប់បម្រើដល់ការនាំចេញរបស់កម្ពុជា និងការងើបឡើងវិញខ្លះៗនៃតម្រូវការក្នុងស្រុក, កំណើននៃការនាំចូលបានបង្ហាញឱ្យឃើញអំពីសមិទ្ធកិច្ចនៃដំណើរការនាំចេញ ដោយសម្រេចបាន ១៨,៥ ភាគរយ ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។** ការនាំចូលក្រណាត់ ដែលជាមុខទំនិញនាំចូលធំជាងគេដែលប្រើប្រាស់ជាចម្បងក្នុងការផលិតសម្លៀកបំពាក់ បានកើនឡើង ២០,៦ ភាគរយ។ បន្ទាប់មកទៀតគឺការកើនឡើងចំនួន ៣,១ ភាគរយ ក្នុងការនាំចូលគ្រឿងបង្គុំអេឡិចត្រូនិក និងអគ្គិសនី ដែលត្រូវបានប្រើសម្រាប់ការដំឡើងនិងផលិតគ្រឿងបន្លាស់សម្រាប់គ្រឿងអេឡិចត្រូនិក និងអគ្គិសនី។ លើសពីនេះការនាំចូលគ្រឿងបរិក្ខារសំណង់ ជាចម្បងសម្រាប់អគារហេដ្ឋារចនាសម្ព័ន្ធរូបវន្ត បានកើនឡើង ២៦,២ ភាគរយ។

**ជាប្រទេសមានសេដ្ឋកិច្ចតូចនិងបើកចំហ កម្ពុជាងាយរងគ្រោះពីការផ្លាស់ប្តូរគោលការណ៍ពាណិជ្ជកម្មសកល ដែលកំពុងតែកើតមាន។** ផលិតផលសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ជាវិស័យដែលប្រឈមជាងគេទៅនឹងហានិភ័យ ដោយសារតែវាបានរួមចំណែក ៤០ ភាគរយដល់កំណើន ផ.ស.ស ពិតប្រាកដ ក្នុងឆ្នាំ២០២៤។ សហរដ្ឋអាមេរិកជាទីផ្សារនាំចេញធំបំផុតរបស់កម្ពុជា ដែលស្រូបយក ៣៧,២ ភាគរយ នៃការនាំចេញសរុប និងទ្រទ្រង់ដល់ ៣០,៩ ភាគរយ នៃការងារក្នុងវិស័យកម្មន្តសាលផ្លូវការ ខណៈដែលចិនជាប្រភពចម្បងនៃការវិនិយោគផ្ទាល់ពីបរទេសរបស់កម្ពុជា ដែលមានចំនួន ៦៥,៥ ភាគរយនៃលំហូរចូល FDI សុទ្ធសរុប (តារាងទី១)។

**ការបាត់បង់លទ្ធភាពចូលទៅកាន់ទីផ្សារធំៗ អាចជះផលប៉ះពាល់យ៉ាងខ្លាំងដល់វិស័យកម្មន្តសាលសម្រាប់ការនាំចេញ និងប្រើប្រាស់កម្លាំងពលកម្មច្រើនរបស់កម្ពុជា។** បច្ចុប្បន្ន វិស័យកម្មន្តសាលផ្លូវការផ្តល់ការងារដល់ប្រជាជន ១,២ លាននាក់ ដែលស្មើនឹង ១៩,៤ ភាគរយនៃការងារមិនមែនកសិកម្ម និង ១២,៥ ភាគរយនៃការងារសរុបនៅក្នុងប្រទេស។ ផ្នែកដ៏សំខាន់នៃការងារទាំងនេះ (៨៣,៧ ភាគរយ) គឺប្រមូលផ្តុំនៅក្នុងឧស្សាហកម្មផលិតសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ក្នុងនោះ ៨០ ភាគរយ នៃកម្លាំងពលកម្មគឺជាស្ត្រី។ កម្មករនៅក្នុងឧស្សាហកម្មទាំងនេះទទួលបានប្រាក់ឈ្នួលអប្បបរមា ២០៨ ដុល្លារអាមេរិកក្នុងមួយខែ និងអនុវត្តតាមបទដ្ឋានការងារដែលរដ្ឋាភិបាលបានបង្កើតឡើង។ តាមការប៉ាន់ប្រមាណ ទីផ្សារអាមេរិកទ្រទ្រង់ដល់ជិតមួយភាគបីនៃការងារក្នុងវិស័យកម្មន្តសាលនេះ។ ផលប៉ះពាល់ពីការបាត់បង់ការងារក្នុងវិស័យនេះ នឹងប៉ះទង្គិចខ្លាំងលើសលប់ទៅលើឱកាសការងារសម្រាប់ស្ត្រី ព្រោះថាកម្មការិនីនៅក្នុងវិស័យនេះមានចំនួនប្រហែល ៤០ ភាគរយ នៃការងារមានប្រាក់កម្រៃរបស់ស្ត្រីសរុបចំនួន ១,៩ លាននាក់។

## ការចំណាយរបស់ភ្ញៀវទេសចរបរទេសកើនឡើង ប៉ុន្តែនៅតែទាបជាងកម្រិតឆ្នាំ២០១៩

**ការងើបឡើងវិញខ្លះៗនៃការចំណាយរបស់ភ្ញៀវទេសចរ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈការកើនឡើង ១៣,២ ភាគរយនៃចំណូលពីការសំបុត្រចូលទស្សនាប្រាសាទអង្គរ ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ធៀបទៅនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។** ចំណូលពីការសំបុត្រចូលក្នុងអំឡុងពេលនេះបានកើនឡើងដល់ ១៨,៧ លានដុល្លារអាមេរិក ប៉ុន្តែវាតំណាងឱ្យតែ ៥២ ភាគរយនៃការប្រមូលបានក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០១៩ ប៉ុណ្ណោះ ហើយកើនតែបន្តិចទេ ពី ៤៦ ភាគរយក្នុងឆ្នាំ២០២៤។ ចំណូលពីទេសចរណ៍នៅឆ្នាំ២០២៤ ត្រូវអាជ្ញាធរកម្ពុជាប៉ាន់ប្រមាណថាបានឈានដល់ ៣ ៦៣៧ លានដុល្លារអាមេរិក ដែលជាការកើនឡើង ១៨ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំកន្លងទៅ (២០២៣) ដែលរួមចំណែក ៩,៤ ភាគរយដល់ ផ.ស.ស។ ចំណូលនេះតំណាងឱ្យ ៧៤ ភាគរយនៃចំណូលទេសចរណ៍ឆ្នាំ២០១៩ ប៉ុន្តែកើនពី ៦៣ ភាគរយ ក្នុងឆ្នាំ២០២៣។ ចំនួនការងារដោយផ្ទាល់ដែលវិស័យនេះបង្កើតបាន កើនឡើងដល់ ០,៥១ លាននាក់ក្នុងឆ្នាំ២០២៤ ពី ០,៤៥ លាននាក់ក្នុងឆ្នាំ២០២៣។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះនៅតែទាបជាង ០,៦៣ លានការងារដោយផ្ទាល់ដែលបានកត់ត្រាក្នុងឆ្នាំ២០១៩។

**តារាងទី១ ៖ ទីផ្សារនាំចេញ, ប្រភពការវិនិយោគផ្ទាល់ពីបរទេស និងការងារនៅកម្ពុជា (ជាភាគរយ)**

| ទំនិញនាំចេញ | | លំហូរ FDI (សុទ្ធ) | | ការងារកម្មន្តសាល | |
|---|---|---|---|---|---|
| ស.រ.អា | 37.2 | ចិន | 65.5 | ស.រ.អា | 30.9 |
| អាស៊ាន | 19.0 | សិង្ហបុរី | 6.9 | អឺរ៉ុប២៧ | 22.2 |
| អឺរ៉ុប២៧ | 16.5 | សា. កូរ៉េ | 5.6 | ជប៉ុន | 8.3 |
| ចិន | 6.6 | ជប៉ុន | 4.2 | ចក្រ.អង់គ្លេស | 5.4 |
| ជប៉ុន | 5.3 | ថៃ | 3.5 | ចិន | 2.4 |
| ចក្រ.អង់គ្លេស | 3.6 | ចិនតៃវ៉ាន់ | 3.3 | អាស៊ាន | 1.3 |

*ប្រភព៖ អាជ្ញាធរកម្ពុជា* និងការប៉ាន់ប្រមាណដោយបុគ្គលិកធនាគារពិភពលោក។
*សម្គាល់៖ ក្នុងឆ្នាំ២០២៤* ការនាំចេញទំនិញសរុប = ២៦.៦៧៣ លានដុល្លារអាមេរិក; លំហូរចូល FDI (សុទ្ធ) = ៤.៣០៦,៩ លានដុល្លារអាមេរិក; និងការងារក្នុងវិស័យកម្មន្តសាល៖ ១,១៦ លាននាក់។

**ចាប់តាំងពីឆ្នាំ២០២៤មក ចំនួនភ្ញៀវអន្តរជាតិដែលមកដល់បានឈានដល់កម្រិតនៅមុនពេលមានការរាតត្បាតកូវីដ-១៩** (រូបទី៥)។ ទិន្នន័យបានបង្ហាញថា ចំនួនភ្ញៀវអន្តរជាតិសរុបបានឈានដល់ ១,៨ លាននាក់ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥

**រូបទី៥ ៖ ចំនួនភ្ញៀវមកដល់ និងចំណូលពីថ្លៃសំបុត្រចូលឧទ្យានអង្គររយៈពេល ១២ ខែ**

*(២០១៩ = ១០០)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

*សម្គាល់៖ GTF* = សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង; YTD = ពីដើមឆ្នាំដល់បច្ចុប្បន្ន។

**រូបទី៦ ៖ កំណើនការងារប្រចាំឆ្នាំ**

*(ជាភាគរយ)*




*ប្រភព៖ ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា។*

ដែលតំណាងឱ្យការកើនឡើង ១៦,១ ភាគរយធៀបនឹងឆ្នាំមុន និងស្មើនឹងកម្រិតឆ្នាំ២០១៩។ យ៉ាងណាក៏ដោយ ចំនួនភ្ញៀវទេសចរ — មិនរាប់បញ្ចូលអ្នកកាន់ទិដ្ឋាការធុរកិច្ច និងពលករឆ្លងដែន — មានត្រឹមតែ ១,៣ លាននាក់ប៉ុណ្ណោះ។ ចំនួននេះបង្ហាញពីការថយចុះពីចំនួនភ្ញៀវទេសចរ ១,៥ លាននាក់ដែលបានកត់ត្រាក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០១៩។ មានន័យថា ថ្វីត្បិតតែការធ្វើដំណើរអន្តរជាតិសរុបបានងើបឡើងវិញក៏ដោយ ផ្នែកទេសចរណ៍មិនទាន់ត្រឡប់ទៅរកកម្រិតនៅមុនពេលមានជំងឺរាតត្បាតនៅឡើយទេ។

**ក្រៅពីនេះ មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងសមាសភាគនៃភ្ញៀវទេសចរ។** មុនពេលមានជំងឺរាតត្បាត ការមកដល់តាមផ្លូវអាកាសមានចំនួនពីរភាគបីនៃការមកដល់សរុប ប៉ុន្តែនិន្នាការនេះបានប្រែប្រួលក្រោយកូវីដ-១៩។ ភ្ញៀវទេសចរចិន ដែលធ្លាប់មានចំនួនជិត ៤០ ភាគរយនៃអ្នកទស្សនា បានថយចុះមកត្រឹម ១៧,៧ ភាគរយក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ដែលជាការកើនឡើងពី ១២ ភាគរយក្នុងឆ្នាំ២០២៤។ ឥឡូវនេះ ពួកគេឈរនៅចំណាត់ថ្នាក់ទីបី បន្ទាប់ពីភ្ញៀវទេសចរថៃ ២៦,១ ភាគរយ និងភ្ញៀវទេសចរវៀតណាម ១៧,៩ ភាគរយ។

## ការងារក្នុងផ្នែកកម្មន្តសាលកើនខ្លាំងមែន ប៉ុន្តែការបង្កើតការងារទូទៅនៅមានកម្រិត

**នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ការពង្រីកការនាំចេញទំនិញបាននាំឱ្យមានការកើនឡើងគួរឱ្យកត់សម្គាល់នៃចំនួនរោងចក្រ និងការងារនៅក្នុងវិស័យកម្មន្តសាល។** គិតត្រឹមខែមីនា ឆ្នាំ២០២៥ ចំនួនរោងចក្របានកើនឡើងដល់ ២ ៥៣៩ ក្នុងនោះ ៥៣,៨ ភាគរយជារោងចក្រសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ដែលជាការកើនឡើង ១៦,៧ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ស្រដៀងគ្នានេះ ការងារនៅក្នុងវិស័យនេះបានកើនឡើងដល់ ១,២ លានការងារ ក្នុងនេះ ៨៣,៧ ភាគរយត្រូវបានរួមចំណែកពីឧស្សាហកម្ម សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង ដែលឆ្លុះបញ្ចាំងពីការកើនឡើង ១៣,៣ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ភាគច្រើននៃកំណើនការងារនេះ (៨៩ ភាគរយ) គឺបានមកពីឧស្សាហកម្ម សម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើង។

**ទោះបីជាមានការកើនឡើងនៃការងារក្នុងវិស័យកម្មន្តសាលក៏ដោយ លក្ខខណ្ឌទីផ្សារការងារសរុបនៅតែមានភាពយឺតយ៉ាវ។** វិស័យកម្មន្តសាលផ្លូវការមានចំនួនត្រឹមតែ ១៩,៤ ភាគរយនៃការងារមិនមែនកសិកម្ម និង ១២,៥ ភាគរយនៃការងារសរុបប៉ុណ្ណោះ។[3] គំហើញពីការអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា បញ្ជាក់ពីទីផ្សារការងារដែលសភាពយឺតយ៉ាវ។ យោងតាមទិន្នន័យការងារពីការអង្កេតនេះ កំណើនការងារបានថយចុះយ៉ាងខ្លាំងក្នុងអំឡុងពេលក្រោយមានជំងឺរាតត្បាត។ កំណើនការងារប្រចាំឆ្នាំបានថយចុះមកត្រឹម ១,១ ភាគរយក្នុងអំឡុងឆ្នាំ២០១៩-២៣ ធ្លាក់ចុះពី ៤,២ ភាគរយក្នុងអំឡុងឆ្នាំ២០០៩-១៧ (រូបទី៦)។

**គំហើញពីការអង្កេតបានបង្ហាញពីការងើបឡើងវិញគួរឱ្យកត់សម្គាល់នៃការងារក្នុងវិស័យផ្លូវការ ដោយចំណែកនៃការងារដែលមានប្រាក់កម្រៃបានកើនឡើងដល់ ៥១,៤ ភាគរយ ក្នុងឆ្នាំ២០២៣។** ការងើបឡើងវិញនេះគឺជាការស្ទុះឡើងជាបណ្តើរៗនៃការងារដែលមានប្រាក់ខែ ក្រោយពីមានការបាត់បង់ច្រើនដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩។

3 ក្រសួងផែនការ ២០២៤

**ប្រអប់ទី១ ៖ ផលប៉ះពាល់នៃជំងឺកូវីដ-១៩ លើប្រាក់ចំណូល និងការចំណាយរបស់គ្រួសារ៖ ភស្តុតាងពីការអង្កេតសេដ្ឋកិច្ច-សង្គមរបស់កម្ពុជាថ្មីៗនេះ[1]**

**សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាមានកំណើនរឹងមាំ ដោយសម្រេចបានជាមធ្យម ៧,៦ ភាគរយក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៩។** កំណើននេះបានធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានកំណើនលឿនជាងគេទីប្រាំមួយនៅលើពិភពលោក និងជាប្រទេសទីបួនក្នុងចំណោមប្រទេសដែលមានចំណូលមធ្យម។ អត្រានៃភាពក្រីក្ររបស់ប្រទេសកម្ពុជាបានធ្លាក់ចុះពាក់កណ្ដាល ពី ៣៣,៨ ភាគរយក្នុងឆ្នាំ២០០៩ មកនៅត្រឹម ១៧,៨ ភាគរយក្នុងឆ្នាំ២០១៩/២០ ដោយមានការថយចុះទាំង នៅតំបន់ទីក្រុង និងជនបទ។ ការកាត់បន្ថយភាពក្រីក្រក្នុងទ្រង់ទ្រាយធំនេះ គឺដោយសារតែមានប្រាក់ចំណូលខ្ពស់ពីការនាំចេញ ផលិតផលកសិកម្ម វិស័យកម្មន្តសាលអតិពលកម្ម និងការងាររបស់សេដ្ឋកិច្ចទៅធ្វើសកម្មភាពក្រៅពីកសិកម្មផ្សេងទៀត។

**ជំងឺរាតត្បាត និងការរាំងស្ទះសេដ្ឋកិច្ចជាសកលដែលពាក់ព័ន្ធ បានបង្កឱ្យមានវិបត្តិសេដ្ឋកិច្ចលើកដំបូងរបស់ប្រទេសកម្ពុជាក្នុងរយៈពេល ២៥ ឆ្នាំ ដោយ ផ.ស.ស សម្រាប់មនុស្សម្នាក់បានធ្លាក់ចុះ ៥ ភាគរយក្នុងឆ្នាំ២០២០។** រាជរដ្ឋាភិបាលបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន ១,៣ ពាន់លានដុល្លារអាមេរិក ដើម្បីកាត់បន្ថយផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច ដែលបានផ្ដល់អត្ថប្រយោជន៍ដល់គ្រួសារជិត ៧០០ ០០០ គ្រួសារ និងប្រជាជន ២,៨ លាននាក់ (១៦ ភាគរយនៃប្រជាជនសរុប)។ នៅពេលសេដ្ឋកិច្ចចាប់ផ្ដើមងើបឡើងវិញក្នុងឆ្នាំ២០២១ ជាមួយនឹងកំណើន ផ.ស.ស ១,៦ ភាគរយ សម្រាប់មនុស្សម្នាក់, វិស័យទេសចរណ៍ និងសំណង់នៅតែរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ អត្រាអ្នកគ្មានការងារធ្វើបានថយចុះ ប៉ុន្តែមនុស្សជាច្រើនបានប្ដូរទៅធ្វើការងារមានប្រាក់ខែទាបជាងមុនក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម។ ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់បានធ្លាក់ចុះ ៨ ភាគរយ ក្នុងឆ្នាំ២០២១ ដែលបណ្ដាលមកពីការថយចុះនៃប្រភពចំណូលភាគច្រើន ទោះបីជាការផ្ញើប្រាក់ចូលពីក្រៅប្រទេសបានកើនឡើងគួរឱ្យកត់សម្គាល់ពីកម្រិតទាបក៏ដោយ។ ការចំណាយសម្រាប់មនុស្សម្នាក់បានធ្លាក់ចុះលឿនជាងប្រាក់ចំណូល ដោយមានការធ្លាក់ចុះ ២៤ ភាគរយក្នុងឆ្នាំ២០២១។ ការកាត់បន្ថយឱកាសនៃការចំណាយដោយសារការបិទខ្ទប់ និងភាពមិនប្រាកដប្រជាខ្ពស់អំពីអនាគត បានជំរុញឱ្យគ្រួសារសន្សំសំចៃ នៅពេលដែលសមាមាត្រនៃគ្រួសារដែលរាយការណ៍ថាមានប្រាក់ចំណូលលើសពីការចំណាយ (ការសន្សំ) បានកើនឡើង។

**នៅឆ្នាំ២០២២ និង២០២៣ សេដ្ឋកិច្ចបានបន្តងើបឡើងវិញ ប៉ុន្តែកំណើននៅតែទាបជាងកម្រិតនៅមុនពេលមានជំងឺរាតត្បាត។** វិស័យទេសចរណ៍បានបង្ហាញពីការស្ទុះងើបឡើងវិញគួរឱ្យកត់សម្គាល់ក្នុងឆ្នាំ២០២៣ ប៉ុន្តែនៅតែទាបជាងកម្រិតឆ្នាំ២០១៩។ វិស័យសំណង់នៅតែចុះខ្សោយ។ អតិផរណាបានឡើងដល់កម្រិតខ្ពស់បំផុតក្នុងរយៈពេល ១៣ ឆ្នាំ គឺ ៧,៨ ភាគរយក្នុងខែមិថុនា ឆ្នាំ២០២២ ដោយសារតែការកើនឡើងនៃតម្លៃថាមពល ជី និងស្បៀងអាហារជាសកល ក្នុងខែមិថុនា ឆ្នាំ២០២២។ រដូវផលិតកម្ម ឆ្នាំ២០២២-២៣ បានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតធ្ងន់ធ្ងរ ដែលធ្វើឱ្យផលិតកម្មស្រូវថយចុះ។

**ប្រាក់ចំណូលសម្រាប់មនុស្សម្នាក់បាននៅទ្រឹងក្នុងឆ្នាំ២០២៣ ដោយនៅតែទាបជាងកម្រិតមុនពេលផ្ទុះជំងឺរាតត្បាតក្នុងកម្រិតជាតិ ប៉ុន្តែក្រុមប្រជាជនស្រទាប់ក្រោមគេបង្អស់ ៤០ភាគរយ មានចំនួនកើនឡើង ១១ ភាគរយ ថែមទៀត ដោយឈានដល់កម្រិតមុនពេលមានជំងឺរាតត្បាត ដោយសារការពង្រីកកម្មវិធីគាំពារសង្គមទៅដល់គ្រួសារដែលងាយរងគ្រោះ។** ការងើបឡើងវិញនេះមានលក្ខណៈគាំទ្រដល់អ្នកក្រីក្រ ដោយប្រាក់ចំណូលកើនឡើងលឿនជាងក្នុងចំណោមអ្នកក្រីក្របំផុត។ ប្រាក់ចំណូលរបស់ក្រុមប្រជាជនស្រទាប់ខាងលើ ៦០ភាគរយ បានធ្លាក់ចុះបន្ថែមទៀត។ និយោជិត ដែលបង្កើតបានជាចំណែកធំបំផុតនៃកម្លាំងពលកម្ម ជាពិសេសក្នុងចំណោមក្រុមប្រជាជនស្រទាប់ក្រោមគេបង្អស់ ៤០ភាគរយ មានទំនោរធ្វើការច្រើនម៉ោងជាងមុន ដោយសារប្រាក់ឈ្នួលពិតប្រាកដធ្លាក់ចុះ។ ឧទាហរណ៍ ប្រាក់ឈ្នួលអប្បបរមាពិតប្រាកដក្នុងវិស័យកាត់ដេរ វាយនភណ្ឌ និងស្បែកជើងបានថយចុះពី ៧៥៥ ០០០ រៀលក្នុងឆ្នាំ២០២០ មកនៅត្រឹម ៧២១ ០០០ រៀលក្នុងឆ្នាំ២០២៣។

**ចំពេលដែលប្រាក់ចំណូលនៅទ្រឹង ការចំណាយសម្រាប់មនុស្សម្នាក់បានកើនឡើងក្នុងឆ្នាំ២០២៣ ដោយសារគ្រួសារបានដកយកប្រាក់សន្សំមកប្រើប្រាស់ដើម្បីទ្រទ្រង់កម្រិតជីវភាពរបស់ពួកគេ។** ការចំណាយសម្រាប់មនុស្សម្នាក់បានកើនឡើង ១០ ភាគរយ រវាងឆ្នាំ២០២១ និង២០២៣ ជាហេតុធ្វើឱ្យប្រាក់សន្សំសម្រាប់មនុស្សម្នាក់បានធ្លាក់ចុះ ៦៦ ភាគរយ។ ការចំណាយមិនមែនម្ហូបអាហារបានកើនឡើងគួរឱ្យកត់សម្គាល់ គឺជិត១៦ ភាគរយ ខណៈដែលការចំណាយលើម្ហូបអាហារមានការកើនឡើងតិចតួចត្រឹមតែ ២ ភាគរយប៉ុណ្ណោះ។ ការទទួលកាឡូរីអាហារក៏បានកើនឡើង ៤ ភាគរយផងដែរ។ បើប្រៀបធៀបទៅនឹងកម្រិត មុនពេលផ្ទុះជំងឺរាតត្បាតការចំណាយសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០២៣ នៅតែទាបជាងឆ្នាំ២០១៩/២០ ដោយក្រុមប្រជាជន ស្រទាប់ក្រោមគេ ៤០ភាគរយ មានការធ្លាក់ចុះតិចជាងក្រុមប្រជាជនស្រទាប់លើ ៦០ភាគរយ។ សេដ្ឋកិច្ច

របស់ប្រទេសកម្ពុជាកំពុងងើបឡើងវិញ ប៉ុន្តែមិនទាន់វិលត្រឡប់ទៅរកកម្រិតមុនពេលមានជំងឺរាតត្បាតនៅឡើយទេ ហើយការងើបឡើងវិញនេះមានរបាយមិនស្មើគ្នារវាងក្រុមប្រាក់ចំណូលផ្សេងៗគ្នា។

**ហេតុការណ៍អង្រួនកន្ត្រាក់ផ្នែកពាណិជ្ជកម្ម ដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចថយចុះ អាចបង្កផលប៉ះពាល់ដ៏ស្មុគស្មាញ និងអវិជ្ជមានទៅលើសុខុមាលភាព ជាពិសេសក្នុងចំណោមប្រជាជនក្រីក្រ។** វិស័យនាំចេញ ដូចជាវិស័យកាត់ដេរ ដែលមានកម្មករជាង ៧០០ ០០០ នាក់ ដែលភាគច្រើនជាស្ត្រី អាចរងគ្រោះដោយសារតម្រូវការធ្លាក់ចុះ ដែលនាំឱ្យមានការបាត់បង់ការងារ និងការកាត់បន្ថយប្រាក់ចំណូល ដែលជាហេតុធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចកាន់តែដុនដាប។ ក្នុងស្ថានភាពនេះ វាមានសារៈសំខាន់ណាស់ក្នុងការរក្សាការចំណាយលើកម្មវិធីសង្គម ជាពិសេសលើវិស័យសុខាភិបាល និងអប់រំ ព្រោះការចំណាយនេះជួយបង្កើនការអភិវឌ្ឍមូលធនមនុស្ស និងផ្តល់ឱកាសដល់អ្នកក្រីក្រដើម្បីកែលម្អស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។

**រូប B1.1 ៖ ការប្រើប្រាស់ប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់**




*ប្រភព៖ ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។*

1. ប្រអប់នេះត្រូវបានរៀបចំឡើងដោយលោក តុង គឹមស៊ុន ក្រោមការណែនាំរបស់ Benu Bidani។

**ផ្ទុយទៅវិញ សកម្មភាពសេដ្ឋកិច្ចក្នុងវិស័យក្រៅប្រព័ន្ធដែលមានទំហំធំរួមមានផ្នែកលក់រាយ និងលក់ដុំបែបប្រពៃណី មានការរីកចម្រើនយឺតជាង។** សកម្មភាពសាងសង់អចលនទ្រព្យដែលបានជាប់គាំង បានជះឥទ្ធិពលអវិជ្ជមានដល់អាជីវកម្មខ្នាតតូច និងពលករតាមរដូវកាល ជាពិសេសកសិករដែលទទួលធ្វើការងារសំណង់ និងសេវាកម្មក្រៅប្រព័ន្ធ បន្ទាប់ពីរដូវដាំដុះ និងប្រមូលផលស្រូវ។ ត្រង់នេះអាចឆ្លុះបញ្ចាំងនៅក្នុងការថយចុះនៃចំណែកនៃពលករស្វ័យនិយោជន៍ ដែលបានធ្លាក់ចុះមកនៅប្រហែល ៣៥ ភាគរយ ពី ៤៥ ភាគរយក្នុងអំឡុងពេលមុនកូវីដ។ លើសពីនេះ ដូចដែលបានពិភាក្សាពីមុន ចំនួនការងារផ្ទាល់ដែលបង្កើតឡើងដោយវិស័យទេសចរណ៍ក្នុងឆ្នាំ២០២៤ នៅតែទាបជាងកម្រិតមុនពេលមានជំងឺរាតត្បាត គឺមានតែប្រហែល ៥១ម៉ឺន កន្លែងប៉ុណ្ណោះ បើធៀបនឹង ៦៣ម៉ឺន កន្លែង ក្នុងឆ្នាំ២០១៩។

**បើគិតតាមភូមិសាស្ត្រ រាជធានីភ្នំពេញ ដែលធ្លាប់មានការរីកលូតលាស់ខ្លាំងក្នុងវិស័យសំណង់ និងអចលនទ្រព្យក្នុងអំឡុងពេលមុនមានជំងឺរាតត្បាត បានរងផលប៉ះទង្គិចខ្លាំងជាងគេ។** នៅរាជធានីភ្នំពេញ ការងារបានកើនឡើង ៥,៦ ភាគរយ ដែលជាអត្រាខ្ពស់បំផុតក្នុងអំឡុងឆ្នាំ២០០៩-១៧ នៅពេលដែលរាជធានីមានការរីកលូតលាស់ខ្លាំងផ្នែកសំណង់ និងការប្រើប្រាស់។ ប៉ុន្តែ កំណើនការងារនៅក្នុងរាជធានីបានថយចុះមកនៅត្រឹម ១,៧ ភាគរយក្នុងអំឡុងឆ្នាំ២០១៩-២៣។ ស្រដៀងគ្នានេះដែរ កំណើនការងារនៅតំបន់ទីក្រុងផ្សេងទៀត ដែលធ្លាប់ទទួលបានអត្ថប្រយោជន៍ពីការរីកចម្រើនផ្នែកសំណង់ដែរនោះ ក៏បានថយចុះមកនៅត្រឹម ១,៣ ភាគរយ ពី ៤,៩ ភាគរយក្នុងអំឡុងពេលដូចគ្នា។ កំណើនការងារនៅតំបន់ជនបទក៏បានធ្លាក់ចុះមកនៅត្រឹម ០,៨ ភាគរយ ពី ៣ ភាគរយក្នុងអំឡុងពេលដូចគ្នា។

**ស្ថានភាពសេដ្ឋកិច្ចមិនស្មើគ្នានៅតាមវិស័យនានា អាចបង្កវិសមភាពក្នុងការកែលម្អសុខុមាលភាពគ្រួសារ។** ជាសរុបរវាងឆ្នាំ២០២១ និង២០២៣ ការចំណាយសម្រាប់មនុស្សម្នាក់ក្នុងមួយគ្រួសារបានកើនឡើង ៨ ភាគរយ ដែលជាសញ្ញានៃការវឌ្ឍនភាពសេដ្ឋកិច្ចបន្តិចម្តងៗ។ ប៉ុន្តែ អត្ថប្រយោជន៍ទាំងនេះត្រូវបានចែកចាយមិនស្មើគ្នា — ការចំណាយសម្រាប់មនុស្ស ម្នាក់បាន កើនឡើង ៧ ភាគរយសម្រាប់ក្រុមប្រជាជនក្រីក្របំផុតមួយភាគប្រាំ បើធៀបនឹង ១០ ភាគរយសម្រាប់ក្រុមប្រជាជនមានបំផុតមួយភាគប្រាំ (សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលប្រអប់ទី១)។

**រូបទី៧ ៖ លំហូរចូលនៃ FDI តាមវិស័យ**
*(%ចំណែក, សុទ្ធ, មិនរាប់បញ្ចូលវិស័យហិរញ្ញវត្ថុ, ២០២៤)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*
*សម្គាល់៖ GTF = សម្លៀកបំពាក់កាត់ដេរ ទំនិញធ្វើដំណើរ និងស្បែកជើង។*

**រូបទី៨ ៖ FDI ពីប្រទេសចិនកើនឡើងក្នុងចំណោមប្រទេស ៦ លើគេ**
*(% នៃតម្លៃសរុប)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

## គម្រោងវិនិយោគផ្ទាល់ពីបរទេសដែលបានអនុម័តកើនឡើង ប៉ុន្តែការវិនិយោគក្នុងស្រុកធ្លាក់ចុះខ្លាំង

**តម្រូវការច្រើននៅក្រៅប្រទេស បានទាក់ទាញអ្នកវិនិយោគបរទេសមករកស៊ីក្នុងវិស័យនាំចេញនៅកម្ពុជា។** ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ តម្លៃវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលត្រូវបានអនុម័ត ក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIP) (ក្រៅតំបន់សេដ្ឋកិច្ចពិសេស) បានកើនឡើងដល់ ៦៣០ លានដុល្លារអាមេរិក ដែលជាការកើនឡើង ១៩ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ប៉ុន្តែ តួលេខនេះនៅតែទាបជាងកម្រិតមុនពេលមុនផ្ទុះជំងឺរាតត្បាត ដែលមានចំនួន ៨០១ លានដុល្លារអាមេរិក។

**វិស័យកាត់ដេរបានទាក់ទាញជិតពីរភាគបីនៃតម្លៃគម្រោង FDI ដែលត្រូវបានអនុម័ត។** ការកើនឡើងនៃការវិនិយោគនេះគឺមួយផ្នែកបានមកដោយសារតែការនាំចេញផលិតផលកាត់ដេរដ៏រស់រវើកក្នុងរយៈពេលមួយឆ្នាំកន្លងមក ដែលអាចមកពីការផ្លាស់ប្តូរទីតាំងនៃខ្សែច្រវាក់ផ្គត់ផ្គង់ពីប្រទេសបង់ក្លាដែសដែរ។ វិស័យកម្មន្តសាលមិនមែនកាត់ដេរ ដែលរួមមាន ថាមពល ទំនិញធ្វើដំណើរ ស្បែកជើង និងសកម្មភាពផលិតកម្មផ្សេងទៀត បានក្លាយជាវិស័យធំទីពីរ មានទំហំមួយភាគបីនៃតម្លៃគម្រោង FDI ដែលត្រូវបានអនុម័តសរុប។ ផ្ទុយទៅវិញ វិស័យសំណង់ និងអចលនទ្រព្យ ដែលពីមុនមានទំហំស្មើនឹងបីភាគបួននៃតម្លៃគម្រោង FDI ដែលត្រូវបានអនុម័តសរុបក្នុងឆ្នាំ២០១៩ បច្ចុប្បន្នមិនទទួលបាន FDI ដែលត្រូវបានអនុម័តឡើយ។ ត្រង់នេះបង្ហាញពីការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងការផ្តោតនិងអាទិភាពនៃការវិនិយោគ។

**ទោះបីជាមានការកើនឡើងនៃតម្លៃគម្រោង FDI ដែលត្រូវបានអនុម័តក៏ដោយ តម្លៃនៃការវិនិយោគក្នុងស្រុកដែលត្រូវបានអនុម័ត បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ដោយរួញអស់ ៩៦,៧ ភាគរយ មកនៅត្រឹមតែ ២៣ លានដុល្លារអាមេរិក ប៉ុណ្ណោះក្នុងអំឡុងត្រីមាសទីមួយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។** វាមានត្រឹមតែ ២,១ ភាគរយនៃតម្លៃវិនិយោគដែលត្រូវបានអនុម័តសរុបប៉ុណ្ណោះ។ នេះបង្ហាញពីការបន្តធ្លាក់ចុះនៃចំណង់របស់វិនិយោគិនក្នុងស្រុក ក្នុងការវិនិយោគលើវិស័យដែលអាចធ្វើពាណិជ្ជកម្មបាន។ ក្នុងអំឡុងពេលមុនផ្ទុះជំងឺរាតត្បាត ការវិនិយោគក្នុងស្រុកមានប្រហែលមួយភាគបីនៃតម្លៃវិនិយោគដែលត្រូវបានអនុម័តសរុប ដោយមូលនិធិភាគច្រើនត្រូវបានបែងចែកទៅវិស័យសំណង់ និងអចលនទ្រព្យ។

**នៅក្នុងសម័យក្រោយមានជំងឺរាតត្បាត មានការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងលំនាំនៃលំហូរចូល FDI ពិតប្រាកដ ដោយមានការផ្តោតកាន់តែខ្លាំងទៅលើវិស័យជាក់លាក់ដូចជា វិស័យកាត់ដេរ ទំនិញធ្វើដំណើរ និងស្បែកជើង។** យោងតាមទិន្នន័យពីធនាគារកណ្តាល ចំណែកនៃ FDI ដែលបានវិនិយោគក្នុងវិស័យកាត់ដេរ ទំនិញធ្វើដំណើរ និងស្បែកជើងបានកើនឡើងដល់ ២៥,៤ ភាគរយ នៃលំហូរចូល FDI សរុបទៅកាន់វិស័យពិតប្រាកដក្នុងឆ្នាំ២០២៤ (រូបទី៧) ពីកម្រិត ២២,៦ ភាគរយក្នុងឆ្នាំ២០១៩។ នេះបង្ហាញពីការប្រមូលផ្តុំ ជាជាងការធ្វើពិពិធកម្មរបស់ឧស្សាហកម្មកាត់ដេរ ទំនិញធ្វើដំណើរ និង ស្បែកជើង។ ស្រដៀងគ្នានេះដែរ FDI របស់ចិនជាចំណែកនៃលំហូរចូល FDI សរុបបានឡើងដល់ ៦៥,៥ ភាគរយក្នុងឆ្នាំ២០២៤ ពី ៤១,៣ ភាគរយក្នុងឆ្នាំ២០១៩ ដែលបង្ហាញពីការកើនឡើងនៃការពឹងផ្អែកលើការវិនិយោគពីប្រទេសចិន (រូបទី៨)។

# ការនាំចេញកសិផលមានទិដ្ឋភាពចម្រុះ ទោះបីជាផលិតកម្មស្រូវកើនឡើងក៏ដោយ

**ក្នុងចំណោមទំនិញកសិកម្មកំពូលទាំងប្រាំ ការនាំចេញគ្រាប់ស្វាយចន្ទី និងអង្ករបានកើនឡើងចំនួន ៦,២ ភាគរយ និង ២០,៨ ភាគរយ រៀងខ្លួន ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ នេះ បើយោងតាមទិន្នន័យនាំចេញផ្លូវការរបស់អាជ្ញាធរ។** ទោះជាយ៉ាងណា ការនាំចេញដំឡូងមី និងកៅស៊ូបានធ្លាក់ចុះ ២៣,២ ភាគរយ និង ១៣,៥ ភាគរយ រៀងខ្លួន។ សម្រាប់ឧស្សាហកម្មឈើ និងកែច្នៃឈើ ការនាំចេញផលិតផលឈើ និងគ្រឿងសង្ហារិមបានកើនឡើង ដោយមានកំណើន ១០,៦ ភាគរយ ពីមួយឆ្នាំទៅមួយឆ្នាំក្នុងអំឡុងពេលនេះ។

**ការដាំដុះ និងផលិតកម្មស្រូវប្រាំង បានកើនឡើងយ៉ាងឆាប់រហ័សក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ដោយកើនឡើង ៨% និង ៧,៥% រៀងខ្លួន។** យោងតាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឆ្នាំ២០២៤ ផលិតកម្មស្រូវសរុបបានកើនឡើង ១១ ភាគរយ ឈានដល់ ១៣,៩ លានតោនម៉ែត្រ។ ផលិតកម្មស្រូវវស្សា ដែលស្មើនឹងប្រហែលបីភាគបួននៃផលិតកម្មស្រូវសរុប បានកើនឡើង ៧,៥ ភាគរយ រីឯផលិតកម្មស្រូវប្រាំងបានកើនឡើងខ្លាំង ដោយពង្រីកបាន ២២,១ ភាគរយ។ ផលិតកម្មស្រូវប្រាំងកើនឡើង គឺដោយសារការកើនឡើង ជាចម្បងនូវផ្ទៃដីដាំដុះ។ ទិន្នផលស្រូវវស្សា និងស្រូវប្រាំង បានកើនឡើងតិចតួចចំនួន ២ ភាគរយ និង ០,២ ភាគរយ រៀងខ្លួន។ ទោះបីជាមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីជំរុញវិស័យកសិកម្មក៏ដោយ ផលិតកម្មដំណាំរបស់កម្ពុជានៅតែពឹងផ្អែកលើអាកាសធាតុ ហើយតម្លៃទំនិញកសិកម្មនៅតែមិនសូវមានស្ថិរភាព។ ការរួមចំណែករបស់វិស័យកសិកម្មដល់កំណើន ផ.ស.ស ពិតប្រាកដនៅតែមានកម្រិត និងនៅទ្រឹង ដោយមានការរួមចំណែកប្រចាំឆ្នាំ ០,២ ចំណុចភាគរយ ប៉ុណ្ណោះ ក្នុងអំឡុងពេលឆ្នាំ២០២១-២៤ បើប្រៀបធៀបនឹង ៣,៥ ចំណុច ភាគរយពីវិស័យឧស្សាហកម្ម និង ០,៨ ចំណុចភាគរយពីវិស័យសេវាកម្ម។ ទោះជាយ៉ាងណា វិស័យនេះបន្តផ្តល់ការងារកសិកម្មចំនួន ៣,១ លាននាក់ ដែលស្មើនឹង ៣៣,៤ ភាគរយនៃការងារសរុប។

# ទំនុកចិត្តអ្នកប្រើប្រាស់មានភាពប្រសើរ លើកកម្ពស់ការប្រើប្រាស់

**ការងើបឡើងវិញមួយផ្នែកនៃការប្រើប្រាស់ឯកជន ដែលបានចាប់ផ្តើមនៅឆ្នាំ២០២៤ បានបន្តរហូតដល់ឆ្នាំនេះ។** និន្នាការនេះទំនងជាត្រូវបានគាំទ្រដោយការកែលម្អទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងការពង្រីកជាបន្តបន្ទាប់នៃការនាំចេញផលិតផលកម្មន្តសាល ដែលបានរួមចំណែកដល់ការបង្កើតការងារ និងការកើនឡើងនូវប្រាក់ចំណូល។ ការផ្ញើប្រាក់របស់ពលករពីក្រៅប្រទេស ក៏មានភាពប្រសើរឡើងផងដែរ។ ការងើបឡើងវិញមួយផ្នែកនៃការប្រើប្រាស់ឯកជន បានជួយជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក និងបង្កើនតម្រូវការសម្រាប់ទំនិញប្រើប្រាស់ ដោយសារការប្រើប្រាស់ឯកជនស្មើនឹងប្រមាណ ៦០ ភាគរយ នៃផ.ស.ស។

**ក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ការនាំចូលទំនិញបានកើនឡើង ១៨,៥ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។** មុខទំនិញនាំចូលសំខាន់ៗមួយចំនួនក្នុងចំណោមទំនិញមិនជាប់បានយូរបានបន្តកើនឡើង។ ការនាំចូលគ្រឿងឧបភោគបរិភោគ សម្លៀកបំពាក់កាត់ដេរ និងឱសថបានកើនឡើង ២៥,៣ ភាគរយ, ២៩,១ ភាគរយ និង ២២,៩ ភាគរយ រៀងខ្លួន។ ស្រដៀងគ្នានេះដែរ ការនាំចូលទំនិញប្រើប្រាស់បានយូរ ក៏កើនឡើងផងដែរ។ ក្នុងអំឡុងពេលដូចគ្នា ការនាំចូលរថយន្តដឹកអ្នកដំណើរ និងម៉ូតូបានកើនឡើងយ៉ាងខ្លាំង ដោយកើនឡើង ៧៩,១ ភាគរយ និង ១៩,០ ភាគរយ រៀងខ្លួន ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។

# អតិផរណាបានងើបឡើងបន្តិច ដោយសារការឡើងថ្លៃនៃស្បៀងអាហារ

**អតិផរណាបានកើនឡើងដល់ ៣,៧ ភាគរយ ក្នុងខែមីនា ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលបណ្តាលមកពីការឡើងថ្លៃស្បៀងអាហារ** (រូបទី៩)។ ទោះបីជាតម្លៃស្រូវបន្តធ្លាក់ចុះក៏ដោយ តម្លៃជាមធ្យមនៃសាច់ ត្រី ផ្លែឈើ និងបន្លែបានកើនឡើង ដែលនាំឱ្យមានការកើនឡើងនៃសន្ទស្សន៍រងរបស់សមាសភាគស្បៀងអាហារ។ ដោយសារសន្ទស្សន៍រងស្បៀងអាហារមានបន្ទុក ៤៣ ភាគរយនៅក្នុងកញ្ចប់អតិផរណា វាបានរួមចំណែកដល់ការកើនឡើងអតិផរណាសរុប។ លើសពីនេះ តម្លៃជាមធ្យមនៃសម្លៀកបំពាក់ និងស្បែកជើង ក៏ដូចជាសេវាប្រើប្រាស់ ក៏បានកើនឡើងផងដែរ។ ប៉ុន្តែ តម្លៃផលិតផលប្រេងឥន្ធនៈបានធ្លាក់ចុះបន្តិចក្នុងអំឡុងពេលដូចគ្នា។

**ថ្លៃទំនិញក្នុងស្រុកនៅកម្ពុជារត់តាមយ៉ាងប្រកៀកជាមួយនិន្នាការសកល ដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់សេដ្ឋកិច្ចតូច បើកចំហ និងពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារ របស់ប្រទេសនេះ។** ក្នុងអំឡុងពេលនេះ ថ្លៃសាច់គោ និងសាច់មាន់ជាសកលបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយកើនឡើង ១៨,១ ភាគរយ និង ៦,៥ ភាគរយ រៀងខ្លួន ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ផ្ទុយទៅវិញ តម្លៃស្រូវជាសកល (ថៃ, ៥ ភាគរយបាក់) បានធ្លាក់ចុះយ៉ាងខ្លាំងចំនួន ២៧,៧ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ខណៈដែលសន្ទស្សន៍តម្លៃថាមពលបានថយចុះ ៤,១ ភាគរយ យោងតាមរបាយការណ៍ Pink Sheet របស់ធនាគារពិភពលោក។[4]

4 ឯកសារ Pink Sheet របស់ធនាគារពិភពលោកផ្តល់ទិន្នន័យតម្លៃទំនិញ។

**រូបទី៩ ៖ អតិផរណាកើនឡើង**

*ការរួមចំណែកដល់អតិផរណា ១២ខែ*

*(ចំណុចភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

*សម្គាល់៖ y/y* = ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន

**រូបទី១០ ៖ រូបិយវត្ថុទូទៅងើបឡើងវិញ**

*ការរួមចំណែកដល់កំណើនរូបិយវត្ថុទូទៅ*

*(ចំណុចភាគរយ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា។*

**ក្នុងខែមីនា ឆ្នាំ២០២៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) របស់កម្ពុជា ដោយមិនរាប់បញ្ចូលមុខទំនិញស្បៀងអាហារ មានការកើនឡើងតិចតួច ចំនួន ០,៩ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលបង្ហាញឱ្យឃើញថាអតិផរណាមានស្ថិរភាពនៅក្នុងសន្ទស្សន៍ថ្លៃទំនិញមិនមែនម្ហូបអាហារ។**

## នៅពេលដែលការនាំចូលបានស្ទុះងើបឡើង ឱនភាពនៃគណនីចរន្តរីកកាន់តែធំ

**ការនាំចូលទំនិញបានកើនឡើងយ៉ាងឆាប់រហ័ស ដោយកើនឡើង ១៨,៥ ភាគរយ ក្នុងត្រីមាសទីមួយឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលច្រើនជាងកំណើននៃការ នាំចេញទំនិញ ដែលបានកើនឡើង ១១,៦ ភាគរយ។** ជាលទ្ធផល ឱនភាពគណនីចរន្តបានកើនឡើង។ នៅឆ្នាំ២០២៥ លំហូរចូលមូលធនដ៏ស្វាហាប់ជាបន្តបន្ទាប់ ជាពិសេស FDI បានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់។ ដោយសារមានអតិរេកជញ្ជីងទូទាត់សរុប ទុនបម្រុងអន្តរជាតិសរុបរបស់ប្រទេសបានកើនឡើងដល់ ២៤,៧ ពាន់លានដុល្លារអាមេរិក ដែលជាការកើនឡើង ២៦,៤ ភាគរយ គិតត្រឹមខែមីនា ឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលសមមូលទៅនឹងការនាំចូលប្រហែលប្រាំពីរខែ។ លំហូរចូល FDI ជាបន្តបន្ទាប់ ប្រាក់បញ្ញើពីពលករក្រៅស្រុក និងការងើបឡើងវិញមួយផ្នែកនៃចំណូលពីទេសចរណ៍ បានជួយបំពេញហិរញ្ញប្បទានដល់ឱនភាពគណនីចរន្ត ដែលត្រូវបានព្យាករថានឹងកើនឡើងដល់ប្រមាណ ៥ ភាគរយនៃ ផ.ស.ស ក្នុងឆ្នាំ២០២៥។

## ប្រាក់រៀលបានឡើងថ្លៃបន្តិច រីឯអត្រាការប្រាក់បានធ្លាក់ចុះ

**ទោះបីជាឱនភាពគណនីចរន្តរីកធំជាងមុនក៏ដោយ សម្ពាធថ្លៃលើរូបិយបណ្ណក្នុងស្រុក និងអត្រាការប្រាក់ក្នុងស្រុកមានភាពធូរស្រាលបន្តិច** ខណៈដែលសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងលើប្រាក់ដុល្លាររបស់កម្ពុជា ដើរតាមគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក។ ធនាគារកណ្តាលសហរដ្ឋអាមេរិក (Fed) បានរក្សាអត្រាការប្រាក់មូលនិធិសហព័ន្ធ ក្នុងចន្លោះគោលដៅពី ៤% ទៅ ៤១/២ ភាគរយ ក្នុងខែមីនា ឆ្នាំ២០២៥។[5] អត្រាការប្រាក់លើប្រាក់បញ្ញើជាដុល្លារអាមេរិកក្នុងស្រុកបានធ្លាក់ចុះ។ ដោយសារតម្រូវការឥណទានក្នុងស្រុកបានធ្លាក់ចុះចំពេលមានការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ អត្រាការប្រាក់លើប្រាក់បញ្ញើជាដុល្លារអាមេរិកក្នុងស្រុកបានធ្លាក់ចុះមកនៅត្រឹម ៤,៦៥ ភាគរយក្នុងមួយឆ្នាំក្នុងខែមីនា ឆ្នាំ២០២៥ ពី ៥,៦៧ ភាគរយ ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។ អត្រាការប្រាក់កម្ចីជាដុល្លារអាមេរិកនៅតែមិនផ្លាស់ប្តូរច្រើន ដោយនៅត្រឹម ១០,១ ភាគរយ។

**ទន្ទឹមនឹងនេះ អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិក បានឡើងថ្លៃបន្តិចបន្តួចក្នុងខែឧសភា ឆ្នាំ២០២៥** ដោយមួយដុល្លារដូរបានតែ ៤,០០២ រៀលទេ ធៀបទៅនឹង ៤,០៩៣ រៀលក្នុងមួយដុល្លារអាមេរិក ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។

**ប្រតិបត្តិការទីផ្សារបើកចំហរបស់ធនាគារកណ្តាល អនុវត្តការទិញចូលសុទ្ធនៃរូបិយបណ្ណដុល្លារអាមេរិកកើនឡើងដល់ ១១៦,៩ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៤ បើធៀបនឹងការ**

5 United States Federal Reserve 2025

**លក់ចេញសុទ្ធចំនួន ១២៣,៩ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣។** ប្រាក់រៀលក៏បានឡើងថ្លៃធៀបនឹងប្រាក់យាន់ចិន និងប្រាក់ដុងវៀតណាម ដោយក្នុងមួយយាន់ ដូរបានតែ ៥៥១ រៀល និងមួយដុង ដូរបានតែ ០,១៥៦ រៀល ទេ ក្នុងខែមីនា ឆ្នាំ២០២៥ ធៀបនឹង ៥៥៩ រៀលក្នុងមួយយាន់ និង ០,១៦៣ រៀលក្នុងមួយដុង ក្នុង អំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។ ផ្ទុយទៅវិញ ប្រាក់រៀលបាន ធ្លាក់ថ្លៃធៀបនឹងប្រាក់បាតថៃ គឺធ្លាក់ដល់ ១១៨ រៀលក្នុងមួយបាត ពី ១១១ រៀលក្នុងមួយបាតក្នុងអំឡុងពេលដូចគ្នា។

## ការផ្គត់ផ្គង់សាច់ប្រាក់កើនឡើង រីឯកំណើនឥណទានស្រុតចុះបន្តិច

**កំណើនរូបិយវត្ថុទូទៅបានកើនឡើងបន្ថែមទៀត ដោយពង្រីក ១៩ ភាគរយ ក្នុងរយៈពេល ១២ ខែ ចប់ត្រឹមខែមីនា ឆ្នាំ២០២៥ ពី ១៤ ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដោយសារការកើនឡើងនៃប្រាក់បញ្ញើជារូបិយបណ្ណបរទេស។** ក្នុងចំណោមកំណើនរូបិយវត្ថុក្នុងទូទៅ ១៩,៩ ភាគរយ ការរួមចំណែកនៃប្រាក់បញ្ញើជារូបិយបណ្ណបរទេស (និងប្រាក់បញ្ញើផ្សេងទៀត) គឺធំជាងគេ ស្មើនឹង ១៤ ចំណុចភាគរយ ដោយសារសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើប្រាក់ដុល្លារ។ ការរួមចំណែកនៃប្រាក់បញ្ញើដែលអាចផ្ទេរបាន និងរូបិយវត្ថុក្នុងចរាចរណ៍ស្មើនឹង ៤,៦ ចំណុចភាគរយ និង ០,៤ ចំណុចភាគរយ រៀងខ្លួន ក្នុងអំឡុងពេលដូចគ្នា (រូបទី១០)។

**ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០២៣មក កំណើនឥណទានក្នុងស្រុកបានធ្លាក់ចុះយ៉ាងគំហុក ក្រោយកើនយ៉ាងឆាប់រហ័សបានមួយរយៈ។** ក្នុងខែមីនា ឆ្នាំ២០២៥ កំណើនឥណទាននៅតែមានកម្រិតទាប ដោយសម្រេចបាន ៥ ភាគរយ ប៉ុណ្ណោះ ដែលកើនបន្តិចពី ៤ ភាគរយ ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដោយសារតម្រូវការឥណទានក្នុងស្រុកបានធ្លាក់ចុះទន្ទឹមគ្នានឹងការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ។ ឥណទានក្នុងស្រុកដល់ផ្នែកសំណង់ អចលនទ្រព្យ និងកម្ចីទិញផ្ទះ ស្មើនឹងមួយភាគបីនៃឥណទានសរុបដែលមិនទាន់បានសង។ ក្នុងឆ្នាំ២០១៩ ឥណទានក្នុងស្រុកបានកើនឡើង ២៧ ភាគរយពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារការរីកចម្រើនខ្លាំងក្នុងវិស័យសំណង់ និងអចលនទ្រព្យ។

**ចំពេលមានការធ្លាក់ចុះនៃវិស័យអចលនទ្រព្យ គុណភាពទ្រព្យសកម្មរបស់វិស័យធនាគារបានបង្ហាញសញ្ញានៃការធ្លាក់ចុះដែរ។** នៅចុងឆ្នាំ២០២៤ អត្រាកម្ចីមិនដំណើរការដែលបានរាយការណ៍ឱ្យដឹង បានកើនឡើងដល់ ៧,៩ ភាគរយសម្រាប់វិស័យធនាគារ និង ៩ ភាគរយសម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ បើប្រៀបធៀបនឹង ៥,៤ ភាគរយ និង ៦,៧ ភាគរយ រៀងខ្លួន ក្នុងឆ្នាំ២០២៣ (សូមមើលប្រអប់ទី២ សម្រាប់ការពិភាក្សាសង្ខេបអំពីកម្ចីមិនដំណើរការក្នុងវិស័យធនាគាររបស់កម្ពុជា)។

**ការថយចុះនៃកំណើនឥណទានបានទាញចុះអនុបាតឥណទានធៀបនឹង ផ.ស.ស ដែលបានធ្លាក់ចុះមកនៅត្រឹម ១២០,៤ ភាគរយក្នុង ខែមីនា ឆ្នាំ២០២៥ ពី ១២៤,១ ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។** ផ្ទុយទៅវិញ កំណើនប្រាក់បញ្ញើរបស់វិស័យឯកជនបានកើនឡើងដល់ ២០,២ ភាគរយក្នុងខែមីនា ឆ្នាំ២០២៥ ពី ១៤,៨ ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤ ទោះបីជាមានការធ្លាក់ចុះនៃអត្រាការប្រាក់លើប្រាក់បញ្ញើជាដុល្លារអាមេរិកមកនៅត្រឹម ៤,៦ ភាគរយ ពី ៥,៦ ភាគរយក្នុងមួយឆ្នាំ ក្នុងអំឡុងពេលដូចគ្នាក៏ដោយ។

**ការកើនឡើងនៃប្រាក់បញ្ញើរបស់វិស័យឯកជនបានជំរុញឱ្យអនុបាតនៃប្រាក់បញ្ញើធៀបនឹង ផ.ស.ស សម្រាប់ឆ្នាំបច្ចុប្បន្នកើនឡើងដល់ ១០៨,៦ ភាគរយក្នុងខែមីនា ឆ្នាំ២០២៥ ពី ៩៧,៨ ភាគរយ ក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។** ការថយចុះនៃកំណើនឥណទាន និងការកើនឡើងនៃកំណើនប្រាក់បញ្ញើ បានជួយកាត់បន្ថយអនុបាតកម្ចីធៀបនឹងប្រាក់បញ្ញើមកនៅត្រឹម ១១០,៨ ភាគរយ ពី ១២៦,៩ ភាគរយក្នុងអំឡុងពេលដូចគ្នាក្នុងឆ្នាំ២០២៤។

## ការបង្រួមសារពើពន្ធបានចាប់ផ្តើម

**អាជ្ញាធរកម្ពុជាបានចាប់ផ្តើមបង្រួមស្ថានភាពសារពើពន្ធរបស់ខ្លួន នៅក្នុងឆ្នាំថវិកា ២០២៥។** នៅក្នុងដំណាក់កាលក្រោយកូវីដ-១៩ ដោយសារសេដ្ឋកិច្ចមានសកម្មភាពកម្រិតមធ្យម ការប្រមូលចំណូលក្នុងស្រុកបានថយចុះបន្តិច។ ការថមថយនៃកំណើនចំណូល បានតម្រូវឱ្យមានអភិក្រមកាន់តែប្រុងប្រយ័ត្នថែមទៀតនៅក្នុងការគ្រប់គ្រងសារពើពន្ធ ដើម្បីធានាស្ថិរភាពសេដ្ឋកិច្ចរយៈពេលវែង។ លើសពីនេះ បន្ទាប់ពីអនុវត្តវិធានការគាំទ្រផ្នែកសារពើពន្ធបន្ថែមទៀតដើម្បីសម្រាលផលប៉ះពាល់អវិជ្ជមានពីជំងឺរាតត្បាតកូវីដ-១៩ អាជ្ញាធរចាំបាច់ត្រូវគិតគូររៀបចំលំហសារពើពន្ធឡើងវិញ សម្រាប់ឆ្លើយតបទៅនឹងស្ថានភាពអង្រួនកន្ត្រាក់សេដ្ឋកិច្ចនាពេលអនាគត។

**សម្រាប់ឆ្នាំថវិកា២០២៥ ចំណូលត្រូវបានគ្រោងទុកថានឹងសម្រេចបាន ២៩ ទ្រីលានរៀល (ស្មើនឹង ៧,១ ពាន់លានដុល្លារអាមេរិក) ឬ ១៤,១ ភាគរយនៃ ផ.ស.ស ថយចុះពី ១៦,៩ ភាគរយនៃ ផ.ស.ស. ដែលបានគ្រោងសម្រាប់ឆ្នាំ២០២៤។** ការធ្លាក់ចុះនេះឆ្លុះបញ្ចាំងពីបញ្ហាប្រឈមក្នុងការប្រមូលចំណូល (សូមមើលអត្ថបទផ្តោតពិសេសក្រោមចំណងជើងថា "ពង្រឹងចំណូលសម្រាប់អនាគតកម្ពុជា")។ ស្រដៀងគ្នានេះដែរ ចំណាយត្រូវបានគ្រោងទុកថានឹងមានដល់ទៅ ៣៥,៤ ទ្រីលានរៀល (ស្មើនឹង ៨,៧ ពាន់លានដុល្លារអាមេរិក) ឬ ១៧,២ ភាគរយ

### ប្រអប់ទី២ ៖ កម្ចីមិនដំណើរការក្នុងវិស័យធនាគាររបស់កម្ពុជា[1]

**បន្ទាប់ពីមានកំណើនឥណទានលឿនក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រព័ន្ធធនាគារកម្ពុជាកំពុងជួបប្រទះការធ្លាក់ចុះខ្លាំងនូវគុណភាពនៃទ្រព្យសកម្មរបស់ខ្លួន។** អនុបាតកម្ចីមិនដំណើរការ (NPL) ដែលបានរាយការណ៍ឱ្យដឹង គឺមានដល់ទៅ ៧,៩ ភាគរយនៅខែធ្នូ ឆ្នាំ២០២៤ ដែលជាការកើនឡើងគួរឱ្យកត់សម្គាល់ពី ១,៨ ភាគរយក្នុងឆ្នាំ២០១៩។ ការកើនឡើងនៃកម្ចីមិនដំណើរការនេះ អាចបណ្តាលមកពីកត្តាច្រើន រួមមាន៖ ការផុតកំណត់កាលនៃការអត់ធ្មត់ពុំទារបំណុលពីសម័យកូវីដ-១៩, ការធ្លាក់ចុះនៃសេដ្ឋកិច្ច, វិស័យអចលនទ្រព្យលែងរីកចម្រើន, និងស្តង់ដានៃការផ្តល់កម្ចីខ្វះគុណភាព។ កម្ចីមិនដំណើរការបានប្រមូលផ្តុំនៅក្នុងវិស័យមួយចំនួន (សណ្ឋាគារ និងភោជនីយដ្ឋាន, លក់រាយ, និងដី) ខណៈដែលវិស័យអចលនទ្រព្យនៅមានអត្រាកម្ចីមិនដំណើរការក្នុងកម្រិតទាបខ្លះនៅឡើយ បើទោះបីជាវិស័យអចលនទ្រព្យលែងលូតលាស់ខ្លាំងទៀតក៏ដោយ។

**នៅខែសីហា ឆ្នាំ២០២៤ ធនាគារជាតិនៃកម្ពុជា បានចេញប្រកាសមួយស្តីពីការរៀបចំឥណទានឡើងវិញ ដែលអនុញ្ញាតឱ្យធនាគាររៀបចំឥណទានរបស់អតិថិជនឡើងវិញបានពីរដង ដោយមិនផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន ឬតម្រូវឱ្យមានការបង្កើតទុនបម្រុងបន្ថែមឡើយ។**[2,3]

**នៅខែមករា ឆ្នាំ២០២៥ ប្រហែល ១០ភាគរយ នៃឥណទានសរុបត្រូវបានរៀបចំឡើងវិញ។** ខណៈដែលវិធានការនេះកំពុងមានប្រសិទ្ធភាព កម្ចីមិនដំណើរការដែលបានរាយការណ៍ឱ្យដឹង អាចនឹងមិនឆ្លុះបញ្ចាំងឱ្យបានពេញលេញអំពីវិសាលភាពនៃទ្រព្យសកម្មដែលកំពុងជួបបញ្ហានោះទេ ពីព្រោះមួយចំណែកនៃកម្ចីដែលបានរៀបចំឡើងវិញ នៅទីបំផុត អាចនឹងក្លាយទៅជាកម្ចីមិនដំណើរការដែរ។ ការអត់ធ្មត់ផ្នែកបទប្បញ្ញត្តិទារបំណុល បានធ្វើឱ្យធនាគារមានភាពធូរស្រាលបន្តិចជុំវិញការទទួលស្គាល់កម្ចីមិនដំណើរការ ប៉ុន្តែពេលណាការអត់ធ្មត់នេះផុតកំណត់ — ប្រកាសនេះនឹងផុតកាលកំណត់នៅខែធ្នូ ឆ្នាំ២០២៥ — គេរំពឹងថា ចំនួននៃកម្ចីមិនដំណើរការ នឹងកើនឡើងខ្ពស់ថែមទៀត។

**ឧបករណ៍ដោះស្រាយកម្ចីមិនដំណើរការមួយចំនួននៅក្នុងប្រទេសកម្ពុជា មិនសូវមានប្រសិទ្ធភាពពេញលេញទេ ដោយសារកត្តាមួយចំនួនដូចជា ក្របខ័ណ្ឌគតិយុត្តិដែលមិនទាន់រៀបចំបានគ្រប់គ្រាន់, នីតិវិធីតុលាការអូសបន្លាយពេលយូរ, និងកង្វះទីផ្សារសម្រាប់ការលក់កម្ចីមិនដំណើរការ។** ប្រទេសនេះមិនទាន់ធ្លាប់មានបទពិសោធន៍ជាមួយការកើនឡើងគួរឱ្យកត់សម្គាល់នៃកម្ចីមិនដំណើរការនោះទេ ដូច្នេះក្របខ័ណ្ឌមួយចំនួនមិនទាន់ត្រូវបានបង្កើតឡើងនៅឡើយ។ ការលក់កម្ចីមិនដំណើរការ និងចំណាត់ការផ្លូវច្បាប់ គឺជាឧទាហរណ៍នៃក្របខ័ណ្ឌដែលមិនទាន់បានអភិវឌ្ឍ/មិនសូវប្រើប្រាស់ ហេតុនេះមានតែការរៀបចំឥណទានឡើងវិញ និងការដកឥណទានចេញពីបញ្ជីសមតុល្យរបស់ធនាគារ (loan write-offs) ដែលជាឧបករណ៍ដោះស្រាយកម្ចីមិនដំណើរការពីរត្រូវបានប្រើប្រាស់ជាទូទៅបំផុតនៅក្នុងប្រទេសកម្ពុជា។

**ឧត្តមានុវត្តន៍ជាអន្តរជាតិបានបង្ហាញថា កម្ពុជាអាចទទួលបានអត្ថប្រយោជន៍ពីវិធីសាស្រ្តមួយសម្រាប់ការដោះស្រាយកម្ចីមិនដំណើរការ ដែលសង្កត់ធ្ងន់លើធនាគារជាតួអង្គសំខាន់នៅក្នុងការរ៉ាប់រងបន្ទុកហិរញ្ញវត្ថុសម្រាប់ដោះស្រាយកម្ចីមិនដំណើរការ ប៉ុន្តែទន្ទឹមគ្នានេះ វាក៏អំពាវនាវឱ្យមានការកែលម្អបរិយាកាសអំណោយផលសម្រាប់ការដោះស្រាយកម្ចីមិនដំណើរការផងដែរ។** ឧត្តមានុវត្តន៍នេះមាន (i) សម្រួលការអនុវត្តចំណាត់ការទៅលើទ្រព្យធានា, (ii) ពិនិត្យឡើងវិញនូវច្បាប់ស្តីពីក្ស័យធន, (iii) ដាក់ឱ្យប្រើប្រាស់នូវបទប្បញ្ញត្តិស្តីពីអ្នកមិនសងបំណុលដោយចេតនា និងយុទ្ធសាស្ត្រកាត់បន្ថយកម្ចីមិនដំណើរការសម្រាប់ធនាគារដែលមានកម្ចីមិនដំណើរការខ្ពស់, (iv) កែលម្អលក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការកាត់ចេញកម្ចីមិនដំណើរការពីបញ្ជីសមតុល្យ, (v) បង្កើតក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់បើកក្រុមហ៊ុនប្រមូលបំណុល និងក្រុមហ៊ុនសេវាកម្មបំណុល ដើម្បីបើកឱ្យមានទីផ្សារសម្រាប់កម្ចីមិនដំណើរការនៅកម្ពុជា, និង (vi) កែលម្អក្របខ័ណ្ឌម៉ាក្រូប្រុងប្រយ័ត្ន។

1. មាតិកាក្នុងប្រអប់នេះត្រូវបានសរសេរដោយ លោក Tim L. De Vaan ក្រោមការណែនាំរបស់ លោក Francesco Strobbe។
2. ប្រកាសលេខ ប៧-០២៤-០០១ ចេញនៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤។
3. ដោយគ្មានការកំណត់ចំពោះវិស័យជាក់លាក់ណាមួយ។

នៃ ផ.ស.ស. ថយចុះពី ១៩,៣ ភាគរយនៃ ផ.ស.ស. ដែលបានគ្រោងទុកក្នុងឆ្នាំ២០២៤។ ការកាត់បន្ថយចំណាយនេះបង្ហាញពីកិច្ចខិតខំរបស់រដ្ឋាភិបាលក្នុងការរៀបចំចំណាយឱ្យរលូន និងកែលម្អវិន័យសារពើពន្ធ។ ឱនភាពសារពើពន្ធជារួមត្រូវបានគ្រោងថានឹងនៅត្រឹម ៣,១ ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ២០២៥។ ដើម្បីដោះស្រាយបញ្ហានៃការប្រមូលចំណូលយឺតថវិកាឆ្នាំ២០២៥បានលើកពិតានកម្ចីដល់ ២ ពាន់លានសិទ្ធិដកប្រាក់ពិសេស (SDR) ពីកម្រិត ១,៧ ពាន់លាន SDR ដែលបានអនុញ្ញាតក្រោមច្បាប់ថវិកាឆ្នាំ២០២៤។

**ការប្រមូលចំណូលក្នុងស្រុកក្នុងឆ្នាំ២០២៥ នៅតែមានភាពរឹងមាំគួរសម ទោះបីជាអត្រាកំណើនរបស់វានៅ ទាបជាងកម្រិតនៅមុនពេលមានជំងឺរាតត្បាតក៏ដោយ។** នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ចំណូលក្នុងស្រុករបស់រដ្ឋបាលកណ្តាលបានកើនឡើង ១១,២ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដោយ

**រូបទី១១ ៖ ចំណូលរដ្ឋបាលកណ្ដាល**

*(ភាគរយនៃការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ)*




*ប្រភព៖ អាជ្ញាធរកម្ពុជា*

*សម្គាល់៖ m = ខែ*

**រូបទី១២ ៖ ប្រតិបត្តិការចំណាយរដ្ឋបាលទូទៅ**

*(ភាគរយនៃផ.ស.ស)*




*ប្រភព៖ ច្បាប់ទូទាត់ថវិកា;* ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*សម្គាល់៖ e* = ការប៉ាន់ស្មាន; p = ការព្យាករ

សារចំណូលពន្ធ និងចំណូលមិនមែនពន្ធជាសំខាន់ (រូបទី១០)។ ក្នុងចំណោមកំណើន ១១,២ ភាគរយនៃចំណូលក្នុងស្រុកសរុបនេះ, ចំណូលពន្ធ, ចំណូលមិនមែនពន្ធ, និងចំណូល ផ្សេងទៀត បានរួមចំណែក ៥,៣, ៣,២, និង ២,៧ ភាគរយរៀងៗខ្លួន។

**ការបង្កើនចំណូលផ្ទាល់ - ដែលរួមមានពន្ធលើប្រាក់ចំណេញ និងពន្ធលើប្រាក់ចំណូល ហើយដែលស្មើប្រហែលមួយភាគបីនៃចំណូលពន្ធសរុប -- នៅតែជាបញ្ហាប្រឈមមួយ ដោយសារកម្ពុជាមានចិត្តល្អបន្តិចក្នុងការផ្ដល់ប្រការលើកទឹកចិត្តពន្ធ ហើយមិនទាន់យកពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) នៅឡើយ។** នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ចំណូលផ្ទាល់បានធ្លាក់ចុះ ២,១ ភាគរយ។ ផ្ទុយទៅវិញ ចំណូលមិនផ្ទាល់បានកើនឡើង ១៦,៦ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលភាគច្រើនត្រូវបានជំរុញដោយអាករលើតម្លៃបន្ថែម និងអាករពិសេស ជាពិសេសពីការនាំចូលស្របគ្នានឹងការងើបឡើងវិញខ្លះនៃការប្រើប្រាស់ឯកជន ដែលជំរុញឱ្យមានការនាំចូលទំនិញ។ ស្ថានភាពប្រសើរឡើងក្នុងវិស័យធ្វើដំណើរ និងសកម្មភាពទេសចរណ៍ បានធ្វើឱ្យចំណូលមិនមែនពន្ធកើនឡើង ៤១,១ ភាគរយ ក្នុងត្រីមាស ទីមួយនៃឆ្នាំ២០២៥ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។

**ចំនួនប្រាក់ចំណាយរបស់រដ្ឋបាលកណ្ដាលបានថយបន្តិចមួយផ្នែកធំដោយសារការក្បិតក្បៀតចំណាយលើទំនិញ និងសេវាកម្ម។** នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ចំណាយថវិការបស់រដ្ឋបាលកណ្ដាលបានថយចុះខ្លាំង ដោយធ្លាក់ចុះ ៣៥,២ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដោយសារការក្បិតក្បៀតចំណាយមិនចាំបាច់។ ចំណាយលើទំនិញ និងសេវាកម្មធ្លាក់ចុះខ្លាំង រហូតដល់ទៅ ៦០,៤ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ផ្ទុយទៅវិញ បញ្ជីរក្ខយបត្រប្រាក់បៀវត្សកើនឡើងប្រហែល ៣,៣ ភាគរយ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ ចំណាយមូលធនកើនឡើង ៨,៩ ភាគរយផងដែរ ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន។

**នៅក្នុងត្រីមាសទីមួយនៃឆ្នាំ២០២៥ ការកើនឡើងនៃចំណូលក្នុងស្រុក និងការថយចុះនៃការចំណាយរបស់រដ្ឋាភិបាល បាននាំឱ្យមានអតិរេកសារពើពន្ធចំនួន ២,៨ ទ្រីលានរៀល ប្រសើរជាងកាលនៅក្នុងត្រីមាសទីមួយ ឆ្នាំ២០២៤ ដែលមានឱនភាពសារពើពន្ធចំនួន ០,៩ ទ្រីលានរៀល។** ក្រោមកិច្ចខិតខំរបស់អាជ្ញាធរក្នុងការរឹតបន្តឹងថវិកាឆ្នាំនេះ ឱនភាពសារពើពន្ធទូទៅត្រូវបានរំពឹងថានឹងរួមតូច។ ចំណូលទូទៅរបស់រដ្ឋាភិបាល (និងជំនួយ) ត្រូវបានរំពឹងថានឹងសម្រេចបាន ១៥,៤ ភាគរយនៃផ.ស.ស. ខណៈដែលការចំណាយទូទៅរបស់រដ្ឋាភិបាលត្រូវបានព្យាករថានឹងមានប្រហែល ១៨,១ ភាគរយនៃ ផ.ស.ស. (រូបទី១១)។ ដូច្នេះឱនភាពសារពើពន្ធជារួមរបស់កម្ពុជាត្រូវបានរំពឹងថានឹងរួមតូចមកត្រឹម ២,៧ ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ២០២៥ ធ្លាក់ចុះពី ៣,០ ភាគរយនៃ ផ.ស.ស. ក្នុងឆ្នាំ២០២៤។

**ដើម្បីបំពេញដល់ឱនភាពជារួមនៃសារពើពន្ធដែលបានព្យាករមកនេះ ហិរញ្ញប្បទានពីខាងក្រៅត្រូវបានរំពឹងថានឹងអាចរ៉ាប់រងបាន ១,៥ ភាគរយនៃ ផ.ស.ស. (ត្រូវនឹង ៥៥ ភាគរយនៃឱនភាព)។** ចំណែក ១,២ ភាគរយទៀតនៃ ផ.ស.ស. (៤៥ ភាគរយនៃឱនភាព) ត្រូវបានរំពឹងថាទទួលបានការទ្រទ្រង់ហិរញ្ញប្បទានតាមរយៈការដកប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុង) ដែលមានចំនួន ១១,៩ ភាគរយនៃ ផ.ស.ស. (២៤,៨ ទ្រីលានរៀល) គិតត្រឹមខែមីនា ឆ្នាំ២០២៥ ធៀបទៅនឹង ១១,២ ភាគរយនៃ ផ.ស.ស. ក្នុងរយៈពេលដូចគ្នានៅឆ្នាំ២០២៤។ ខណៈដែលអាជ្ញាធរបានលក់បណ្ណបំណុលក្នុងស្រុក ចំណូលពីបំណុលនេះត្រូវបានបង្វែរទៅវិនិយោគលើគម្រោងសាធារណៈដែលផ្ដល់អត្ថប្រយោជន៍ច្រើនមកវិញ ជាជាងការយកទៅបំពេញឱ្យឱនភាពសារពើពន្ធទូទៅ (សម្រាប់ព័ត៌មានលម្អិតសូមមើលផ្នែកស្ដីពីបំណុលសាធារណៈនៅខាងក្រោម)។

## ស្តុកបំណុលសាធារណៈកើនដល់ ២៥,៩ ភាគរយនៃ ផ.ស.ស. ត្រឹមចុងឆ្នាំ២០២៤

**គិតត្រឹមដំណាច់ឆ្នាំ២០២៤ អនុបាតបំណុលសាធារណៈរបស់កម្ពុជាធៀបទៅនឹង ផ.ស.ស. បានកើនដល់ ២៥,៩ ភាគរយ ដែលស្មើនឹង ១២,០៣ ពាន់លានដុល្លារអាមេរិក នៃបំណុលដែលមិនទាន់ត្រូវបានទូទាត់សង។**[6] ក្នុងចំណោមចំនួនសរុបនេះ ៦២ ភាគរយ ជាបំណុលជំពាក់ឥណទាយកទ្វេភាគី ហើយ ៣៨ ភាគរយ ជាបំណុលជំពាក់ឥណទាយកពហុភាគី។ បំណុលសាធារណៈក្រៅប្រទេសមាន ៩៩ ភាគរយ នៃចំនួនសរុបត្រូវនឹង១១,៩២ ពាន់លានដុល្លារអាមេរិក រីឯ ១ ភាគរយទៀត ដែលស្មើនឹង ១១៥ លានដុល្លារអាមេរិក ជាបំណុលសាធារណៈក្នុងស្រុក។

**សម្រាប់ការប្រឈមវិបត្តិបំណុលខាងក្រៅ និងវិបត្តិបំណុលរួម កម្ពុជាមានហានិភ័យកម្រិតទាបនៅឡើយទេ ក្រោមក្របខ័ណ្ឌចីរភាពបំណុលសម្រាប់ប្រទេសមានចំណូលទាប។**[7] បើគិតតាមសេណារីយោបន្ទាត់គោល សេដ្ឋកិច្ចនឹងបន្តងើបឡើងមួយផ្នែកធំ ដោយសារការស្ទុះងើបឡើងវិញនៃការនាំចេញទំនិញរោងចក្រ ផលិតផលកសិកម្ម និងវិស័យទេសចរណ៍។ អនុបាតបំណុលសាធារណៈសរុប និងអនុបាតបំណុលសាធារណៈមានការធានាធៀបទៅនឹង ផ.ស.ស. ត្រូវបានរំពឹងថានឹងឡើងប្រហែល ៤ ចំណុចភាគរយនៃ ផ.ស.ស. ក្នុងអំឡុងទសវត្សខាងមុខ ប៉ុន្តែតាមការរំពឹងទុក កម្រិតរបស់វានឹងមិនប្រែប្រួលទេ។ សូចនាករបន្ទុកបំណុល ត្រូវបានព្យាករថានឹងនៅទាបជាងបន្ទាត់ក្រិតអតិបរមាសម្រាប់សេណារីយោបន្ទាត់គោលពេលមានវិបត្តិ។ ការធ្វើតេស្តស្រ្តេសអំពីបំណុល បង្ហាញឱ្យឃើញថា ចីរភាពបំណុលមានភាពងាយរងគ្រោះខ្លាំង ក្នុងករណីដែលមានវិបត្តិបំណុលណាមួយកើតឡើងជាយថាហេតុ។

### ទស្សនវិស័យ

**ដោយសារបញ្ហាប្រឈមជាសកល និងក្នុងស្រុក កំណើនពិតប្រាកដនៃសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានព្យាករថានឹងថយចុះមកត្រឹម ៤ ភាគរយ ក្នុងឆ្នាំ២០២៥ និង ៤,៥ ភាគរយក្នុងឆ្នាំ២០២៦ (សូមមើលតារាងទី២)។** ស្របពេលដែលតម្រូវការក្រៅស្រុកស្រុតចុះ និងភាពមិនប្រាកដប្រជាឡើងខ្ពស់ ជាពិសេសជុំវិញគោលការណ៍ពាណិជ្ជកម្ម, ការនាំចេញ និងការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យនាំចេញផលិតកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មច្រើន -- ជាពិសេសនៅក្នុងឧស្សាហកម្មកាត់ដេរ ទំនិញធ្វើដំណើរ និងស្បែកជើង (GTF) -- ត្រូវបានរំពឹងថានឹងធ្លាក់ចុះ។

**ផ្ទុយទៅវិញ ឧស្សាហកម្មធ្វើដំណើរ ទេសចរណ៍ និងបដិសណ្ឋារកិច្ច ត្រូវបានរំពឹងថានឹងបន្តមានភាពប្រសើរឡើងមួយផ្នែក ដោយសារអំណោយផលពីការកែលម្អជាបន្តបន្ទាប់ក្នុងការតភ្ជាប់រវាងអន្តរជាតិ និងក្នុងស្រុក។** ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ផលិតកម្មកសិកម្ម និងឧស្សាហកម្មកែច្នៃកសិផលត្រូវបានរំពឹងថានឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី ជាពិសេស ប្រសិនបើមានការដោះស្រាយបញ្ហាប្រឈមរចនាសម្ព័ន្ធមួយចំនួននៅក្នុងវិស័យនេះ។

**សេដ្ឋកិច្ចកម្ពុជា ដែលមានប្រាក់ដុល្លារជាមូលដ្ឋានទូទាត់ ត្រូវរត់តាមគន្លងគោលនយោបាយរូបិយវត្ថុរបស់សហរដ្ឋអាមេរិក** ដែលនាំឱ្យអតិផរណាដែលបានព្យាករទុក កើនឡើង ដោយសារការផ្លាស់ប្តូរគោលការណ៍ពាណិជ្ជកម្មពិភពលោក ដែលប៉ះពាល់ដល់អត្រាប្តូរប្រាក់ និងតម្លៃនៃការនាំចូលទំនិញជាប្រាក់ដុល្លារ។ ការនាំចេញទំនិញត្រូវបានរំពឹងថានឹងថយចុះ ក្នុងទំហំមួយធំជាងការធ្លាក់ចុះនៃទំហំរបស់ការនាំចូលទំនិញទៅទៀត។ អតុល្យភាពនេះទំនងជានឹងធ្វើឱ្យឱនភាពគណនីចរន្តរីកកាន់តែធំក្នុងរយៈពេលខ្លី។ កិច្ចខិតខំការរឹតបន្តឹងសារពើពន្ធដែលកំពុងដំណើរការ ដែលរួមមានវិធានការកែលម្អការប្រមូលពន្ធ និងការក្បិតក្បៀតចំណាយមិនចាំបាច់ ត្រូវបានព្យាករថានឹងអាចធ្វើឱ្យឱនភាពសារពើពន្ធសរុប រួមតូចបន្តិចវិញ។

**ខណៈដែលកំណើនសេដ្ឋកិច្ចត្រូវបានរំពឹងថានឹងជួយកាត់បន្ថយភាពក្រីក្រ, អត្រាល្បឿនកាត់បន្ថយភាពក្រីក្រនឹងថយចុះទន្ទឹមគ្នានឹងកំណើនដែលមានល្បឿនយឺតជាងមុន ហើយអត្រានេះនឹងបន្តមានភាពខុសគ្នានៅតាមតំបន់ និងវិស័យផ្សេងៗ។**

### បញ្ហាប្រឈម និងហានិភ័យ

**នៅក្រៅប្រទេស កំណើនសេដ្ឋកិច្ចពិភពលោកយឺតជាងការរំពឹងទុក អាចធ្វើឱ្យការនាំចេញ និងលំហូរវិនិយោគផ្ទាល់ពីបរទេសធ្លាក់ចុះខ្លាំង។** អ្វីដែលអាចបង្កហានិភ័យបន្ថែមទៀត គឺលទ្ធភាពនៃការរឹតត្បិតកាន់តែខ្លាំងដល់ការនាំទំនិញទៅកាន់ទីផ្សារសំខាន់ៗ ដូចជាសហរដ្ឋអាមេរិក ជាដើម។

**នៅក្នុងស្រុក បំណុលឯកជនដែលមានកម្រិតខ្ពស់ អមដោយទំហំប្រាក់កម្ចីមិនដំណើរការដែលកើនឡើងលឿនជាងការរំពឹងទុក និងការលេចឡើងនូវហានិភ័យបណ្តាលមកពីអតិផរណានាំចូល - ក្នុងករណីដែលអតិផរណាកើនឡើងតាមការរំពឹងទុកនៅក្នុងសហរដ្ឋអាមេរិក - ទាំងអស់នេះអាចប៉ះពាល់ដល់ស្ថិរភាពម៉ាក្រូហិរញ្ញវត្ថុ និងជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។**

6 ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ 2025a.
7 មូលនិធិរូបិយវត្ថុអន្តរជាតិ 2025b

**តារាងទី២ ៖ ទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ចបង្ហាញពីសកម្មភាពសេដ្ឋកិច្ចកម្រិតមធ្យម**

| | 2020 | 2021 | 2022 | 2023 | 2024e | 2025p | 2026p | 2027p |
|---|---|---|---|---|---|---|---|---|
| **គណនេយ្យជាតិ និងតម្លៃ** | | | | | | | | |
| ផ.ស.ស. សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក, ថ្លៃបច្ចុប្បន្ន) | 2,090 | 2,167 | 2,298 | 2,455 | 2,657 | 2,881 | 3,095 | 3,349 |
| ផ.ស.ស. តាមថ្លៃទីផ្សារថេរ (% ការប្រែប្រួល) | -3.6 | 3.1 | 5.1 | 5.0 | 6.0 | 4.0 | 4.5 | 5.1 |
| កសិកម្ម | 0.6 | 1.5 | 0.6 | 1.6 | 1.0 | 1.4 | 1.5 | 1.6 |
| ឧស្សាហកម្ម | -2.2 | 8.4 | 8.2 | 7.6 | 9.5 | 6.3 | 6.4 | 6.5 |
| សេវាកម្ម | -6.7 | -1.8 | 3.6 | 3.4 | 4.0 | 2.8 | 4.0 | 4.4 |
| សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (ជាមធ្យមប្រចាំឆ្នាំ) | 2.9 | 2.8 | 5.5 | 2.1 | 2.2 | 4.0 | 4.0 | 4.1 |
| **ការគ្រប់គ្រងរដ្ឋបាលទូទៅ** (% នៃ ផ.ស.ស.) | | | | | | | | |
| ចំណូល និងជំនួយឥតសំណង | 17.9 | 16.2 | 17.2 | 16.5 | 15.2 | 15.2 | 15.0 | 14.9 |
| ចំណូលពន្ធ | | 12.3 | 13.8 | 12.5 | 12.3 | 12.3 | 12.1 | 11.9 |
| ពន្ធលើទំនិញ និងសេវាកម្ម | 8.0 | 6.9 | 7.7 | 6.6 | 6.4 | 6.6 | 6.5 | 6.5 |
| ពន្ធផ្ទាល់ | 4.1 | 3.9 | 4.5 | 4.5 | 4.4 | 4.3 | 4.1 | 4.0 |
| ពន្ធលើពាណិជ្ជកម្មអន្តរជាតិ | 1.6 | 1.4 | 1.6 | 1.5 | 1.5 | 1.4 | 1.4 | 1.4 |
| ជំនួយឥតសំណង | 1.4 | 1.1 | 0.5 | 0.8 | 0.4 | 0.3 | 0.1 | 0.1 |
| ចំណាយ និងការផ្តល់កម្ចីសុទ្ធ | 21.3 | 21.3 | 20.4 | 21.8 | 18.2 | 17.9 | 17.5 | 16.9 |
| សមតុល្យរួម (មិនរួមបញ្ចូលជំនួយ) | -4.8 | -6.3 | -3.8 | -6.1 | -3.4 | -3.1 | -2.7 | -2.1 |
| សមតុល្យរួម (រួមបញ្ចូលជំនួយ) | -3.4 | -5.1 | -3.2 | -5.3 | -3.0 | -2.7 | -2.5 | -2.0 |
| ហិរញ្ញប្បទានបរទេស | 3.5 | 3.1 | 3.9 | 3.6 | 1.6 | 2.5 | 2.7 | 2.5 |
| ហិរញ្ញប្បទានក្នុងស្រុកសុទ្ធ (ពីការសន្សំបច្ចុប្បន្ន) | 0.7 | 2.8 | 0.2 | 2.6 | 2.3 | 1.1 | 0.8 | 0.4 |
| ការរំលស់បំណុល | -0.8 | -0.8 | -0.9 | -0.9 | -0.9 | -0.9 | -0.9 | -0.9 |
| **រូបិយវត្ថុ និងឥណទាន** | | | | | | | | |
| រូបិយវត្ថុទូទៅ (% ការប្រែប្រួល) | 18.2 | 15.3 | 16.4 | 8.2 | 12.5 | 17.9 | 18.5 | 18.5 |
| ឥណទានដល់វិស័យឯកជន (% ការប្រែប្រួល) | 17.7 | 23.2 | 18.9 | 4.1 | 4.3 | 6.5 | 8.0 | 10.5 |
| **វិស័យខាងក្រៅ** (ជាលានដុល្លារអាមេរិក លើកលែងតែមានការបញ្ជាក់ផ្សេង) | | | | | | | | |
| ការនាំចេញ (ទំនិញ និងសេវាកម្ម) | 16,692 | 18,566 | 24,495 | 28,570 | 31,885 | 36,923 | 41,863 | 47,356 |
| ការនាំចូល (ទំនិញ និងសេវាកម្ម) | 19,955 | 29,489 | 40,467 | 32,468 | 34,506 | 40,638 | 45,163 | 50,415 |
| ការវិនិយោគផ្ទាល់ពីបរទេស, ចរន្តចូលសុទ្ធ | 3,498 | 3,391 | 3,425 | 3,639 | 4,080 | 3,847 | 4,198 | 4,620 |
| ទុនបម្រុងផ្លូវការដុល | 16,237 | 17,675 | 17,764.8 | 19,895.6 | 22,523.0 | 23,693.2 | 25,541.7 | 26,850.3 |
| (ខែនៃការនាំចូល) | 10.4 | 8.1 | 7.0 | 7.1 | 7.1 | 6.4 | 6.2 | 6.0 |
| គណនីចរន្ត (ភាគរយនៃ ផ.ស.ស.) | -5.5 | -29.1 | -18.8 | 1.3 | -1.1 | -5.2 | -4.6 | -4.6 |
| អត្រាប្តូរប្រាក់ (រៀល ក្នុងមួយដុល្លារអាមេរិក ជាមធ្យម) | 4,077 | 4,100 | 4,150 | 4,110 | 4,067 | 4,010 | 4,010 | 4,010 |
| បំណុលសាធារណៈសរុប (% នៃ ផ.ស.ស.) | 25.2 | 25.6 | 24.9 | 26.5 | 25.9 | 26.3 | 26.2 | 26.0 |
| *ជំនួយស្មារតីស្តីពី ផ.ស.ស* | | | | | | | | |
| ផ.ស.ស ថ្លៃបច្ចុប្បន្ន, លានដុល្លារអាមេរិក | 34,949 | 36,779 | 39,532 | 42,779 | 46,872 | 51,423 | 55,861 | 61,119 |

*ប្រភព៖ អាជ្ញាធរកម្ពុជា;* ការប៉ាន់ស្មាន និងការព្យាកររបស់បុគ្គលិកធនាគារពិភពលោក

*កំណត់សម្គាល់៖ e* = ការប៉ាន់ស្មាន; p = ការព្យាករ

## ជម្រើសគោលនយោបាយ

**វិធានការគោលនយោបាយគួរតែផ្ដល់អាទិភាពដល់ការរក្សាស្ថិរភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច និងផ្នែកហិរញ្ញវត្ថុ, ជំរុញកំណែទម្រង់ពាណិជ្ជកម្ម និងការវិនិយោគ និងការពង្រឹងសំណាញ់សុវត្ថិភាពសង្គមដើម្បីការពារគ្រួសារដែលងាយរងគ្រោះ។** វិធានការទាំងនេះគួរតែរួមបញ្ចូលការធ្វើឱ្យស៊ីជម្រៅនូវកំណែទម្រង់បទប្បញ្ញត្តិ និងការលើកកម្ពស់អាជីវកម្មខ្នាតតូច ដែលជាកន្លែងបង្កើតការងារភាគច្រើន និងកាត់បន្ថយចំណាយថ្លៃដើមក្នុងការធ្វើពាណិជ្ជកម្ម តាមរយៈការសម្របសម្រួលពាណិជ្ជកម្ម និងការធ្វើឱ្យប្រសើរឡើងនូវការតភ្ជាប់ និងការដឹកជញ្ជូន។

**កម្ពុជាក៏អាចប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងតំបន់ (FTA) រួមទាំងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) និងកិច្ចព្រមព្រៀងអាស៊ានបូក[8]** ដើម្បីជួយសម្រួលដល់ការចូលទីផ្សារ និងធ្វើពិពិធកម្មភាពជាដៃគូពាណិជ្ជកម្មរបស់ខ្លួន រួមទាំងក្នុងតំបន់អាស៊ានផងដែរ។

**ដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ចាំបាច់ត្រូវអនុវត្តយុទ្ធសាស្ត្រដើម្បីដោះស្រាយទ្រព្យសកម្មដែលកំពុងជួបបញ្ហា** សូមមើលប្រអប់ទី ២ សម្រាប់អនុសាសន៍គោលនយោបាយ។ ការពង្រឹងក្របខ័ណ្ឌក្ស័យធនគឺមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងទ្រព្យសកម្មឱ្យមានប្រសិទ្ធភាព ធានាបាននូវដំណោះស្រាយប្រកបដោយតម្លាភាព និងយុត្តិធម៌សម្រាប់កម្ចីមិនដំណើរការ។ ក្របខ័ណ្ឌដំណោះស្រាយដែលត្រូវបានរៀបចំយ៉ាងល្អដោយធនាគារគួរតែត្រូវបានដាក់ចេញ ដើម្បីធ្វើជាឧបករណ៍សម្រាប់គ្រប់គ្រងឱ្យមានរបៀបរៀបរយនូវធនាគារដែលរកស៊ីខាតកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចឱ្យនៅតិចបំផុត។ ត្រង់នេះរាប់បញ្ចូលទាំងយន្តការ និងឧបករណ៍អន្តរាគមន៍ដំបូងដូចជាការលក់ទ្រព្យសកម្ម និងធនាគារបណ្ដោះអាសន្នជាដើម សម្រាប់ចាត់ចែងទ្រព្យសកម្ម និងបំណុលរបស់ធនាគារដែលបរាជ័យ។ ធាតុផ្សំមួយទៀតនៃសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុរបស់ប្រទេសដែលគួរមាន គឺការធានារ៉ាប់រងលើប្រាក់បញ្ញើ ដើម្បីជួយការពារអ្នកដាក់ប្រាក់បញ្ញើ និងរក្សាស្ថិរភាព។

**ក្នុងរយៈពេលមធ្យម កម្ពុជាត្រូវបង្វែរមុខព្រួញនៃបែបផែនកំណើនរបស់ខ្លួន ចេញពីការពឹងផ្អែកលើវិស័យសំណង់អចលនទ្រព្យ និងការនាំចេញសម្លៀកបំពាក់។** ការផ្លាស់ប្ដូរនេះពាក់ព័ន្ធ នឹងការលើកកម្ពស់តម្លៃបន្ថែមក្នុងផ្នែកកម្មន្តសាល និងសេវាកម្ម រួមជាមួយនឹងការលើកកម្ពស់ផលិតភាពក្នុងវិស័យកសិកម្ម។ ដើម្បីរក្សាបាននូវកំណើនមានចីរភាពយូរអង្វែងសំខាន់ណាស់ដែលត្រូវពង្រឹងមូលធនមនុស្ស កែលម្អហេដ្ឋា-រចនាសម្ព័ន្ធ និងលើកកម្ពស់តម្លាភាព និងប្រសិទ្ធភាពនៃបទប្បញ្ញត្តិ។ ទន្ទឹមនឹងនោះ ការបង្កើនការកៀរគរចំណូលក្នុងស្រុក នឹងជួយទ្រទ្រង់ដល់ស្ថិរភាពម៉ាក្រូសារពើពន្ធដែលកំពុងដំណើរការ។

**ដូចត្រូវបានលើកឡើងនៅក្នុងអត្ថបទផ្ដោតពិសេស ការបង្កើនធនធានថែមទៀត គឺជាការចាំបាច់សម្រាប់រដ្ឋាភិបាលក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ និងមហិច្ឆតានៃការចំណាយ ដូចមានចែងនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ។** ការពង្រឹងការកៀរគរប្រាក់ចំណូលមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដ៏ទូលំទូលាយរបស់កម្ពុជា និងមានសារៈសំខាន់ជាពិសេសក្នុងការដោះស្រាយតម្រូវការវិនិយោគក្នុងវិស័យសង្គម ជាពិសេសការថែទាំសុខភាព និងការអប់រំ ដែលការចំណាយនៅតែមានកម្រិតទាបធៀបនឹងប្រទេសមានចំណូលមធ្យមទាបដទៃទៀត។ ប្រាក់ចំណូលកាន់តែខ្ពស់នឹងអាចឱ្យរដ្ឋាភិបាលកែលម្អគុណភាពនៃសេវាសាធារណៈ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងកសាងភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបានថែមទៀត។

---

8 កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរបស់កម្ពុជារួមមាន៖ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន (CCFTA), កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េខាងត្បូង (CKFTA), កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយកម្ពុជា-អារ៉ាប់រួម។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូករួមមាន៖តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (ACFTA), ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយអាស៊ាន-ជប៉ុន (AJCEP), តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េខាងត្បូង (AKTFA), តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZTFA), តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ឥណ្ឌា (AIFTA), និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង ចិន (AHKFTA)។ សូមមើល https://investasean.asean.org/asean-plus-agreements ។

# ផ្នែកទី២

## ការពង្រីកចំណូលសម្រាប់អនាគតរបស់កម្ពុជា[9]



9 អត្ថបទផ្តោតពិសេសនេះ ត្រូវបានតាក់តែងឡើងដោយ Ildrim Valley ក្រោមការណែនាំរបស់ Oleksii Balabushko ដោយមានការចូលរួមចំណែកពី Evan Harold Blecher, Hana Ross, Wollela Yesegat និងលោក តុង គឹមស៊ុន។

# ១. សេចក្តីផ្តើម

**ការប្រមូលចំណូល គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងការពង្រីកការវិនិយោគសាធារណៈ ការចំណាយលើសេវាកម្ម និងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។** លទ្ធផលនៃចំណូលនេះ គឺសម្រេចបានតាមរយៈកំណែទម្រង់រដ្ឋបាលដ៏ស្វាហាប់ ដែលអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានអនុវត្តកន្លងមក។ កំណែទម្រង់ទាំងនេះរួមមាន ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ការពង្រឹងកិច្ចខិតខំប្រឆាំងការរត់ពន្ធ ការផ្លាស់ប្តូរទៅកាន់របបពិតសម្រាប់ការយកពន្ធលើប្រាក់ចំណេញ វិធានការជាច្រើនដែលសំដៅកែលម្អអនុលោមភាពពន្ធដោយស្ម័គ្រចិត្ត (ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិក និងអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអេឡិចត្រូនិក) សេវាអ្នកជាប់ពន្ធកាន់តែប្រសើរ (សេវាពន្ធដារតាមប្រព័ន្ធអេឡិចត្រូនិក) ការពង្រឹងការគ្រប់គ្រងអ្នកបង់ពន្ធ និងមុខងារសវនកម្ម និងការជ្រើសរើសមន្ត្រីប្រកបដោយការប្រកួតប្រជែង។ អត្ថប្រយោជន៍ដែលទទួលបានពីកំណែទម្រង់ទាំងនេះ បានអនុញ្ញាតឱ្យកម្ពុជាពង្រឹងការត្រៀមលក្ខណៈផ្នែកសារពើពន្ធ ដែលជាចំណុចស្នូលក្នុងការធ្វើហិរញ្ញប្បទានដល់វិធានការឆ្លើយតបនឹងជំងឺកូវីដ-១៩ ក្នុងពេលកន្លងមក។

**សមិទ្ធកម្មផ្នែកពន្ធរបស់កម្ពុជាបានចុះខ្សោយបន្តិច បន្ទាប់ពីមានការរីកចម្រើនគួរឱ្យកត់សម្គាល់អស់រយៈពេលពីរទសវត្សក្នុងការបង្កើនចំណូលពន្ធ (តារាង S.1)។** ចំណូលពន្ធដែលភាគច្រើនជាចំណូលក្នុងស្រុក បានកើនឡើងពីក្រោម ៨ ភាគរយទៅជាង ១៦ ភាគរយនៃ ផ.ស.ស នៅចន្លោះឆ្នាំ២០០៥ និងឆ្នាំ២០១៩។ ជំងឺរាតត្បាតកូវីដ-១៩ បានបណ្តាលឱ្យចំណូលធ្លាក់ចុះយ៉ាងគំហុក ហើយចាប់តាំងពីពេលនោះមក ចំណូលមានការងើបឡើងវិញបន្តិចបន្តួចប៉ុណ្ណោះ។ នៅឆ្នាំ២០២៤ ចំណូលពន្ធនៅតែមានកម្រិតទាបជាងកាលនៅមុនពេលមានជំងឺរាតត្បាត បើគិតតាមចំណែកនៃ ផ.ស.ស. ហើយឥឡូវនេះគឺទាបជាងប្រទេសដែលមានចំណូលប្រហាក់ប្រហែល និងប្រទេសក្នុងតំបន់អាស៊ាន ទៅទៀត។

**កម្ពុជាចាំបាច់ត្រូវកែលម្អប្រព័ន្ធពន្ធដាររបស់ខ្លួនក្នុងទសវត្សខាងមុខ ដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់ខ្លួនក្នុងការក្លាយជាប្រទេសដែលមានចំណូលខ្ពស់។** ភាពចាំបាច់នេះមិនត្រឹមតែផ្តោតលើការបង្កើតចំណូលប៉ុណ្ណោះទេ ប៉ុន្តែវាក៏ឆ្លុះបញ្ចាំងពីតម្រូវការទូលំទូលាយបន្ថែមទៀត ក្នុងការទ្រទ្រង់ការអភិវឌ្ឍតាមរយៈប្រព័ន្ធសារពើពន្ធដែលមានប្រសិទ្ធភាពជាងមុន ផ្តោតលើកំណើន និងមានសមធម៌។ មានទិដ្ឋភាពទាក់ទងគ្នាបីយ៉ាងដែគូសបញ្ជាក់ពីសារៈសំខាន់នៃកំណែទម្រង់ចំណូលគ្រប់ជ្រុងជ្រោយ៖ ការប្រមូលធនធានឱ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយតបនឹងតម្រូវការចំណាយសាធារណៈដែលកំពុងកើនឡើង, ការពង្រឹងបរិយាកាសធុរកិច្ចតាមរយៈប្រព័ន្ធពន្ធដារដែលមានប្រសិទ្ធភាព និងអាចព្យាករបានជាងមុន, និងការលើកកម្ពស់សមធម៌ដោយធានាឱ្យមានការបែងចែកបន្ទុកពន្ធកាន់តែត្រឹមត្រូវយុត្តិធម៌ជាងមុន និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីកត្តាខាងក្រៅ។ គោលបំណងនៃផ្នែកនេះគឺដើម្បីជួយរៀបចំបង្កើត និងធ្វើអាទិភាពអនុសាសន៍គោលនយោបាយជាក់ស្តែងដែលផ្តល់ព័ត៌មានជាប្រយោជន៍សម្រាប់រាជរដ្ឋាភិបាល និងតួអង្គនានានៅក្នុងវិស័យឯកជន។ ផ្អែកលើភាពជោគជ័យដែលសម្រេចបានកន្លងមក កម្ពុជាមានឱកាស និងសមត្ថភាពក្នុងការកសាងប្រព័ន្ធពន្ធដារទំនើបមួយ ដែលទ្រទ្រង់ដល់កំណើន ប្រកបដោយចីរភាព ទាក់ទាញការវិនិយោគ និងគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិ។

**រូប S.1 ៖ សមិទ្ធផលពន្ធដារធ្លាក់ចុះក្រោយពីមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់**

*% នៃ ផ.ស.ស.*




*ប្រភព៖ IMF* GFS, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់កម្ពុជា; ការប៉ាន់ប្រមាណដោយបុគ្គលិកធនាគារពិភពលោក។

*សម្គាល់៖ អាស៊ាន*, មិនរាប់បញ្ចូលកម្ពុជា។ OECD = អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍; LMIC = ប្រទេសមានចំណូលទាបកម្រិតមធ្យម; EAP = តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក

**រូប S.2 ៖ ការងើបឡើងវិញមិនស្មើគ្នានូវចំណូលពន្ធនាមករណ៍ បានជួយលាក់បាំងភាពទន់ខ្សោយនៃរចនាសម្ព័ន្ធចំណូល**

*ផ្ទាំង A. ការប្រមូលពន្ធ, % នៃ ផ.ស.ស*




*ផ្ទាំង B. ចំណូលពន្ធធៀបនឹងកម្រិតឆ្នាំ២០១៩ (២០១៩ = ១០០), ប្រាក់រៀល (នាមករណ៍)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ, UNU-WIDER Government Revenue Dataset - Version 2023; ការប៉ាន់ប្រមាណដោយបុគ្គលិកធនាគារពិភពលោក។

# ២. បរិការណ៍ចំណូល

## *ទិដ្ឋភាពទូទៅ*

**ខណៈដែលការប្រមូលពន្ធជាប្រាក់រៀលបែបនាមករណ៍បានងើបឡើងវិញជាទូទៅចាប់តាំងពីមានជំងឺរាតត្បាតមក ចំណូលពន្ធសរុបគិតជាចំណែកនៃ ផ.ស.ស. នៅតែស្ថិតនៅក្រោមកម្រិតមុនពេលមានកូវីដ (តារាង S.2) នៅឡើយ។** ពន្ធលើចំណូលក្រុមហ៊ុន (CIT) បានកើនឡើង គិតជាចំណែកនៃ ផ.ស.ស. ចាប់តាំងពីឆ្នាំ២០១៩ ប៉ុន្តែវាបានធ្លាក់ចុះនៅឆ្នាំ២០២៣ និង២០២៤ ដែលមួយផ្នែកបណ្ដាលមកពីការធ្លាក់ចុះនៃពន្ធលើប្រាក់ចំណេញរបស់ក្រុមហ៊ុនធំៗ។[10] អាករលើតម្លៃបន្ថែម (VAT) បានបង្ហាញពីការងើបឡើងវិញក្នុងន័យនាមករណ៍ ដែលស្របទៅនឹងការងើបឡើងវិញនៃការប្រើប្រាស់ឯកជន (សូមមើលផ្នែកទី១) ប៉ុន្តែបានធ្លាក់ចុះជាលំដាប់បើគិតជាភាគរយនៃ ផ.ស.ស. ដែលបង្ហាញពីការរេចរឹលនៃមូលដ្ឋានពន្ធ បញ្ហាប្រឈម នៃការងើបឡើងវិញក្រោយកូវីដ និងអាចមកពីបញ្ហាអនុលោមភាពផងដែរ។ អាករពិសេសនៅតែជាផ្នែកមួយមានការអនុវត្តខ្សោយជាងគេ — ទាបជាងកម្រិតមុនកូវីដ ទាំងក្នុងន័យនាមករណ៍ និងបើគិតជាចំណែកនៃ ផ.ស.ស — ដែលបង្ហាញពីកង្វះប្រសិទ្ធភាពនៃរចនាសម្ព័ន្ធ (ការរៀបចំវិសាលភាព ឬរដ្ឋបាល) និងក៏អាចមកពីការផ្លាស់ប្តូរឥរិយាបថរបស់អ្នកប្រើប្រាស់ (តារាង S.2) ផងដែរ។ និន្នាការទាំងនេះគូសបញ្ជាក់ថា កំណើនសរុបនៃការប្រមូលពន្ធ មិនមែនមានន័យថាការប្រមូលចំណូលមានកិច្ចខិតខំប្រឹងប្រែងរឹងមាំជាងមុនទេ ហើយកាន់តែរំលេចឱ្យឃើញពីតម្រូវការធ្វើកំណែទម្រង់គ្រប់ជ្រុងជ្រោយដើម្បីកសាងប្រព័ន្ធពន្ធដារឡើងវិញឱ្យដើរទាន់គ្នាជាមួយកំណើនសេដ្ឋកិច្ច។

**សមិទ្ធកម្មនៃការប្រមូលចំណូលបានចុះខ្សោយ ចំពេលដែលឱនភាពសារពើពន្ធរីកកាន់តែធំ ចាប់តាំងពីមានជំងឺរាតត្បាតមក។** ឱនភាពនេះត្រូវបានព្យាករថានឹងរួមតូចមកនៅត្រឹម ២,៧ ភាគរយនៃ ផ.ស.ស នៅឆ្នាំ២០២៥ ដោយធ្លាក់ចុះពីប្រមាណ ៣ ភាគរយនៅឆ្នាំ២០២៤។[11] ត្រង់នេះផ្ទុយពីអតិរេកសារពើពន្ធដែលមាន ០,៤ និង ១,៥ ភាគរយ ក្នុងឆ្នាំ២០១៨ និង២០១៩ រៀងខ្លួន។ ឱនភាពនេះបាននាំឱ្យមានការដកយកថវិកាពីទុនបម្រុងសារពើពន្ធមកប្រើប្រាស់ ហើយធ្វើឱ្យបំណុលសាធារណៈកើនឡើង។ សម្ពាធលើហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា អាចរឹតត្បិតសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះបញ្ហាប្រឈមដែលកំពុងកើតមាន និងចំពោះកាខ្វះលទ្ធភាពសម្រាប់ការចាយវាយលើវិស័យនានាដូចជា សុខាភិបាល បើធៀបនឹងប្រទេសមានចំណូលមធ្យម, ក្នុងការកែលម្អគុណភាពសេវាសាធារណៈ និងក្នុងការកាត់បន្ថយផលប៉ះពាល់នៃហានិភ័យនៃការប្រែប្រួលអាកាសធាតុមកលើសេដ្ឋកិច្ចរបស់ខ្លួន។[12] ផលប៉ះពាល់នេះបានស្ដែងឱ្យឃើញច្បាស់រួចហើយ គឺការរួមតូចនៃឱនភាពនៅឆ្នាំ២០២៥ តាមរយៈការរឹតបន្តឹងសារពើពន្ធ ដែលក្នុងនោះការចំណាយមូលធនបានធ្លាក់ចុះគួរឱ្យកត់សម្គាល់។

**ចំណូលពន្ធពឹងផ្អែកខ្លាំងលើពន្ធប្រយោល។** ពន្ធលើការប្រើប្រាស់ (ដូចជាពន្ធលើទំនិញ និងសេវាកម្ម) ជាចំណែកដ៏ធំមួយនៃចំណូលសរុប ទោះបីជាវាកំពុងធ្លាក់ចុះក៏ដោយ។ នៅឆ្នាំ២០១៧ ពន្ធទាំងនេះមានចំនួនប្រហែល ៨,២ ភាគរយនៃ ផ.ស.ស ឬ ៦៣ ភាគរយនៃចំណូលពន្ធសរុប។ ចំណែកនេះបានបន្តប្រែប្រួល និងបានធ្លាក់ចុះមកនៅត្រឹម ៧,៤ ភាគរយនៃ

10 ទោះជា “ពន្ធលើប្រាក់ចំណេញ” របស់កម្ពុជា មិនត្រូវបានចាត់ថ្នាក់ជាផ្លូវការថាជាពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) ក៏ដោយ ក៏វាមានមុខងារស្រដៀងគ្នាដែរ ហើយសម្រាប់គោលបំណងប្រៀបធៀប គេសំដៅលើពន្ធនេះថាជា CIT នៅក្នុងការវិភាគនេះ។

11 ធនាគារពិភពលោក 2024b។

12 ធនាគារពិភពលោក ការពិនិត្យឡើងវិញហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្នាំ២០២៣។

### រូប S.3 ៖ រចនាសម្ព័ន្ធពន្ធនៅតែលម្អៀងទៅរកពន្ធប្រយោល

ផ្ទាំង A. % នៃ ផ.ស.ស. និងពន្ធប្រយោលជាចំណែកនៃពន្ធសរុប




ផ្ទាំង B. សមាសភាគពន្ធ, % នៃ ពន្ធសរុប (២០២៤)




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

### រូប S.4 ៖ ចំណូលពន្ធដែលប្រមូលបានពីមូលដ្ឋានប្រើប្រាស់ (ពន្ធប្រយោល) គឺខ្ពស់ជាងនៅប្រទេសជិតខាង

*ចំណែកជាភាគរយ (២០២១-២៤)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ, UNU-WIDER Government Revenue Dataset - Version 2023; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

ផ.ស.ស ឬ ៥៨ ភាគរយនៅឆ្នាំ២០២៤ (តារាង S.3, ផ្ទាំង A)។ នៅឆ្នាំ២០២៤ អាករលើតម្លៃបន្ថែម (VAT) មានចំនួនប្រហែលមួយភាគបីនៃចំណូលពន្ធសរុប (តារាង S.3, ផ្ទាំង B) និងជិតពាក់កណ្ដាលនៃចំណូលពន្ធប្រយោលសរុប។ តួនាទីនៃពន្ធលើការប្រើប្រាស់ គឺខ្ពស់ជាងពន្ធផ្ទាល់លើប្រាក់ចំណេញ និងប្រាក់ចំណូលនៅកម្ពុជា បើធៀបទៅនឹងប្រទេសជិតខាង (តារាង S.4)។

## *ពន្ធលើប្រាក់ចំណូល*

**ចំណូលពន្ធលើប្រាក់ចំណូលបានកើនឡើង គិតជាចំណែកនៃ ផ.ស.ស ប៉ុន្តែមានចំណែកតូចជាងនៃចំណូលសរុបរបស់កម្ពុជា បើធៀបទៅនឹងប្រទេសក្នុងតំបន់ និងពិភពលោក។** ចំណូលពន្ធលើប្រាក់ចំណូលបានកើនឡើងពី ២,៦ ទៅ ៣,៩ ភាគរយនៃ ផ.ស.ស នៅចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០២៤ (រូប S.5)។ ទោះបីជាយ៉ាងនេះក្ដី ចំណែកពន្ធលើប្រាក់ចំណូលរបស់កម្ពុជាក្នុងចំណូលពន្ធសរុប នៅតែទាបជាងមធ្យមភាគនៅបណ្ដាប្រទេសអាស៊ាន, អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក, អាហ្វ្រិក និងប្រទេសសមាជិកនៃអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ។ ប្រទេសកាន់តែមាន គេពឹងផ្អែកកាន់តែខ្លាំងលើពន្ធលើប្រាក់ចំណូល (រូប S.6)។ អនុបាតពន្ធលើប្រាក់ចំណូលធៀបនឹង ផ.ស.ស របស់កម្ពុជា គឺនៅទាបជាងមធ្យមភាគនៅតាមប្រទេសដែលមានចំណូលប្រហាក់ប្រហែលគ្នាក្នុងក្រុមប្រទេសចំណូលមធ្យមកម្រិតទាប; វាខ្ពស់ជាងនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប៉ុន្តែទាបជាងនៅប្រទេសជិតខាងអាស៊ានផ្សេងទៀត។ ជាមធ្យម មួយចំណែកធំនៃចំណូលពន្ធនៅប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី សិង្ហបុរី ថៃ និងវៀតណាម បានមកពីពន្ធលើប្រាក់ចំណូល។ អនុបាតពន្ធលើប្រាក់ចំណូលធៀបនឹង ផ.ស.ស ដែលមានកម្រិតទាបនេះ គឺដោយសារតែកម្ពុជាមានចិត្តល្អក្នុងផ្ដល់ការលើកទឹកចិត្តផ្នែកពន្ធ និងការមិនទាន់មានពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) គ្រប់ជ្រុងជ្រោយមួយ។

**កម្ពុជាមិនទាន់មានការយកពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) គ្រប់ជ្រុងជ្រោយមួយនៅឡើយទេ។**[13] កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសពីរនៅអាស៊ានដែលគ្មានប្រព័ន្ធ PIT គ្រប់ជ្រុងជ្រោយ; ប្រទេសនេះពឹងផ្អែកជាចម្បងលើការយកពន្ធលើប្រាក់ចំណូលពីការងារ និងកិច្ចការ

13 ខណៈដែលមិនទាន់មានការអនុវត្តពេញលេញនូវប្រព័ន្ធពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗគ្រប់ជ្រុងជ្រោយនៅឡើយ រចនាសម្ព័ន្ធពន្ធដែលមានស្រាប់ រួមមានពន្ធលើប្រាក់បៀវត្ស និងពន្ធកាត់ទុកលើសេវាកម្ម ប្រាក់ចំណូលអកម្ម និងទម្រង់ចំណូលផ្សេងទៀត ដែលជារួមតំណាងឱ្យធាតុផ្សំសំខាន់ៗនៃប្រព័ន្ធពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ។ សម្រាប់គោលបំណងនៃការប្រៀបធៀបជាអន្តរជាតិនៅក្នុងរបាយការណ៍នេះ ពន្ធទាំងនេះ ត្រូវបានគេសំដៅថាជាពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) ដែលតាមការយល់ដឹងថា កម្ពុជាមិនទាន់បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការគ្រប់ជ្រុងជ្រោយនៅឡើយទេ ខណៈដែលពន្ធលើប្រាក់ចំណូលដែលដាក់លើក្រុមហ៊ុន ឬសហគ្រាស គឺជាពន្ធលើប្រាក់ចំណូលសាជីវកម្ម (CIT)។

**រូប S.5 ៖ ពន្ធលើប្រាក់ចំណូល**

*% នៃ ផ.ស.ស*




**រូប S.6 ៖ ប្រទេសកាន់តែមាន កាន់តែពឹងផ្អែកលើប្រាក់ចំណូល**

*% នៃ ផ.ស.ស (២០២១ – ២០២៤)*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ, UNU-WIDER Government Revenue Dataset - Version 2023; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

*សម្គាល់៖ អាស៊ាន*, មិនរាប់បញ្ចូលប្រទេសកម្ពុជា។ RHS = អ័ក្សខាងស្តាំ។

LMIC = ប្រទេសមានចំណូលទាបកម្រិតមធ្យម; EAP = តំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក

អាជីវកម្មដែលមិនបានចុះបញ្ជី។[14] ពន្ធលើប្រាក់បៀវត្សមានចំណែកតូចមួយនៅក្នុងសមាសភាពចំណូលរបស់កម្ពុជា។ នៅក្នុងឆ្នាំ២០២៤ ពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) មានចំនួន ៨១ ភាគរយនៃពន្ធលើប្រាក់ចំណូល និង ៣០ ភាគរយនៃចំណូលពន្ធសរុប។ ខណៈដែលវាជារឿងធម្មតាទៅហើយដែលប្រទេសក្នុងតំបន់ពឹងផ្អែកលើពន្ធសាជីវកម្ម កម្ពុជាពឹងផ្អែកខ្លាំងជាងប្រទេសដទៃទៀត (៩៥ ភាគរយ នៅហ្វីលីពីន, ៦៨ ភាគរយនៅថៃ និង ៧២ ភាគរយនៅវៀតណាម)។ ចំណុចនេះកាន់តែបញ្ជាក់បន្ថែមនូវការពឹងផ្អែកកាន់តែខ្ពស់លើពន្ធលើការប្រើប្រាស់ បើធៀបទៅនឹងបណ្តាប្រទេសអាស៊ានផ្សេងទៀត ដែលពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ/ពន្ធលើប្រាក់បៀវត្សរ៍ដើរតួនាទីសំខាន់ជាងក្នុងការបង្កើតចំណូល។ ពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗដែលនៅរាយប៉ាយខ្លាំង មិនបានដើរតួជាឧបករណ៍ សម្រាប់វាស់វែងប្រាក់ចំណូលបុគ្គលឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់បន្ទុកពន្ធឱ្យបានសមស្រប ឬដើម្បីប្រើប្រាស់ក្នុងការគ្រប់គ្រងកម្មវិធីសុខុមាលភាពសង្គមនោះទេ។

**សេដ្ឋកិច្ចក្រៅប្រព័ន្ធជាឧបសគ្គក្នុងការកសាងមូលដ្ឋានពន្ធលើចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT)។** ភាគចំណែកនៃសកម្មភាពក្នុងវិស័យក្រៅប្រព័ន្ធក្នុងសកម្មភាពមិនមែនកសិកម្ម បានធ្លាក់ចុះពីជាង ៩០ ភាគរយ មកនៅត្រឹម ៨៣ ភាគរយ នៅចន្លោះឆ្នាំ២០១២ និងឆ្នាំ២០១៩។[15] ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចក្រៅប្រព័ន្ធនៅតែមានកម្រិតខ្ពស់ ហើយខ្ពស់ជាងប្រទេសជិតខាងរបស់កម្ពុជាទៅទៀត។ ជាលទ្ធផល ការពង្រីកមូលដ្ឋានពន្ធអាចជួបការលំបាកដោយសារតែទំហំនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងចំនួនអ្នកជាប់ពន្ធ PIT ដែលទំនងជាមាននៅក្នុងចំណោមកម្លាំងពលកម្មសរុប។ ម៉្យាងវិញទៀត អ្នកដែលអាចជាប់ពន្ធ PIT អាចនៅក្រៅពីអ្នកដែលមានការងារជាផ្លូវការ និងជាប់ពន្ធលើប្រាក់បៀវត្សរ៍។ បុគ្គលជាច្រើនដែលប្រកបអាជីវកម្មខ្នាតតូចអាចមិនបានចុះបញ្ជីជាមួយអគ្គនាយកដ្ឋានពន្ធដារ ប៉ុន្តែពួកគេបង្កើតប្រាក់ចំណូលដែលអាចជាប់ពន្ធ។ នៅឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញវិធានការគោលនយោបាយជាបន្តបន្ទាប់[16] ក្នុងគោលបំណងលើកទឹកចិត្តប្រតិបត្តិករអាជីវកម្មខ្នាតតូច និងមធ្យម ឱ្យចុះបញ្ជីក្នុងប្រព័ន្ធពន្ធដារ និងបង្កើនមូលដ្ឋានពន្ធ។ ជំហានកំណែទម្រង់បន្ថែមទៀតអាចត្រូវបានធ្វើឡើងដើម្បីពង្រឹងរដ្ឋបាលក្នុងរយៈពេលខ្លីសម្រាប់អ្នកបង់ពន្ធលើប្រាក់បៀវត្សរ៍ដែលមានស្រាប់ និងដើម្បីបង្កើនសក្តានុពលពន្ធលើប្រាក់ចំណូលឱ្យដល់អតិបរមា នៅពេលដែលកម្ពុជាបន្តអភិវឌ្ឍ ហើយចំណែកកម្លាំងពលកម្មកាន់តែច្រើនឡើងបានងាកទៅរកការងារផ្លូវការមិនមែនកសិកម្មវិញ។

**កំណើនចំណូលពន្ធលើប្រាក់ចំណូលក្រុមហ៊ុនកំពុងថយល្បឿន បន្ទាប់ពីមានកំណើនរឹងមាំអស់មួយទសវត្សរ៍។** សមិទ្ធកម្មនៃពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) មានភាពប្រសើរឡើងច្រើននៅចន្លោះឆ្នាំ២០១៥ និង២០២២ ដោយចំណូល CIT កើនឡើងជិតពីរដងដល់ក្រោម ៤ ភាគរយ គិតជាចំណែកនៃ ផ.ស.ស ស្របគ្នាជាមួយការកើនឡើងនៃផលិតភាព (រូប S.7, ផ្ទាំង A)។ ត្រង់នេះឆ្លុះបញ្ចាំងពីរយៈពេលមួយដែលវិស័យសាជីវកម្មមានកំណើនរឹងមាំ អមដោយការពង្រីកនៃអនុលោមភាព និងការពង្រឹងរដ្ឋបាលពន្ធ។ ប៉ុន្តែ ការធ្លាក់ចុះទាំងចំណូល CIT និងផលិតភាពនៅឆ្នាំ២០២៣ និង២០២៤ បង្ហាញឱ្យឃើញពីការ

14 ប្រាក់ចំណូលដែលរកបានដោយអង្គភាពមិនបានចុះបញ្ជី រួមទាំងអាជីវកម្មជាដៃគូ និងសហគ្រាសឯកបុគ្គលត្រូវជាប់ពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ ក្នុងរចនាសម្ព័ន្ធអត្រាពន្ធតាមឋានានុក្រម។

15 ទិន្នន័យការងារក្រៅប្រព័ន្ធពី ILOSTAT។

16 ទាំងនេះរួមមាន យុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សេដ្ឋកិច្ចក្រៅប្រព័ន្ធ ២០២៣-២០២៨, អនុក្រឹត្យលេខ ២៧២ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ, និងប្រកាស (សេចក្តីណែនាំផ្លូវការរបស់រដ្ឋាភិបាល) លេខ ៨១០ ស្តីពីគោលការណ៍ណែនាំអនុវត្តសម្រាប់អនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលបានចេញនៅឆ្នាំ២០២៤។

**រូប S.7 ៖ ចំណូលពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) កើនក្នុងល្បឿនយឺតជាងមុន បន្ទាប់ពីកើនឡើងខ្លាំងអស់ពេលជាច្រើនឆ្នាំ**

*ផ្ទាំង A. ការប្រមូលពន្ធ CIT, % នៃផ.ស.ស និងផលិតភាព*

*ផ្ទាំង B. ការប្រៀបធៀបក្នុងតំបន់ ការប្រមូលពន្ធ CIT និងផលិតភាព*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ, សំណុំទិន្នន័យចំណូលរដ្ឋាភិបាល UNU-WIDER - កំណែឆ្នាំ២០២៣; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។
*សម្គាល់៖ RHS* = ខាងស្តាំ។

ថយចុះនៃលទ្ធភាពរកបានប្រាក់ចំណេញរបស់សាជីវកម្ម ការថយចុះនៃមូលដ្ឋានពន្ធ និងការលេចឡើងនូវភាពទន់ខ្សោយដែលកំពុងកើតមាននៅក្នុងការអនុវត្តប្រមូលពន្ធផងដែរ។ ដើម្បីរក្សាសមិទ្ធកម្មក្នុងការប្រមូលពន្ធលើចំណូលក្រុមហ៊ុនឱ្យបានរឹងមាំ ចាំបាច់ត្រូវបន្តកំណែទម្រង់ផ្នែករដ្ឋបាល និងគោលនយោបាយដើម្បីពង្រីកមូលដ្ឋានពន្ធ និងបង្កើនភាពធន់នៃការយកពន្ធលើចំណូលក្រុមហ៊ុន សម្រាប់ត្រៀមទប់ទល់ជាមួយផលប៉ះទង្គិចមកសេដ្ឋកិច្ច នាពេលអនាគត។ នៅក្នុងកម្រិតតំបន់ ការប្រមូលពន្ធលើចំណូលក្រុមហ៊ុននៅកម្ពុជា គិតជាភាគរយនៃ ផ.ស.ស គឺមានកម្រិតប្រហាក់ប្រហែលនៅវៀតណាម និងថៃ ប៉ុន្តែទាបជាងនៅហ្វីលីពីន និងម៉ាឡេស៊ី (រូប S.7, ផ្ទាំង B)។ ទោះបីជាអត្រា[17] នេះនៅតែ ខ្ពស់ជាងអត្រាពន្ធសាជីវកម្មអប្បបរមា១៥ ភាគរយដែលបានព្រមព្រៀងជាអន្តរជាតិ ក៏ដោយ ក៏វាមានលក្ខណៈប្រកួតប្រជែងដែរ បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់។

**ច្បាប់ស្តីពីវិនិយោគឆ្នាំ២០២១ បានពង្រីកបន្ថែមនូវការលើកទឹកចិត្តពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) នៅកម្ពុជា ទោះបីជាមុននេះ របបលើកទឹកចិត្តដល់ការវិនិយោគ មានលក្ខណៈអំណោយផលយ៉ាងហោចណាស់ក៏ប្រហាក់ប្រហែលគ្នានឹងរបបដែលមាននៅប្រទេសជិតខាងរួចទៅហើយក្តី។** ឥឡូវនេះ វិនិយោគិនអាចទទួលបានការលើកលែងពន្ធលើប្រាក់ចំណូលរយៈពេលពី ៣ ទៅ ៩ឆ្នាំ ជាមួយនឹងការកាត់បន្ថយអត្រាពន្ធលើចំណូលក្រុមហ៊ុន រយៈពេលប្រាំមួយឆ្នាំបន្ថែមទៀត។ រយៈពេលបន្ថែមនៃការលើកលែងពន្ធនេះ នឹងនាំឱ្យមានការខាតបង់ចំណូលបន្ថែមទៀត។ ទោះបីជាមិនមានតួលេខប៉ាន់ប្រមាណអំពីចំណូលដែលបានបាត់បង់ក៏ដោយ តាមការប៉ាន់ស្មាន កម្ពុជាបានបាត់ជិតមួយភាគបីនៃចំណូលគយដែលអាចប្រមូលបានពីការនាំចូលដែលឆ្លុះបញ្ចាំងឱ្យឃើញពីតម្លៃខាតបង់ធំមួយពីប្រការលើកទឹកចិត្តពន្ធ។ អាស្រ័យហេតុនេះ ជារឿងសំខាន់មួយដែលគេគួរពិចារណា និងគណនាឱ្យបានល្អិតល្អន់អំពីទំហំនៃផលប៉ះពាល់ដែលអាចកើតមាន (ទាំងអត្ថប្រយោជន៍ និងការខាតបង់) ពីការពង្រីករយៈពេលលើកលែងពន្ធ ដើម្បីធានាឱ្យមានការយកចិត្តទុកដាក់អំពីគោលបំណងរបស់ចំណូល និងការអភិវឌ្ឍ។

## អាករលើតម្លៃបន្ថែម

**អាករលើតម្លៃបន្ថែម (VAT) របស់កម្ពុជា ត្រូវបានអនុវត្តល្អគួរសម បើធៀបទៅនឹងបណ្តាប្រទេសក្នុងតំបន់ (រូប S.8, ផ្ទាំង A) ដោយចំណូល VAT មានចំណែកប្រហែល ៤ ភាគរយនៃ ផ.ស.ស និងសន្ទស្សន៍ប្រសិទ្ធភាព (C-efficiency) 0,៤១ — ដែលវាស់វែងថាតើ VAT ត្រូវបានប្រមូលបានប៉ុន្មានគិតជាអតិបរមាជាក់ស្តែង ធៀបទៅនឹងទ្រឹស្តី។** សន្ទស្សន៍នេះ បង្ហាញពីមូលដ្ឋានពន្ធដែលធំទូលាយល្មម និងអនុលោមភាពក្នុងកម្រិតមធ្យម។ ចំណូល VAT ភាគច្រើនត្រូវបានប្រមូលពី VAT លើការនាំចូល

17 CIT ត្រូវបានអនុវត្តនិងវាយតម្លៃជារៀងរាល់ឆ្នាំលើប្រាក់ចំណូលជាប់ពន្ធរបស់អង្គភាពដែលបានចុះបញ្ជី ដោយមានអត្រាពន្ធចាប់ពី ៥ ភាគរយ ដល់ ៣០ ភាគរយ អាស្រ័យលើប្រភេទអាជីវកម្ម និងទម្រង់ច្បាប់។ អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការប្រេងកាត និងធនធានរ៉ែ ត្រូវជាប់ពន្ធក្នុងអត្រា ៣០ ភាគរយ ហើយនីតិបុគ្គលទាំងអស់ត្រូវជាប់ពន្ធក្នុងអត្រា ២០ ភាគរយ។ សម្រាប់ការធានារ៉ាប់រងទូទៅ ការធានារ៉ាប់រងបន្ត ឬសហគ្រាសខ្នាតតូចដែលរួមមានការធានារ៉ាប់រងលើអចលនទ្រព្យ ការទទួលខុសត្រូវ និងសុខភាព ត្រូវអនុវត្ត ៥ ភាគរយនៃបុព្វលាភដុលដែលទទួលបាន។ អ្នកជាប់ពន្ធ CIT តម្រូវឱ្យដាក់លិខិតប្រកាស និងបង់ពន្ធ CIT ក្នុងរយៈពេលបីខែបន្ទាប់ពីដំណាច់ឆ្នាំជាប់ពន្ធ។ មូលដ្ឋាន CIT រួមមានប្រាក់ចំណូលពីអាជីវកម្ម និងសកម្មភាពផ្សេងៗទៀត។ ជាពិសេស យោងតាមប្រកាស (សេចក្តីណែនាំផ្លូវការរបស់រដ្ឋាភិបាល) ស្តីពីពន្ធលើប្រាក់ចំណូល ប្រាក់ចំណូលសម្រាប់គោលបំណងនៃការយកពន្ធរួមមាន ប្រាក់ចំណូលពីការជួលអចលនទ្រព្យ កម្រៃជើងសា ភាគលាភ ផលចំណេញមូលធន សំណងធានារ៉ាប់រង និងអំណោយ និងជំនួយឥតសំណង ក្នុងចំណោមប្រភពចំណូលផ្សេងៗទៀត។ ខណៈ ដែលប្រកាសនេះរាយនាមប្រភពចំណូលជាក់លាក់ដែលត្រូវបញ្ចូលក្នុងមូលដ្ឋានពន្ធលើប្រាក់ចំណូលអាជីវកម្ម ច្បាប់ហាក់ដូចជាមិនបានចែងនិយមន័យកំណត់ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយអំពីប្រាក់ចំណូល ដើម្បីណែនាំអំពីការកំណត់អត្តសញ្ញាណនៃប្រភពចំណូលទាំងអស់ដែលត្រូវពិចារណាក្នុងការយកពន្ធលើប្រាក់ចំណូល នោះទេ។

## រូប S.8 ៖ VAT សម្រេចសមិទ្ធកម្មបានល្អ ដោយចំណូលភាគច្រើនបានមកពីការនាំចូល

*ផ្ទាំង A. VAT, ជា % នៃផ.ស.ស និងសន្ទស្សន៍ប្រសិទ្ធភាព (ខាងស្តាំ), ២០២១-២០២៤*

*ផ្ទាំង B. សមាសភាគចំណូល VAT ប្រមូលក្នុងស្រុក និងពីការនាំចូល*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ, សំណុំទិន្នន័យ UNU-WIDER Government Revenue Dataset – Version 2023; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

ដែលមានចំនួនជាង ៥០ភាគរយ (រូប S.8, ផ្ទាំង B)។ ទោះជាយ៉ាងណាក៏ដោយ គេឃើញមានគម្លាតកាន់តែធំឡើង រវាង VAT ដែលប្រមូលបានជាក់ស្តែង និង VAT ដែលនៅគួរប្រមូលបាន ដោយក្នុងនោះ សន្ទស្សន៍ប្រសិទ្ធភាព បានធ្លាក់ចុះពី ០,៥០ មក ០,៤១ នៅចន្លោះឆ្នាំ២០១៩ និង ២០២៤ ដែលឆ្លុះបញ្ចាំងពីវិសាលភាពសម្រាប់ការពង្រឹងប្រសិទ្ធភាពថែមទៀតក្នុងការប្រមូល VAT។ កម្ពុជានៅតែយឺតជាងប្រទេសមួយចំនួនក្នុងអាស៊ាន ដូចជាថៃ និងវៀតណាម ដែលមានសន្ទស្សន៍ប្រសិទ្ធភាពក្នុងការប្រមូល VAT ខ្ពស់ជាង។ ដោយសារតែ VAT មានចំណែកធំនៅក្នុងចំណូលពន្ធសរុប ការថយចុះណាមួយនៃការអនុវត្តរបស់ VAT នឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រមូលពន្ធសរុប។

**ការចំណាយពេលយូរនៅក្នុងដំណើរការបង្វិលសង VAT ជះឥទ្ធិពលមិនល្អដល់ប្រសិទ្ធភាពនៃប្រព័ន្ធ VAT ដែលកំពុងតែមានសភាពយ៉ាប់យ៉ឺនខ្លាំងឡើង ដោយសារការប្រើប្រាស់ច្រើនពេកនូវការកំណត់អត្រាសូន្យក្នុងស្រុក ដែលធ្វើឱ្យទំហំ និងភាពស្មុគស្មាញក្នុងការទាមទារបង្វិលសងមានការកើនឡើងយ៉ាងខ្លាំង។** ក្រោម**យុទ្ធសាស្ត្រគៀរគរចំណូលទីពីរ** ដែលបានអនុវត្តកន្លងមក រដ្ឋាភិបាលបានកែលម្អដំណើរការបង្វិលសង រួមទាំងការប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicators)។ ទោះជាយ៉ាងណាក៏ដោយ ពេលវេលាបង្វិលសងនៅតែត្រូវបានសម្គាល់ឃើញថាស៊ីពេលយូរ និងចំណាយពេលរហូតដល់បួនសប្តាហ៍ ដោយគ្មាននីតិវិធីសាស្ត្រផ្អែកលើហានិភ័យសម្រាប់ដំណើរការបង្វិលសង VAT ឡើយ - នេះបើយោងតាមរបាយការណ៍ B-Ready របស់ធនាគារពិភពលោក។ ដំណើរការបង្វិលសង VAT យឺតយ៉ាវ បានធ្វើឱ្យអ្នកជាប់ពន្ធជួបការលំបាកខាងដើមទុនសម្រាប់យកទៅបង្វិលធ្វើអាជីវកម្ម ហើយក៏អាចរួមចំណែកធ្វើឱ្យអ្នកជាប់ពន្ធកាន់តែមានឥរិយាបថអវិជ្ជមានក្នុង ចំពោះប្រព័ន្ធពន្ធដារផងដែរ។ នៅក្នុងការអនុវត្តជាក់ស្តែង គេត្រូវការចំណាយពេលយូរទម្រាំទទួលបានការបង្វិលសង VAT មកវិញ មួយផ្នែកដោយសារតែអគ្គនាយកដ្ឋានពន្ធដារ ជាធម្មតា តម្រូវឱ្យមានសវនកម្មសិនមុននឹងអនុម័តលើសំណើទារសង VAT។ ការយឺតយ៉ាវក្នុងការដំណើរការ និងការទូទាត់ការបង្វិលសង ដោយសារតែការកកស្ទះរវាង អគ្គនាយកដ្ឋានពន្ធដារ និងនាយកដ្ឋានរតនាគារជាតិ ហើយការដាក់ឯកសារមិនពេញលេញរបស់អ្នកជាប់ពន្ធ ត្រូវបានគេជឿថាបានរួមចំណែកធ្វើឱ្យដំណើរការបង្វិលសង VAT នៅកម្ពុជាប្រើប្រាស់ពេលវេលាយូរដែរ។ មានកិច្ចខិតខំប្រឹងប្រែងសំខាន់ៗដើម្បីសម្រួលនីតិវិធី កំណត់ពេលវេលាច្បាស់លាស់ជាងមុន និងបង្កើនសេវាកម្មសម្រាប់អ្នកជាប់ពន្ធ។[18] ឧទាហរណ៍ សេចក្តីណែនាំថ្មីមួយ[19] ស្តីពីចំណាត់ថ្នាក់នៃការអនុលោមភាពសារពើពន្ធ បានចាត់ថ្នាក់អ្នកជាប់ពន្ធជាបីប្រភេទ ក្នុងនោះ អ្នកជាប់ពន្ធដែលមានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទមាស អាចមានសិទ្ធិទទួលបានការបង្វិលសង VAT លឿនសម្រាប់ចំនួនទឹកប្រាក់ក្រោមដែនកំណត់ជាក់លាក់ណាមួយ ដោយមិនចាំបាច់ឆ្លងកាត់សវនកម្ម VAT ដាច់ដោយឡែក។[20] វិធានការទាំងនេះអាចដើរតួនាទីមួយក្នុងការកាត់បន្ថយអប្រសិទ្ធភាពនានាដែលពាក់ព័ន្ធ។

**មូលដ្ឋាន VAT មានភាពតូចចង្អៀតដោយសារតែការលើកលែងពន្ធ ជាពិសេសសម្រាប់អ្នកអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ក្រោមច្បាប់ស្តីពីវិនិយោគរបស់កម្ពុជា និងដោយសារទង្វើមិនផ្លូវការមានកម្រិតខ្ពស់។** អ្នកផ្គត់ផ្គង់ត្រូវទទួលខុសត្រូវចំពោះ VAT ប្រសិនបើផលរបរសរុបប្រចាំឆ្នាំរបស់ពួកគេលើសពី ២៥០ លានរៀល (ប្រហែល ៦២ ៤៧២ ដុល្លារអាមេរិក) (ឬស្ថិតក្រោមរបបស្វ័យប្រកាស)។ ទោះជាយ៉ាងណាក៏ដោយ ផលិតផលជាច្រើនត្រូវបានលើកលែង។ ផលិតផលមួយចំនួនត្រូវបាន

18 នេះរួមបញ្ចូលទាំងប្រកាសលេខ ៥៧៦ ស្តីពីយន្តការបង្វិលសងអាករលើតម្លៃបន្ថែម (VAT) ដែលផ្តល់ការណែនាំច្បាស់លាស់ និងលម្អិតអំពីនីតិវិធី និងលំហូរការងារសម្រាប់ការដាក់ស្នើការទាមទារបង្វិលសង VAT។

19 ប្រកាសលេខ ១៥៣៦

20 ក្រោមក្របខ័ណ្ឌទាំងនេះ អ្នកជាប់ពន្ធប្រភេទមាសត្រូវបានលើកលែងពីសវនកម្មបង្វិលសង VAT សម្រាប់រយៈពេលពីរឆ្នាំសម្រាប់ការទាមទារបង្វិលសងមិនលើសពី ១២៥ 000 ដុល្លារអាមេរិក ខណៈដែលអ្នកជាប់ពន្ធប្រភេទប្រាក់ត្រូវបានលើកលែងពីសវនកម្មបែបនេះសម្រាប់ការទាមទារបង្វិលសងមិនលើសពី ៥០ 000 ដុល្លារអាមេរិកក្នុងរយៈពេលដូចគ្នា។

**រូប S.9 ៖ ចំណូលអាករពិសេសបានធ្លាក់ចុះ និងពឹងផ្អែកលើការនាំចូល**

*កម្ពុជា, ២០១៥-២០២២*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

**រូប S.10 ៖ ចំណូលអាករពិសេសស្ថិតក្នុងចំណោមចំណូលធំជាងគេក្នុងតំបន់ ជា % នៃផ.ស.ស**

*ប្រទេសមួយចំនួន, ឆ្នាំ២០២០-២០២២*




*ប្រភព៖ ការប៉ាន់ប្រមាណរបស់កម្មវិធីពន្ធសកលរបស់ធនាគារពិភពលោក* ដោយប្រើប្រាស់ទិន្នន័យពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; វិទ្យាស្ថានជាតិស្ថិតិ។

លើកលែងពី VAT[21] ដូចជាផលិតផលកសិកម្ម រួមទាំងជីគ្រាប់ពូជដំណាំ ថ្នាំសត្វ និងសេវាកម្មកាត់ដេរ និងតម្រឹម (CMT)។[22] ការផ្គត់ផ្គង់ដែលលើកលែងពី VAT ក៏រួមបញ្ចូលផងដែរនូវសេវាកម្មធានារ៉ាប់រង សេវាកម្មហិរញ្ញវត្ថុ និងទំនិញនិងសេវាកម្មផ្សេងៗទៀត។ ការលើកលែងជាច្រើនក្នុងចំណោមនេះរួមមានទំនិញដែលមួយចំណែកធំ ជាទំនិញប្រើប្រាស់សម្រាប់គ្រួសារក្រីក្រ។ ទោះជាយ៉ាងណាក៏ដោយ ការលើកលែងនេះអាចមានតម្លៃថ្លៃ និងនាំឱ្យខាតពន្ធ ព្រោះគ្រួសារអ្នកមានគ្រាន់បើក៏ទទួលបានការលើកលែងពន្ធដែរ ហើយក្នុងបរិមាណច្រើនទៀត ដែលមានន័យថាចំណាយពន្ធភាគច្រើនបានទៅលើគ្រួសារអ្នកមានទៅវិញ។ ក្រៅពីការធ្វើឱ្យខូចមូលដ្ឋានពន្ធ ការប្រើការកំណត់អត្រាសូន្យក្នុងស្រុកកាន់តែច្រើនឡើង នឹងធ្វើឱ្យករណីទារបង្វិលសង VAT និងការក្លែងបន្លំពាក់ព័ន្ធការទារបង្វិលសង VAT កើនឡើងផងដែរ។

## អាករពិសេស

**ការចូលរួមចំណែកនៃអាករពិសេសក្នុងការកៀរគរចំណូលមានសារៈសំខាន់ ហើយប្រមូលផ្តុំនៅលើការនាំចូល។** រវាងឆ្នាំ២០១៥ និងឆ្នាំ២០១៩ ការអនុវត្តចំណូលអាករពិសេសបានកើនឡើងពី ២,៥ ទៅ ៤,៣ភាគរយនៃផ.ស.ស ឬ ពី ២១,២ ទៅ ២៦,៨ ភាគរយនៃចំណូលពន្ធសរុប (រូប S.9)។ ការធ្លាក់ចុះនៃការប្រមូលចំណូលពន្ធបន្ទាប់ពីមានជំងឺរាតត្បាត បានប៉ះទង្គិចខ្លាំងមែនទែនទៅលើអាករពិសេស ដោយចំណែករបស់វានៅក្នុងការប្រមូលពន្ធសរុបបានធ្លាក់ចុះមកនៅត្រឹម ១៧,៤ ភាគរយ (២,២ ភាគរយនៃ ផ.ស.ស) នៅឆ្នាំ២០២៤។ ខណៈដែលអាករពិសេសនៅតែបន្តជាផ្នែកមួយដែលមានស្ថិរភាពនៃចំណូលពន្ធសរុប ការចូលរួមចំណែករបស់វាក្នុងការប្រមូលពន្ធបានចុះខ្សោយ។ ចាប់តាំងពីពេលមានជំងឺរាតត្បាតមក ចំណូលអាករពិសេសមានសភាពងាយប្រែប្រួលខ្លាំង ក្នុងនោះគឺការប្រែប្រួលខ្លាំងនៅក្នុងកំណើនពីមួយឆ្នាំទៅមួយឆ្នាំ ដែលភាគច្រើនបណ្តាលមកពីពន្ធអាករលើការនាំចូល។ នៅឆ្នាំ២០២៣ ស្ថានភាពប្រែប្រួលនេះត្រូវបានឆ្លុះបញ្ចាំងតាមរយៈការធ្លាក់ចុះ ១៩,៥ភាគរយនៃការនាំចូលទំនិញ និងស្ថានភាពប្រសើរឡើងក្នុងការនាំចូលទំនិញប្រើប្រាស់នៅឆ្នាំ២០២៤។ ការពឹងផ្អែកលើការប្រមូលអាករពិសេសពីការនាំចូល ធ្វើឱ្យការអនុវត្តចំណូលសរុបងាយប្រឈមនឹងវិបត្តិពីខាងក្រៅ និងវដ្តពាណិជ្ជកម្ម ដែលនេះជាការបញ្ជាក់ពីភាពចាំបាច់ត្រូវធ្វើពិពិធកម្មមូលដ្ឋានអាករពិសេសក្នុងស្រុក និងពង្រឹងភាពធន់តាមរយៈការរៀបចំអត្រា វិសាលភាពគ្របដណ្តប់ និងអនុលោមភាព ឱ្យប្រសើរជាងមុន។

**ការចូលរួមនៃអាករពិសេសជាចំណែកនៃ ផ.ស.ស របស់កម្ពុជា មានទំហំប្រហាក់ប្រហែលទៅនឹងប្រទេសក្នុងតំបន់ដែរ (រូប S.10)។** ការចូលរួមចំណែកដ៏ធំនៃអាករពិសេសដល់ចំណូលពន្ធសរុប តម្រូវឱ្យមានវិធីសាស្ត្រប្រុងប្រយ័ត្នក្នុងការអនុវត្តគោលនយោបាយអាករពិសេសនៅកម្ពុជា។ ភាពចាំបាច់ធ្វើទំនើបកម្មប្រព័ន្ធអាករពិសេស គួរតែមានការថ្លឹងថ្លែងជាមួយនឹងការសើធីស៊ីជម្រៅផ្នែកគោលនយោបាយ ដោយសារតែរួមចំណែកធំគួរសមដែរដល់ចំណូលពន្ធសរុប។ ភាពចាំបាច់នេះក៏មានអម

21 អត្រា VAT សូន្យត្រូវបានអនុវត្តចំពោះទំនិញនិងសេវាកម្មដូចខាងក្រោម៖ ទំនិញនិងសេវាកម្មដែលផ្គត់ផ្គង់ដោយអង្គភាពក្នុងស្រុកទៅឱ្យគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (QIPs); សេវាកម្មដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែត្រូវបានប្រើប្រាស់នៅក្រៅប្រទេសកម្ពុជាដោយផ្ទាល់ ឬទាំងស្រុងដោយអង្គភាពមិនមែននិវាសនជន; សេវាកម្មដែលបានអនុវត្តនៅក្រៅប្រទេសកម្ពុជា ឬប្រើប្រាស់នៅក្រៅប្រទេសកម្ពុជាសម្រាប់អង្គភាពមិនមែននិវាសនជន; ការផ្គត់ផ្គង់ស្រូវក្នុងស្រុក; ការផ្គត់ផ្គង់អង្ករសម្រួបក្នុងស្រុក ឬសេវាកម្មផលិតអង្ករសម្រួបដោយអ្នកម៉ៅការឱ្យអ្នកនាំចេញអង្ករ; ការផ្គត់ផ្គង់ក្នុងស្រុកនៃផលិតផលកសិកម្ម ជាក់លាក់ រួមទាំងជីគ្រប់ប្រភេទ គ្រាប់ពូជដំណាំ ថ្នាំសត្វ អាហារសត្វ ប្រភេទសត្វ និងគ្រឿងយន្តនិងឧបករណ៍កសិកម្ម; សេវាកម្ម CMT; ការផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូនអន្តរជាតិ; និងឧស្សាហកម្មគាំទ្រដែលផ្គត់ផ្គង់ ដល់ឧស្សាហកម្មកាត់ដេរវាយនភ័ណ្ឌ និងស្បែកជើងសម្រាប់ការនាំចេញ។

22 សេវាកម្ម CMT ត្រូវបានផ្តល់ដោយរោងចក្រកាត់ដេរនៅកម្ពុជា។

**រូប S.11 ៖ ចំណូលមួយភាគធំត្រូវបានប្រមូលពីផលិតផលមួយចំនួនតូច**

*ការបែងចែកចំណូលអាករពិសេសនៅកម្ពុជា, ២០២២*




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច* និងហិរញ្ញវត្ថុ; ការប៉ាន់ប្រមាណរបស់បុគ្គលិកធនាគារពិភពលោក។

ជាមួយផងដែរនូវការពឹងផ្អែកលើអាករពិសេសពីការនាំចូល ដូចដែលបានលើកឡើងភ្ជាប់ជាមួយ VAT នៅខាងលើ ហើយវាអាចរងសម្ពាធសង្កត់កាន់តែខ្លាំងទៀតដែរ ពីកត្តានានាដែលទៅហួសពីលទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជាអាចគ្រប់គ្រងបាន។

**ខណៈដែលវិសាលភាពនៃទំនិញនិងសេវាកម្មជាប់អាករពិសេសនៅកម្ពុជាមានលក្ខណៈធំទូលាយ ចំណូលអាករពិសេសនេះបានមកពីមុខទំនិញមួយចំនួនតូចប៉ុណ្ណោះ។** ឧទាហរណ៍ នៅឆ្នាំ២០២២ អាករពិសេសលើយានយន្ត មានចំណែកធំជាងគេបង្អស់ គឺប្រហែល ៦០ ភាគរយនៃចំណូលអាករពិសេស ហើយចំណែកធំបន្ទាប់[23] (តាមលំដាប់លំដោយ) គឺបានមកពីគ្រឿងស្រវឹង ឥន្ធនៈ និងថ្នាំជក់ (រូប S.11)។ សមាសភាគចំណូលនេះគឺមិនធម្មតា បើគិតតាមស្តង់ដាអន្តរជាតិ ដែលជាទូទៅឥន្ធនៈមានចំណែកធំជាង ហើយតែងតែជាតួអង្គចូលរួមចំណែកធំជាងគេ[24]។ អត្រាអាករពិសេសខុសគ្នាខ្លាំង គឺចាប់ពីទាបត្រឹម ៣ភាគរយ លើប្រេងម៉ាស៊ូត រហូតដល់ខ្ពស់ ៥៥ ភាគរយ លើយានយន្តមួយចំនួន[25]។ ប្រភេទនៃទំនិញជាប់អាករពិសេសមួយចំនួនមិនហាក់ដូចជាបំពេញតាមលក្ខណៈពិសេសមួយចំនួនសម្រាប់អាករពិសេសផងទេ, វាត្រូវបានជ្រើសរើសចោះៗ និងមានចំនួនតិចតួច ហើយតម្រង់ទៅលើតែមុខទំនិញណាដែលនាំឱ្យមានឥទ្ធិពលអវិជ្ជមានខាងក្រៅ និងខាងក្នុង តែប៉ុណ្ណោះ[26]។ របបអាករពិសេសនៅកម្ពុជាគ្របដណ្តប់លើវិស័យធំទូលាយ ដូចជា ការកម្សាន្ត និងឧបករណ៍អេឡិចត្រូនិក ក្នុងចំណោមវិស័យផ្សេងៗទៀត។

**អាករពិសេសនៅកម្ពុជា ជាទូទៅ ជាពន្ធគិតតាមថ្លៃ (ad valorem) និងត្រូវបានយកនៅដំណាក់កាលដំបូងនៃខ្សែចង្វាក់ផ្គត់ផ្គង់ (ពោលគឺ មូលដ្ឋានពន្ធគឺស្ថិតនៅដំណាក់កាលដំបូងនៃខ្សែចង្វាក់ផ្គត់ផ្គង់) ដែលនាំឱ្យពន្ធមានប្រសិទ្ធភាពទាបជាងពន្ធដែលបានអនុវត្តនៅដំណាក់កាលក្រោយនៃខ្សែចង្វាក់ផ្គត់ផ្គង់ (អាចរហូតដល់តម្លៃលក់រាយចុងក្រោយ)។** នៅក្នុងប្រទេសផ្សេងទៀត ដែលមានទម្លាប់យកពន្ធគិតតាមថ្លៃនៅដំណាក់កាលដំបូងនៃខ្សែចង្វាក់ផ្គត់ផ្គង់ មូលដ្ឋានពន្ធគឺខុសគ្នាសម្រាប់ផលិតផលនាំចូល និងផលិតផលផលិតក្នុងស្រុក។ សម្រាប់ការនាំចូល អាករពិសេសត្រូវបានយកលើតម្លៃថ្លៃដើម ការធានារ៉ាប់រង និងការដឹកជញ្ជូន (CIF) បូកនឹងពន្ធគយ ហើយ ៩0 ភាគរយនៃតម្លៃវិក្កយបត្រ (មិនរាប់បញ្ចូលពន្ធទាំងអស់) សម្រាប់ផលិតផលផលិតក្នុងស្រុក។ សម្រាប់សេវាកម្ម អាករពិសេសអាចយកបានលើតម្លៃផ្គត់ផ្គង់ (តម្លៃវិក្កយបត្រ)។[27]

**តម្លៃនៃមូលដ្ឋានពន្ធលើផលិតផលនាំចូល ជាទូទៅ តូចជាងមូលដ្ឋានពន្ធលើផលិតផលធ្វើក្នុងស្រុក ដែលបង្កើតបញ្ហាប្រឈមសម្រាប់ផលិតផលដូចជា បារី និងស្រាបៀរ** ដែលមានទាំងផលិតផលនាំចូល និងផលិតក្នុងស្រុក។ ត្រង់នេះតែងធ្វើឱ្យមានពន្ធប្រសិទ្ធភាពទាបជាងលើផលិតផលនាំចូល ទោះបីជាវាតែងត្រូវបានលក់ក្នុងតម្លៃលក់រាយខ្ពស់ជាងនៅក្នុងទីផ្សារក៏ដោយ។ ការប្រើប្រាស់ពន្ធគិតតាមថ្លៃ និងពន្ធជាក់លាក់ (ពន្ធតាមបរិមាណ)[28] គឺជាយន្តការដែលមានប្រសិទ្ធភាពបំផុតដើម្បីយកឈ្នះបញ្ហាប្រឈមនេះ។ ក្របខ័ណ្ឌណែនាំស្តីពីអាករពិសេសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលស្គាល់ពីភាពខ្សោយ និងភាពគ្មានប្រសិទ្ធភាពនៃរចនាសម្ព័ន្ធពន្ធគិតតាមថ្លៃសម្រាប់ "ទំនិញប្រើប្រាស់តម្លៃទាប ដែលមានផលវិបាកអវិជ្ជមានជាច្រើនទៅលើសុខភាព និងបរិស្ថាន" ក៏ដូចជាបញ្ហាប្រឈមដែលវាបង្កឡើងសម្រាប់ការគ្រប់គ្រងអាករពិសេស។

23 សូមបញ្ជាក់ថា ចំណូលពន្ធពីភេសជ្ជៈគ្មានជាតិអាល់កុលមិនអាចបំបែកបានទេដោយសារតែខ្វះទិន្នន័យ។

24 គេអាចធ្វើទឡ្ហីករណ៍បានថា ការចូលរួមចំណែកដ៏ធំនៃយានយន្ត ជាពិសេសនៅពេលប្រៀបធៀបទៅនឹងឥន្ធនៈ គឺគ្មានប្រសិទ្ធភាពទេ ព្រោះយានយន្តគ្រាន់តែជាអង្គជំនួសមុខមិនសូវល្អមួយប៉ុណ្ណោះសម្រាប់ផលជះអវិជ្ជមាននៅខាងក្រៅ បើធៀបទៅនឹងឥន្ធនៈ។ តាមរយៈនេះ គេអាចនាំចូលយានយន្តដែលមានតម្លៃថោក/ចាស់ ដែលគ្មានប្រសិទ្ធភាពផ្នែកឥន្ធនៈ។ ទោះជាយ៉ាងណាក៏ដោយ ចំណុចនេះត្រូវបានពិចារណាលម្អិតបន្ថែមទៀតនៅក្នុងការវិភាគយានយន្ត និងឥន្ធនៈ។

25 ធនាគារពិភពលោក ២០២២។

26 ខណៈដែលចំណូលពន្ធភាគច្រើនបានមកពីមុខទំនិញដែលបង្កើតផលជះអវិជ្ជមានខាងក្រៅ និងខាងក្នុង ទំនិញជាប់អាករពិសេសមួយចំនួនធំអាចត្រូវបានចាត់ទុកថាជាទំនិញប្រណីត និងបង្កើតចំណូលបានតិចតួច។

27 មូលដ្ឋានអាករពិសេសសម្រាប់ទំនិញផលិតក្នុងស្រុក និងការផ្គត់ផ្គង់សេវាកម្ម គឺរាប់បញ្ចូលពន្ធទាំងអស់ លើកលែងតែអាករពិសេស និង VAT។

28 ពន្ធជាក់លាក់គឺងាយស្រួលក្នុងការគ្រប់គ្រង។ វាមានប្រសិទ្ធភាពជាងក្នុងការកំណត់គោលដៅអវិជ្ជមានខាងក្រៅ ដែលបង្កើតឡើងដោយការប្រើប្រាស់ទំនិញមួយចំនួន (ឧទាហរណ៍ បារី ឬសារធាតុបំពុល) ដោយសារតម្លៃនៃវត្ថុធាតុខាងក្រៅ មិនជាប់ទាក់ទងជាមួយថ្លៃដាក់លក់ទេ ប៉ុន្តែគឺបរិមាណនៃការប្រើប្រាស់ឯណោះទេ។ ទោះជាយ៉ាងណាក៏ដោយ ពន្ធគយជាក់លាក់មានដែនកំណត់ រួមទាំងការខ្វះខាតការកែតម្រូវដោយស្វ័យប្រវត្តិជាមួយនឹងថ្លៃដាក់លក់ ហើយដូច្នេះ អតិផរណា និងចំណូលពន្ធអាចថយចុះតាមទិដ្ឋភាពជាក់ស្តែង លុះត្រាតែអត្រាពន្ធត្រូវបានដាក់លិបិក្រម។ ឯកសារនានាបានឱ្យដឹងថា ពន្ធគយជាក់លាក់ដាក់បន្ទុកពន្ធដូចគ្នាទៅលើទំនិញគុណភាព(ថ្លៃ)ខ្ពស់ និងទំនិញដែលមានគុណភាព(ថ្លៃ)ទាប ដែលបណ្តាលឱ្យប្រព័ន្ធពន្ធមានដំណើរការធាក់ថយទៅវិញ។

**រូប S.12 ៖ កម្ពុជាមានអត្រា VAT ក្នុងចំណោមអត្រាទាបបំផុតបើធៀបនឹងបណ្ដាប្រទេសមានចំណូលមធ្យមកម្រិតទាប**




*ប្រភព៖ ពិនិត្យដោយបុគ្គលិកធនាគារពិភពលោក។*

ពោលឱ្យចំ គឺមូលដ្ឋានអាករពិសេស និងជាពិសេសវិធីសាស្ត្រផ្សេងៗគ្នាសម្រាប់ការគណនាអាករពិសេសលើទំនិញនាំចូល និងផលិតក្នុងស្រុក ក៏ដូចជាទំនោររបស់ទំនិញនាំចូលចង់បានមូលដ្ឋានពន្ធទាបជាងទំនិញផលិតក្នុងស្រុក[29] អត្រាអាករពិសេសទាប និងមានអថេរច្រើន និងបញ្ហាប្រឈមសម្រាប់អាជីវកម្មដោយសារការផ្លាស់ប្តូរអត្រាអាករពិសេសញឹកញាប់។ ខណៈដែលកម្ពុជាមិនមានអាករពិសេសជាក់លាក់នាពេលបច្ចុប្បន្ន ពន្ធជាក់លាក់ត្រូវបានអនុវត្តជាផ្នែកមួយនៃពន្ធគយលើប្រេងសាំង និងប្រេងម៉ាស៊ូត ហើយសេវាប្រថាប់ត្រាពន្ធលើថ្នាំជក់ គឺជាពន្ធជាក់លាក់តាមព្រឹត្តន័យ។ ទោះបីជាទាំងពីរមុខខាងលើនេះមិនមែនជាអាករពិសេសក៏ដោយ វានៅតែបង្ហាញពីលទ្ធភាពថា កម្ពុជាគួរអនុវត្តប្រព័ន្ធពន្ធណាមួយ - ជាប្រព័ន្ធពន្ធជាក់លាក់ ឬប្រព័ន្ធពន្ធចម្រុះ។

# ៣. ផលជះនៃការចំណាយផ្នែកអនុលោមភាពពន្ធដារ ទៅលើបរិយាកាសធុរកិច្ច

**ក្រុមហ៊ុននៅកម្ពុជាភាគច្រើនចាត់ទុកពន្ធ - ទាំងអត្រាពន្ធ និងការគ្រប់គ្រងកិច្ចការពន្ធ - ជាឧបសគ្គកំពូលក្នុងការធ្វើអាជីវកម្ម។**[30] វត្តមាននៃក្រុមហ៊ុនក្រៅផ្លូវការក៏ត្រូវបានចាត់ទុកថាជាឧបសគ្គកំពូលផងដែរ។ អត្រាពន្ធ និងការគ្រប់គ្រងកិច្ចការពន្ធ - ដែល បន្ទាប់ពីក្រុមហ៊ុនក្រៅផ្លូវការ ជា "ឧបសគ្គធំជាងគេ" តាមលំដាប់ទីពីរ និងទីបី នៅក្នុងការធ្វើអាជីវកម្មនៅកម្ពុជា - បានក្លាយជាក្តីកង្វល់ធំ ហើយអត្រាពន្ធគឺជាកង្វល់កាន់តែធំមួយទៀតសម្រាប់ក្រុមហ៊ុនកម្ពុជា ជាងដៃគូប្រកួតប្រជែងរបស់ពួកគេ។ ការគ្រប់គ្រងកិច្ចការពន្ធច្រើនតែត្រូវបានចាត់ទុកថាជាឧបសគ្គក្នុងការធ្វើអាជីវកម្មដោយក្រុមហ៊ុនដែលនៅឆ្ងាយពីរាជធានី និងដោយក្រុមហ៊ុនផលិតកម្ម (៦៧ ភាគរយ) ជាពិសេសក្រុមហ៊ុនកាត់ដេរ (៧៥ ភាគរយ) ក្រុមហ៊ុនផលិតសម្រាប់ការនាំចេញ (៧៧ ភាគរយ) ក្រុមហ៊ុនធំ (៧៤ ភាគរយ) និងក្រុមហ៊ុនខ្នាតមធ្យម (៧១ ភាគរយ)។ ផ្ទុយទៅវិញ ការគ្រប់គ្រងកិច្ចការពន្ធ មិនសូវជាការព្រួយបារម្ភប៉ុន្មានទេសម្រាប់ក្រុមហ៊ុនសេវាកម្ម (លើកលែងក្រុមហ៊ុនលក់រាយ) ក្រុមហ៊ុនផលិតសម្រាប់ក្នុងស្រុក និងក្រុមហ៊ុនខ្នាតតូច។ លំនាំស្រដៀងគ្នានេះត្រូវបានគេសង្កេតឃើញក្នុងចំណោមក្រុមហ៊ុនអំពីអត្រាពន្ធ។

**កង្វល់អំពីគោលនយោបាយពន្ធ និងការគ្រប់គ្រងកិច្ចការពន្ធនៅកម្ពុជា ទំនងជាបណ្ដាលមកពីបន្ទុកនៃថ្លៃចំណាយនៅក្នុងការអនុលោមតាមបទប្បញ្ញត្តិពន្ធ អមជាមួយការបង់លុយក្រៅផ្លូវការញឹកញាប់ ជាជាងបង់តាមអត្រាស្របច្បាប់។** អត្រាពន្ធស្តង់ដាលើប្រាក់ចំណូលសាជីវកម្មនៅកម្ពុជា គឺ ២០ភាគរយ ដែលជារួមមានភាពប្រហាក់ប្រហែលស្របតាមមធ្យមភាគក្នុងបណ្ដាប្រទេសអាស៊ាន (២១ ភាគរយ) និងដៃគូក្នុងតំបន់ ដែរ។ ដូចគ្នានេះដែរ អត្រាពន្ធលើតម្លៃបន្ថែមក៏ស្ថិតក្នុងចំណោមប្រទេសដែលមានចំណូលមធ្យមកម្រិតទាបបំផុតផងដែរ (រូប S.12)។ ទោះជាយ៉ាងណាក៏ដោយ ការស្ទង់មតិជាមួយក្រុមហ៊ុននៅកម្ពុជា បង្ហាញថា ការគ្រប់គ្រងកិច្ចការពន្ធមានភាពស្មុគស្មាញ និងបង់ចំណាយច្រើន (ទាំងពេលវេលា និងថវិកា)។ ត្រង់នេះមិនឆ្លុះបញ្ចាំងពីការចំណាយផ្ទាល់នៃកាតព្វកិច្ចចាំបាច់នោះទេ ប៉ុន្តែជាបន្ទុកដ៏ធំផ្នែករដ្ឋបាលសម្រាប់ក្រុមហ៊ុន និងអត្រាប្រេវ៉ាឡង់នៃការទូទាត់ក្រៅផ្លូវការ។ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនដទៃក្នុងតំបន់ ក្រុមហ៊ុននៅកម្ពុជាបានឱ្យដឹងថា (i) ពួកគេប្រឈមនឹងលទ្ធភាពខ្ពស់ក្នុងការដែលត្រូវបានមន្ត្រីពន្ធដារចុះមកសួរនាំ ឬធ្វើអធិការកិច្ចនៅទីស្នាក់ការ ហើយថ្មីៗនេះកាន់តែញឹកញាប់; (ii) ការចុះមកសួរនាំរបស់មន្ត្រីពន្ធដារមានចំនួនកាន់តែច្រើនឡើង; និង (iii) មានលទ្ធភាពច្រើន ដែលមន្ត្រីក្នុងកិច្ចប្រជុំពន្ធដារទាំងនេះ រំពឹងទុក ឬស្នើសុំការបង់ប្រាក់ក្រៅផ្លូវការ ឬអំណោយផ្សេងៗ ហើយ ៣៦ ភាគរយនៃក្រុមហ៊ុននិយាយថាគេបានបង់ប្រាក់ទៅឱ្យមន្ត្រីទាំងនោះ។

29 ទោះបីជានេះអាចបណ្ដាលមកពីការប្រកួតប្រជែងថ្លៃជាអន្តរជាតិក៏ដោយ ទំនិញនាំចូលនៅតែទាក់ទាញបានអាករពិសេសទាប ជាងទំនិញផលិតក្នុងស្រុក។

30 ធនាគារពិភពលោក 2024b។

**រូប S.13 ៖ ចំនួនម៉ោងដែលបានចំណាយលើការអនុលោមតាមកាតព្វកិច្ចពន្ធប្រចាំឆ្នាំ**




ប្រភព៖ ការស្ទង់មតិសហគ្រាសរបស់ធនាគារពិភពលោក ឆ្នាំ២០២៣។
កំណត់សម្គាល់៖ ចំនួនម៉ោងមធ្យមដែលបានរាយការណ៍, EAP = អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក

**បន្ទុកនៃអនុលោមភាពពន្ធដារ គឺមួយផ្នែកដោយសារក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ដែលបានកំណត់ការរំពឹងទុកខ្ពស់ផ្នែកអនុលោមភាព និងតម្រូវការឱ្យមានត្រួតពិនិត្យដ៏តឹងរឹង។** ច្បាប់ពន្ធដារ បានផ្តល់សិទ្ធិអំណាចយ៉ាងទូលំទូលាយដល់អាជ្ញាធរពន្ធដារក្នុងការត្រួតពិនិត្យប្រតិបត្តិការទូទាត់ឡើងវិញ និងអនុវត្តទណ្ឌកម្មកាន់តែតឹងរ៉ឹង រួមទាំងការផាកពិន័យជាប្រាក់យ៉ាងច្រើនសន្ធឹកសន្ធាប់ផងដែរ។ កត្តានេះ បង្កើនភាពមិនប្រាកដប្រជាដល់កាតព្វកិច្ចពន្ធរបស់អ្នកជាប់ពន្ធ។ ផ្ទុយទៅវិញ ច្បាប់មានយន្តការច្បាស់លាស់តិចតួចណាស់សម្រាប់ការពារអ្នកជាប់ពន្ធដែលបង្កើតឱ្យមានភាពមិនប្រាកដប្រជា ហើយក្រុមហ៊ុនចេះតែព្យាយាមបកស្រាយច្បាប់ និងប្រឹងបំពេញតាមលក្ខខណ្ឌតម្រូវដែលត្រូវបានពង្រីកធំឡើងៗ។ ការណ៍នេះអាចបង្កើនចំណាយថ្លៃដើមទៅលើការគ្រប់គ្រងកិច្ចសន្យា រក្សាកំណត់ត្រា និងរៀបចំរបាយការណ៍។ ការសង្កត់ធ្ងន់នៃបទប្បញ្ញត្តិទៅលើការត្រួតពិនិត្យសព្វបែបយ៉ាង ទំនងជាកំពុងធ្វើឱ្យភាពមិនច្បាស់លាស់ និងចំណាយថ្លៃដើមរបស់ធុរកិច្ចទៅលើអនុលោមភាពពន្ធ កាន់តែកើនឡើងថែមទៀត។ របាយការណ៍ B-Ready របស់ធនាគារពិភពលោក បានបញ្ជាក់អំពីចំណុចនេះ ដោយក្នុងនោះ កម្ពុជាទទួលបានពិន្ទុ ៥០ (ក្នុងចំណោម ១០០) លើគុណភាពនៃបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលជាពិន្ទុទាបជាងប្រទេសជិតខាងក្នុងតំបន់អាស៊ាន ដូចជា ឥណ្ឌូណេស៊ី (៦៦,៧) ហ្វីលីពីន (៥៦,៧) និងសិង្ហបុរី (៧០,៤)។[31]

**នៅពេលដែលមានការរំពឹងច្រើនពេកអំពីកាតព្វកិច្ចអនុលោមភាពពន្ធ វាអាចធ្វើឱ្យកើនឡើងនូវចំណាយថ្លៃប្រតិបត្តិការសម្រាប់ធុរកិច្ចដែលបានចុះបញ្ជីក្នុងវិស័យផ្លូវការ និងអាចធ្វើឱ្យក្រុមហ៊ុនទៀតផងរារែកមិនចង់ចុះបញ្ជីផ្លូវការ។** ស្ថានភាពបែបនេះ អាចធ្វើឱ្យក្រុមហ៊ុនក្នុងវិស័យផ្លូវការចាញ់ប្រៀបគេ យ៉ាងហោចណាស់ក៏ក្នុងរយៈពេលខ្លីដែរ នៅពេលដែលក្រុមហ៊ុនដែលជាគូប្រជែងដែលក្រៅផ្លូវការ តែងតែចំណាយតិចជាងនៅក្នុងការធ្វើអាជីវកម្ម។ ចំណាយថ្លៃដើមទាំងនេះធ្វើឱ្យគម្លាតរវាងប្រតិបត្តិការក្នុងប្រព័ន្ធផ្លូវការ និងក្រៅផ្លូវការ រីកកាន់តែធំ និងធ្វើឱ្យក្រុមហ៊ុនខ្លះមិនចង់ចុះបញ្ជី ដែលជាហេតុនាំឱ្យចំណូលពន្ធថយចុះ និងការផ្តល់សេវាសាធារណៈមិនបានល្អ។ ក្នុងករណីដែលអាក្រក់ជាងនេះទៅទៀត អាជីវកម្មខ្លះអាចនឹងចាកចេញពីវិស័យផ្លូវការ ទៅរកស៊ីក្រៅផ្លូវការវិញ ដើម្បីចៀសវាងបន្ទុកបង់ពន្ធ។ ការសឹករេចរឹលនៃមូលដ្ឋានវិស័យផ្លូវការនេះ នាំឱ្យចំណូលពន្ធធ្លាក់ចុះ ការផ្តល់សេវាសាធារណៈមិនសូវបានល្អ និងការប្រកួតប្រជែងមិនស្មើភាព។

**ជាក់ស្តែង ៤១ ភាគរយនៃក្រុមហ៊ុនចុះបញ្ជី នៅក្នុងការស្ទង់មតិសហគ្រាសរបស់ធនាគារពិភពលោក បានចាត់ទុកវិស័យក្រៅផ្លូវការថាជាឧបសគ្គធំបំផុតក្នុងការធ្វើអាជីវកម្ម ដោយភាគច្រើនគេបានលើកឡើងពីការប្រតិបត្តិរបស់ដៃគូប្រកួតប្រជែងក្រៅផ្លូវការ។** ក្តីកង្វល់ទាំងនេះ ជាទូទៅមានសភាពកាន់តែធ្ងន់ធ្ងរសម្រាប់ក្រុមហ៊ុនតូចៗ និងក្រុមហ៊ុនមានលក្ខណៈមិនសូវស្មុគស្មាញដែលទំនងជាត្រូវប្រកួតប្រជែងដោយផ្ទាល់ជាមួយក្រុមហ៊ុនក្រៅផ្លូវការ។ ការស្ទង់មតិមួយទៅលើក្រុមហ៊ុនក្នុងវិស័យក្រៅផ្លូវការនៅតាមទីក្រុងចំនួនបួន ក្នុងប្រទេសកម្ពុជា បានបញ្ជាក់បន្ថែមពីចំណុចនេះ ដោយអ្នកឆ្លើយសំណួរជាងពាក់កណ្តាលដែលជាអាជីវកម្មក្រៅផ្លូវការ បានលើកឡើងថា "មិនសូវឃើញអាជ្ញាធរពន្ធដារ" មករកទេ ដោយហេតុថាពួកគេ ដាក់អាជីវកម្ម ឬធ្វើសកម្មភាពរកស៊ីនៅក្នុងបរិវេណផ្ទះរបស់ពួកគេ។[32]

**ថ្លៃចំណាយទៅលើអនុលោមភាពពន្ធ មានភាពខុសគ្នាខ្លាំងក្នុងចំណោមក្រុមហ៊ុននៅកម្ពុជា ដោយធុរកិច្ចដែលបរទេសកាន់កាប់ និងក្រុមហ៊ុននាំចេញ ត្រូវចំណាយពេលវេលាក្នុងការអនុលោមតាមបទប្បញ្ញត្តិពន្ធ ច្រើនជាងសហគ្រាសតូចៗ និងសហគ្រាសដែលផ្តោតលើទីផ្សារក្នុងស្រុក (រូប S.13)។** ចំនួនម៉ោងអនុលោមភាពដែលក្រុមហ៊ុនមួយចំនួនបានរាយការណ៍ឱ្យដឹងថាបានចំណាយ ទោះបីជាមិនមែនជាការវាស់វែងពេញ

31 សម្រាប់ទិន្នន័យ និងវិធីសាស្ត្រក្នុងរបាយការណ៍ B-Ready សូមចូលមើល

32 ធនាគារពិភពលោក 2024c។

លេញអំពីថ្លៃចំណាយក៏ដោយ ក៏វាជាការប៉ាន់ប្រមាណមួយមានប្រយោជន៍ដែរ នៅពេលដែលគ្មានទិន្នន័យលម្អិតអំពីថ្លៃចំណាយ។ ក្រុមហ៊ុនធំៗចំណាយពេលជិតពីរដងច្រើនជាងក្រុមហ៊ុនទំហំមធ្យម ទៅលើកិច្ចការពាក់ព័ន្ធអនុលោមភាពពន្ធ។ ថ្វីដ្បិតតែថ្លៃចំណាយអនុលោមភាពប្រែប្រួលទៅតាមទំហំ និងប្រភេទក្រុមហ៊ុន ដោយសារតែភាពស្មុគស្មាញនៃប្រតិបត្តិការមានកម្រិតខុសគ្នា, គម្លាតរវាងក្រុមហ៊ុនធំ និងក្រុមហ៊ុនតូចនៅកម្ពុជា គឺធំជាងគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងបណ្ដាសេដ្ឋកិច្ចផ្សេងទៀតនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក។ ក្រុមហ៊ុនដែលមានកម្មសិទ្ធិបរទេស ឬដែលធ្វើសកម្មភាពនាំចេញដោយផ្ទាល់ បានឱ្យដឹងថា ពួកចំណាយពេលច្រើនជាងមែនទែន (ពី៣៦០ ទៅ ៣៦៩ ម៉ោង) បើធៀបទៅនឹងក្រុមហ៊ុនដែលមានកម្មសិទ្ធិក្នុងស្រុក (៧០ ម៉ោង) និងក្រុមហ៊ុនដែលមិនមែនជាអ្នកនាំចេញ (៨៥ ម៉ោង)។ បន្ទុកអនុលោមភាពនេះ បង្កឱ្យមានវិការសេដ្ឋកិច្ចទាំងដោយផ្ទាល់ និងដោយប្រយោល។ អនុលោមភាពដែលមិនស្មើភាព និងច្រើនឡើងៗ បង្កើតភាពមិនប្រាកដប្រជា បង្កើនហានិភ័យកំហុសឆ្គង និងអាចនាំឱ្យមានការជាប់កាតព្វកិច្ចបង់ពន្ធជាក់ស្ដែងកាន់តែខ្ពស់ បើធៀបទៅនឹងក្រុមហ៊ុនដែលរងបន្ទុកអនុលោមភាពទាបជាង។ ជាចុងក្រោយ បន្ទុកអនុលោមភាពដែលមិនស្មើភាពគ្នាធ្វើឱ្យខូចនូវការប្រកួតប្រជែងស្មើភាព ក្នុងនោះក្រុមហ៊ុនធំៗ ក្រុមហ៊ុនផ្លូវការ និងក្រុមហ៊ុនដែលប្រកបអាជីវកម្មដោយចំហ អាចរងបន្ទុកចំណាយកាតព្វកិច្ចពន្ធច្រើនហួសប្រមាណ ធៀបទៅនឹងអាជីវកម្មតូចៗ ឬអាជីវកម្មក្រៅផ្លូវការ ដែលជាញឹកញាប់ ជាប់កាតព្វកិច្ចអនុលោមពន្ធជាក់ស្ដែងទាបជាង។ ការណ៍នេះនាំឱ្យមានវិការភាពនៅក្នុងការប្រកួតប្រជែង ដែលធ្វើឱ្យក្រុមហ៊ុនមួយចំនួនមិនចង់ចូលក្នុងប្រព័ន្ធផ្លូវការ និងអាចរារាំងការវិនិយោគពីសំណាក់ក្រុមហ៊ុនដែលមានដើមទុនធំជាង ក្នុងការចូលរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងចំណូលពន្ធ។ ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារ បានចាត់វិធានការធ្វើឌីជីថលូបនីយកម្មសេវាកម្មស្នូល ដូចជាការចុះបញ្ជី ការដាក់លិខិតប្រកាស និងការបង់ប្រាក់។ កំណែទម្រង់ទាំងនេះមានគោលបំណងកាត់បន្ថយការប្រាស្រ័យទាក់ទងដោយផ្ទាល់ សម្រួលដល់ដំណើរការអនុលោមភាព និងអាចជួយកាត់បន្ថយបន្ទុកចំណាយលើអនុលោមភាពបានខ្លះដែរ។

**ទោះបីជាវាជួយជំរុញការប្រមូលចំណូលពន្ធក៏ដោយ ការធ្វើសវនកម្មញឹកញាប់ពេកអាចកាន់តែធ្វើឱ្យមានភាពស្មុគស្មាញ និងបង្កើនភាពមិនអាចទាយទុកជាមុនបាននៃប្រព័ន្ធពន្ធដារ ដែលរួមចំណែកបង្កបញ្ហាប្រឈមដល់អនុលោមភាពពន្ធរបស់ធុរកិច្ច។** ចាប់តាំងពីឆ្នាំ២០១៨ ចំនួនសវនកម្មបានកើនឡើងយ៉ាងខ្លាំង។ តាមការប៉ាន់ប្រមាណខ្លះ សវនកម្មដែលធ្វើឡើងដោយនាយកដ្ឋានសវនកម្មអ្នកជាប់ពន្ធធំ និងនាយកដ្ឋានសវនកម្មសហគ្រាស បានកើនឡើងយ៉ាងរហ័សពី ៩០៧ ដល់ ៣ ៨៨៣ លើក ក្នុងឆ្នាំ ២០២១។[33] ទោះបីជាមិនមានចំនួនពិតប្រាកដនៃអ្នកជាប់ពន្ធធំដែលបានចុះបញ្ជីក៏ដោយ គេបានប៉ាន់ប្រមាណថាវាមានចំនួនប្រហែល ៤ ០០០ ក្រុមហ៊ុន ដែលកើនឡើងពី ៣ ៧៤៤ នៅក្នុងឆ្នាំ ២០១៧[34] ដែលសបញ្ជាក់ឱ្យឃើញថាសកម្មភាពសវនកម្ម មានភាពញឹកញាប់ខ្លាំង នៅក្នុងផ្នែកនេះ។ ក្នុងឆ្នាំ ២០១៩ ចំណូលដែលបានពីសវនកម្មពន្ធ បានរួមចំណែកប្រមាណ ២៨ ភាគរយនៃចំណូលពន្ធសរុប ដែលនេះបង្ហាញពីតួនាទីដ៏សំខាន់របស់សវនកម្មពន្ធ នៅក្នុងការកៀរគរចំណូល។ ទោះបីជាមានការកើនឡើងនៃចំនួនសវនកម្មពន្ធក៏ដោយ ប្រសិទ្ធភាពនៃដំណើរការដោះស្រាយបណ្ដឹងឧទ្ធរណ៍ហាក់ដូចជានៅមានកម្រិត ដូចដែលបានបង្ហាញតាមរយៈអត្រាទាបនៃដំណោះស្រាយដែលបានសម្រេច ដែលវាអាចធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តទៅលើភាពត្រឹមត្រូវ និងលទ្ធភាពចូលទៅប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទ។

**ភាពទន់ខ្សោយនៅក្នុងសវនកម្មពន្ធ និងការដោះស្រាយវិវាទកាន់តែធ្វើឱ្យមានបញ្ហាប្រឈមថែមទៀតនៅក្នុងអនុលោមភាពពន្ធ។** អគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការសំខាន់ៗក្នុងការងារពង្រឹងមុខងារសវនកម្មរបស់ខ្លួន និងកែលម្អនីតិវិធីសវនកម្ម។ អគ្គនាយកដ្ឋានពន្ធដារមានកម្មវិធីសវនកម្មពន្ធថ្នាក់ជាតិ ដែលគ្របដណ្ដប់លើពន្ធសំខាន់ៗទាំងអស់ និងគ្រប់ប្រភេទអ្នកជាប់ពន្ធ។ ទោះជាយ៉ាងណា គុណភាពនៃករណីសវនកម្មនីមួយៗមិនត្រូវបានពិនិត្យតាមដានទេ, ឥទ្ធិពលរបស់វាទៅលើការអនុលោមភាពក៏មិនត្រូវបានវាយតម្លៃជាប្រចាំ ហើយក៏គ្មានការប្រមូលមតិយោបល់របស់អ្នកជាប់ពន្ធ អំពីភាពវិជ្ជាជីវៈ និងសមត្ថភាពបំពេញកិច្ចរបស់សវនករ ឱ្យបានទៀងទាត់ដែរ។ ស្របគ្នានេះ ដំណើរការដោះស្រាយវិវាទពន្ធ ហាក់ដូចជានៅយឺតយ៉ាវ ហើយស្មុគស្មាញ។ កម្ពុជាទទួលបានពិន្ទុទាបនៅក្នុងរបាយការណ៍ B-Ready របស់ធនាគារពិភពលោក ស្ដីពីការដោះស្រាយវិវាទសវនកម្មពន្ធ និងវិវាទពាក់ព័ន្ធ ដោយទទួលបានពិន្ទុ ៥ បើធៀបនឹង ១៤,៤ នៅឥណ្ឌូណេស៊ី, ៨,៤៤ នៅហ្វីលីពីន និង ៥,៦៣ នៅសិង្ហបុរី និងវៀតណាម។ ពិន្ទុទាបនេះ មានជាពិសេសនៅក្នុងផ្នែកនៃការតវ៉ាចំពោះលទ្ធផលសវនកម្ម និងរយៈពេលនៃដំណើរការសវនកម្ម។ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ អគ្គនាយកដ្ឋានពន្ធដារបានផ្ដួចផ្ដើមកំណែទម្រង់សំខាន់ៗដើម្បីដោះស្រាយបញ្ហាទាំងនេះ រួមទាំងការដាក់ឱ្យប្រើនីតិវិធីប្រតិបត្តិការស្ដង់ដា (SOPs) ដើម្បីបង្កើនតម្លាភាព និងសង្គតិភាព, ការបង្កើតអង្គភាពសវនកម្មពន្ធពិសេសក្នុងគោលបំណងពន្លឿនការដោះស្រាយករណីស្មុគស្មាញ និងការដាក់ឱ្យអនុវត្តវិធានការដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធកែតម្រូវកំហុសក្នុងលិខិតប្រកាសពន្ធរបស់ពួកគេ ដោយមិនប្រឈមនឹងការផាកពិន័យ ឬការប្រាក់ពិន័យ។ វិធានការទាំងនេះ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយគម្លាតដែលបានលើកឡើងនៅក្នុងការស្ទង់មតិជាមួយក្រុមហ៊ុននានា។

33 Andersen Global 2024

34 មូលនិធិរូបិយវត្ថុអន្តរជាតិ ២០១៨

**រូប S.14 ៖ អត្រាភាពក្រីក្រនៅមុន និងក្រោយពេលមានអន្តរាគមន៍សារពើពន្ធ**




**រូប S.15 ៖ មេគុណជីនី (Gini) នៅមុន និងក្រោយពេលមានអន្តរាគមន៍សារពើពន្ធ នៅកម្ពុជា**




*ប្រភព៖ Karamba* et al. 2023. ការគណនារបស់ Commitment to Equity (CEQ) ដោយផ្អែកលើទិន្នន័យ CSES 2019/20។

*សម្គាល់៖ យោងតាមអនុសាសន៍បច្ចេកទេសរបស់* Commitment to Equity (CEQ), ការផ្ទេរអំណោយជាសម្ភារផ្នែកសុខាភិបាល និងអប់រំ មិនត្រូវបានរួមបញ្ចូលនៅពេលប៉ាន់ប្រមាណពីផលប៉ះពាល់លើភាពក្រីក្រឡើយ។

# ៤. សមធម៌

**សមាសភាគពន្ធរបស់កម្ពុជា ដែលពឹងផ្អែកខ្លាំងលើពន្ធប្រយោល ជាឧបសគ្គមួយដល់កិច្ចខិតខំក្នុងការកាត់បន្ថយភាពក្រីក្រ។**[35] ជារួម ប្រព័ន្ធសារពើពន្ធតាមគំរូរបស់កម្ពុជា បានធ្វើឱ្យភាពក្រីក្រកើនឡើង ២,១ ចំណុចភាគរយ ដូចបានបង្ហាញតាមរយៈការធ្វើអន្តរកម្មពីចំណូលទីផ្សារ ទៅចំណូលចំណាយបាន (រូប S.14)។[36] ការផ្ទេរប្រាក់សុទ្ធដែលបានតាមរយៈការផ្ទេរដោយផ្ទាល់ និងពន្ធផ្ទាល់លើប្រាក់ចំណូល គឺតូចពេក ដែលមិនអាចធ្វើឱ្យប្រាក់ចំណូលជាមធ្យមនៅតាមគ្រួសារមានភាពប្រសើរបានទេ ហើយដូច្នេះក៏មិនអាចកាត់បន្ថយភាពក្រីក្របានដែរ។ យ៉ាងណាក្តី ការផ្ទេរប្រាក់សុទ្ធតាមរយៈការឧបត្ថម្ភធន និងពន្ធប្រយោលលើការប្រើប្រាស់ គឺមានលក្ខណៈអវិជ្ជមាន និងមានទំហំធំ ដែលជាហេតុធ្វើឱ្យភាពក្រីក្រកើនឡើង។ និយាយម្យ៉ាងទៀត គ្រប់គ្រួសារទាំងអស់ប្រឈមនឹងទំនិញឡើងថ្លៃកាន់តែខ្ពស់ដោយសារពន្ធប្រយោល។ សម្រាប់គ្រួសារក្រីក្រ និងគ្រួសារនៅក្បែរបន្ទាត់ភាពក្រីក្រ កាលណាទំនិញឡើងថ្លៃកាន់តែខ្ពស់ វាបានកាត់បន្ថយលទ្ធភាពទិញរបស់ពួកគេ រហូតដល់អាចកាត់បន្ថយការចំណាយសុទ្ធរបស់ពួកគេ ឱ្យនៅក្រោមបន្ទាត់ភាពក្រីក្រទៅទៀត។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធសារពើពន្ធទាំងមូលបានកាត់បន្ថយវិសមភាព។ នៅពេលដែលពន្ធផ្ទាល់ និងការផ្ទេរដោយផ្ទាល់ត្រូវបានពិចារណា មេគុណជីនី (Gini) បានធ្លាក់ចុះបន្តិចមកនៅត្រឹម ៣២,២ ភាគរយនៃចំណូលចំណាយបាន។ ពន្ធប្រយោល និងការឧបត្ថម្ភធន មានឥទ្ធិពលតិចតួច ហើយជាមួយនឹងការពិចារណាលើចំណុចទាំងនេះ មេគុណជីនីនៃចំណូលចំណាយបាន នៅតែស្ថិតក្នុងកម្រិត ៣២,២ ភាគរយ (រូប S.15)។[37]

**កម្រិតផ្សេងៗគ្នានៃកត្តាខាងក្រៅ (externalities) និងកត្តាខាងក្នុង (internalities) មិនត្រូវបានកំណត់ដៅឱ្យបានល្អនៅក្នុងរចនាសម្ព័ន្ធពន្ធគយបច្ចុប្បន្នទេ ដោយសារវាមិន បានគិតបញ្ចូលបរិមាណជាតិអាល់កុល ជាតិស្ករ ឬកម្រិតនៃការបញ្ចេញឧស្ម័នពុល។** ឧទាហរណ៍ អត្រាពន្ធគយ គឺប្រហាក់ប្រហែលគ្នាសម្រាប់ផលិតផលគ្រឿងស្រវឹងផ្សេងៗគ្នា ទោះបីជាវាមានបរិមាណជាតិអាល់កុលខុសគ្នាច្រើនក៏ដោយ។ ក្របខ័ណ្ឌដូចគ្នានេះត្រូវបានអនុវត្តទៅលើឥន្ធនៈដែលមានកម្រិតនៃការបញ្ចេញឧស្ម័នពុលខុសៗគ្នា និងចំពោះភេសជ្ជៈផ្អែម (SSBs) ដែលមានបរិមាណជាតិស្ករខុសៗគ្នា។ លើសពីនេះ ពន្ធតាមតម្លៃ (ad valorem tax) មិនកំណត់គោលដៅលើផលប៉ះពាល់ខាងក្រៅ និងខាងក្នុងបានល្អទេ ព្រោះវាបង្កប់ន័យមិនត្រឹមត្រូវថា ផលិតផលដែលមានតម្លៃថោក បង្កផលប៉ះពាល់ខាងក្រៅ និងខាងក្នុង តិចជាងផលិតផលដែលមានតម្លៃថ្លៃជាង។

**ជាលទ្ធផល ការប្រើប្រាស់ថ្នាំជក់ គ្រឿងស្រវឹង និងភេសជ្ជៈផ្អែម (SSB) នៅកម្ពុជា បង្កអត្រាមរណភាព និងជំងឺតម្កាត់ឡើងអត្រាគួរឱ្យកត់សម្គាល់។** ករណីនេះអាចជះផលធ្ងន់ធ្ងរមែនទែនទៅលើគ្រួសារក្រីក្រ ដោយធ្វើឱ្យគ្រួសារដែលមានចំណូលទាប ត្រូវរងបន្ទុកចំណាយលើការថែទាំសុខភាពកាន់តែខ្លាំងឡើង។ អត្រាមរណភាព និងជំងឺតម្កាត់នៅកម្ពុជា ដោយសារការប្រើប្រាស់ថ្នាំជក់ និងគ្រឿងស្រវឹង មានកម្រិតខ្ពស់ជាងនៅបណ្តាប្រទេសដែលមានសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា

35 Karamba et al. 2023។

36 ការវិភាគនេះផ្អែកលើទិន្នន័យពីមុនមានការរាតត្បាតនៃជំងឺកូវីដ-១៩។ ស្ថិរភាពពាក់ព័ន្ធគោលនយោបាយដែលជាមូលដ្ឋាន បង្ហាញថាលទ្ធផលនៃការវិភាគនេះនៅតែមានភាពពាក់ព័ន្ធជារួមនាពេលបច្ចុប្បន្ន។

37 ការផ្ទេរជា “សម្ភារ” (in-kind) ពីវិស័យសុខាភិបាល និងអប់រំ ផ្ទុយទៅវិញ មានឥទ្ធិពលធំបំផុតលើវិសមភាព ដោយចំណូលចុងក្រោយមានមេគុណជីនី ៣១,៤ ភាគរយ។ ត្រង់នេះឆ្លុះបញ្ចាំងពីអង្គហេតុដែលថា ការផ្ទេរជាសម្ភារ ជាចំណែកដ៏សំខាន់មួយនៃប្រាក់ចំណូលមុនពេលគិតពន្ធ ហើយផ្តល់អត្ថប្រយោជន៍ដល់គ្រួសារដែលមានចំណូលទាបច្រើនជាង បើធៀបនឹងគ្រួសារនៅផ្នែកខាងលើនៃការបែងចែកប្រាក់ចំណូល។

**រូប S.16 ៖ អត្រាមរណៈ (ផ្ទាំង A) និងឆ្នាំអាយុដែលបាត់បង់ដោយសារពិការភាព (DALYs) (ផ្ទាំង B) ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំជក់ ក្នុងឆ្នាំ២០១៩**

*ផ្ទាំង A*




*ផ្ទាំង B*




*ប្រភព៖ IHME* 2019។

*សម្គាល់៖ អាស៊ីអាគ្នេយ៍* ដូចដែលបានកំណត់ដោយប្រភព រួមមានប្រទេស កម្ពុជា ឥណ្ឌូណេស៊ី ឡាវ ម៉ាឡេស៊ី ម៉ាល់ឌីវ ម៉ូរីស មីយ៉ាន់ម៉ា ហ្វីលីពីន ស៊ីស្ហែល ស្រីលង្កា ថៃ ទីម័រខាងកើត និងវៀតណាម។

(រូប S.16)។ ករណីនេះមិនដូចគ្នាទេ សម្រាប់របបអាហារដែលមានការទទួលទានភេសជ្ជៈផ្អែម (SSB) ច្រើន ហើយទោះបីជាអត្រាទាបជាងបើធៀបទៅនឹងថ្នាំជក់ និងគ្រឿងស្រវឹងក៏ដោយ ក៏គេពិបាកនឹងធ្វើការប្រៀបធៀបដែរ។ ការប្រើប្រាស់ផលិតផលជាតិផ្អែមទាំងនេះ រួមចំណែកដល់ ២៦ ភាគរយនៃការស្លាប់ទាំងអស់នៅកម្ពុជា ដែលខ្ពស់ជាងតំបន់អាស៊ីអាគ្នេយ៍ (២២ ភាគរយ) និងនៅ បណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប (១៦ ភាគរយ)។[38] កាលណាគិតបញ្ចូលឆ្នាំអាយុជីវិតដែល បាត់បង់ដោយសារពិការភាព (DALYs)[39] អាហារផ្អែមទាំងនេះរួមចំណែក ១៧ ភាគរយនៃ DALYs ទាំងអស់នៅកម្ពុជា ធៀបទៅនឹង ១៥ ភាគរយនៅតំបន់អាស៊ីអាគ្នេយ៍ និង ១០ ភាគរយនៅបណ្តាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ នៅពេលកែសម្រួលតាមចំនួនប្រជាជន ក្នុងចំណោមប្រជាជន ១០០ ០០០ នាក់ អត្រាមរណភាព និងឆ្នាំអាយុដែលបាត់បង់ដោយសារពិការភាព នៅកម្ពុជា គឺ ២៦ ភាគរយ និង ២៩ ភាគរយ រៀងខ្លួន ខ្ពស់ជាងនៅអាស៊ីអាគ្នេយ៍ និង ៦៣ ភាគរយខ្ពស់ជាងនៅបណ្តាប្រទេសមានចំណូលមធ្យមកម្រិតទាប។ អត្រាមរណភាព និងជំងឺតម្កាត់ដោយសារភេសជ្ជៈផ្អែម (SSBs) គឺនៅទាបជាងគ្រឿងស្រវឹង និងថ្នាំជក់ ប៉ុន្តែកំពុងកើនឡើងយ៉ាងឆាប់រហ័ស។

38 ការសិក្សាអំពីបន្ទុកជំងឺសកល (Global Burden of Disease Study - IHME 2019) ត្រូវបានប្រើប្រាស់ជំនួសឱ្យទិន្នន័យជាតិ ព្រោះវាផ្តល់នូវការប៉ាន់ប្រមាណដែលអាចប្រៀបធៀបបានជាសកល ជាមួយនឹងទិន្នន័យស៊េរីពេលវេលាប្រចាំឆ្នាំ ពីឆ្នាំ ១៩៩០ រហូតដល់ឆ្នាំ ២០១៩ (ជាឆ្នាំថ្មីបំផុតដែលមាន)។

39 DALYs ប៉ាន់ប្រមាណពីចំនួនឆ្នាំដែលអាចនឹងបាត់បង់ដោយសារការស្លាប់មុនអាយុ និងរួមបញ្ចូលឆ្នាំនៃជីវិតដែលមានសុខភាពល្អតែត្រូវបាត់បង់ដោយសារសុខភាពមិនល្អ ឬពិការភាព ដោយរួមបញ្ចូលទាំងអត្រាមរណភាព និងជំងឺតម្កាត់ទៅក្នុងមេទ្រិកតែមួយ។

# ៥. អនុសាសន៍គោលនយោបាយ

**ផ្នែកនេះសង្ខេបអំពីវិស័យអាទិភាពសសម្រាប់ធ្វើកំណែទម្រង់ ដើម្បីជួយដល់ប្រព័ន្ធពន្ធដារមួយដែលបង្កើនការប្រមូលចំណូល ព្រមទាំងបង្កើនភាពត្រឹមត្រូវ និងពង្រឹងបរិយាកាសធុរកិច្ច។**

**ការបង្កើនធនធានឱ្យបានច្រើន គឺជាការចាំបាច់ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ និងមហិច្ឆតាចំណាយរបស់រាជរដ្ឋាភិបាលដូចមានចែងនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ។[40]** ការពង្រឹងការប្រមូលចំណូល មានសារៈសំខាន់ណាស់ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ទូលំទូលាយរបស់កម្ពុជា ហើយជាពិសេសមានសារៈសំខាន់ក្នុងការដោះស្រាយការវិនិយោគក្នុងវិស័យសង្គម ជាពិសេសវិស័យសុខាភិបាល និងអប់រំ ដែលការចំណាយនៅតែមានកម្រិតទាប បើធៀបទៅនឹងបណ្តាប្រទេសដែលមានចំណូលមធ្យម។ ចំណូលកាន់តែខ្ពស់ជាងនេះនឹងអនុញ្ញាតឱ្យរដ្ឋាភិបាលកែលម្អគុណភាពសេវាសាធារណៈ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងកសាងភាពធន់ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ឱ្យបានកាន់តែប្រសើរឡើង។[41]

**ប្រព័ន្ធពន្ធដារដែលកាន់តែមានតម្លាភាព និងប្រសិទ្ធភាពជាងមុន មានសារៈសំខាន់ក្នុងការកែលម្អបរិយាកាសធុរកិច្ច។** ការខ្វះចន្លោះនៅក្នុងក្របខ័ណ្ឌច្បាប់ កង្វះប្រសិទ្ធភាពផ្នែករដ្ឋបាល និងការអនុវត្តច្បាប់មិនស្មើគ្នា ដែលធ្វើឱ្យមានអ្នកជាប់ពន្ធមានកង្វល់កាន់តែច្រើនអំពីអនុលោមភាពពន្ធ ប៉ុន្តែមិនផ្តល់កិច្ចការពារ

40 យុទ្ធសាស្ត្របញ្ចកោណមានគោលបំណង ៥៖ (១) រក្សាកំណើនសេដ្ឋកិច្ច, (២) បង្កើតការងារបន្ថែម, (៣) កាត់បន្ថយភាពក្រីក្រ, (៤) ពង្រឹងសមត្ថភាពអភិបាលកិច្ច និងកែលម្អគុណភាពស្ថាប័នសាធារណៈ, និង (៥) ធានាការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយចីរភាព។

41 ធនាគារពិភពលោក ២០២៣។

**រូប S.17 ៖ ផលចំណេញដែលអាចបានពីកំណែទម្រង់អាករលើតម្លៃបន្ថែម (VAT)**




*ប្រភព៖ ការគណនារបស់បុគ្គលិកធនាគារពិភពលោកដោយប្រើទិន្នន័យរបាយការណ៍អង្កេតសេដ្ឋកិច្ច-សង្គមកម្ពុជា* ២០១៩/២០ និងទិន្នន័យសារពើពន្ធឆ្នាំ ២០១៩។

គ្រប់គ្រាន់ដល់អ្នកពួកគេ កាន់តែបង្កឱ្យមានភាពមិនប្រាកដប្រជា និងបង្កើនចំណាយថ្លៃដើមនៅក្នុងការធ្វើអាជីវកម្ម។ កិច្ចខិតខំធ្វើកំណែទម្រង់ដែលពង្រឹងភាពត្រឹមត្រូវផ្នែករដ្ឋបាល ពង្រីកមូលដ្ឋានពន្ធ និងកែលម្អនូវភាពទស្សន៍ទាយបានរបស់បទប្បញ្ញត្តិ អាចជួយលើកកម្ពស់ទំនុកចិត្តរបស់វិស័យឯកជន ជំរុញការធ្វើអាជីវកម្មផ្លូវការ និងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្នថែមទៀត។

**ប្រព័ន្ធពន្ធដារត្រឹមត្រូវ និងសមធម៌ គឺចាំបាច់សម្រាប់ការពង្រឹងកំណើនដែលមានមូលដ្ឋានទូលំទូលាយ។** រចនាសម្ព័ន្ធពន្ធដារបច្ចុប្បន្នរបស់កម្ពុជា ដាក់បន្ទុកធ្ងន់គួរសមទៅលើក្រុមគ្រួសារដែលមានចំណូលទាប តាមរយៈការពឹងផ្អែកលើការបង់ពន្ធប្រយោល។ ការពង្រីកតួនាទីការបង់ពន្ធផ្ទាល់ និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីកត្តាខាងក្រៅទៅលើសុខភាព គឺជាជំហានដ៏សំខាន់ដើម្បីលើកកម្ពស់សមធម៌ កសាងទំនុកចិត្តក្នុងស្ថាប័ន និងពង្រឹងភាពស្របច្បាប់នៃប្រព័ន្ធពន្ធដារ។

**ពន្ធប្រយោលនឹងបន្តនៅជាប្រភពចំណូលដ៏សំខាន់ក្នុងរយៈពេលខ្លី។** ដើម្បីបំពេញតម្រូវការផ្នែកអភិវឌ្ឍន៍ និងចំណាយបន្ទាន់ អាជ្ញាធរអាចផ្ដោតលើកំណែទម្រង់ពន្ធប្រយោល។ ធនធានដែលចាំបាច់សម្រាប់ជួយសម្រាលបន្ទុកធ្ងន់ធ្ងររបស់គ្រួសារក្រីក្រ មានចម្រៀកមួយតូចប៉ុណ្ណោះ នៃទំហំពន្ធដែលរដ្ឋាភិបាលនឹងប្រមូលបាន តាមរយៈកំណែទម្រង់ដែលបានស្នើឡើង។ ប្រសិទ្ធភាពក្នុងបទពិសោធន៍ពីមុនក្នុងជំនួយសង្គមពេលមានការរាតត្បាតកូវីដ-១៩ អាចដើរតួជាចំណុចយោងមួយសម្រាប់ចាត់វិធានការរៀបចំសារពើពន្ធឡើងវិញ។ ក្នុងពេលជាមួយគ្នានេះ កម្ពុជាគួរផ្តោតលើការបង្កើតធាតុផ្សំមូលដ្ឋានដើម្បីជួយសម្រួលពន្ធលើប្រាក់ចំណូលដែរ។ ការណ៍នេះនឹងបង្កលក្ខណៈឱ្យប្រទេសអាចធ្វើអន្តរកម្មបន្តិចម្តងៗឆ្ពោះទៅពឹងផ្អែកលើពន្ធផ្ទាល់ច្រើនជាងពេលបច្ចុប្បន្ន។ មានវិធានការជាច្រើនដែលកម្ពុជាអាចអនុវត្តបានតាមរយៈកំណែទម្រង់បន្ត ដូចជា៖

ក. កែសម្រួលឡើងវិញ នូវអត្រាអាករលើតម្លៃបន្ថែម (VAT) ការលើកលែងពន្ធ និងអត្រាពន្ធសូន្យ
ខ. ដាក់ឱ្យប្រើពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) ពង្រីកមូលដ្ឋានគិតពន្ធនៃការបង់ពន្ធតាមចំណូលរកបាន (PAYE) និងសម្រួលប្រាក់ឧបត្ថម្ភឱ្យមានប្រសិទ្ធភាព
គ. ការធ្វើសនិទានកម្មលើការលើកទឹកចិត្តផ្នែកពន្ធ
ឃ. កំណែទម្រង់ពន្ធពិសេសជាក់លាក់ ឬប្រព័ន្ធចម្រុះ និងដាក់ឱ្យប្រើការចំឡើងពន្ធលើគ្រឿងស្រវឹង និងថ្នាំជក់ ដោយយកតាមលំនាំបន្ទាត់គោលដែលធ្លាប់បានអនុវត្តនៅតាមបណ្ដាប្រទេសមានចំណូលមធ្យម។

**ដើម្បីបង្កើនប្រាក់ចំណូលបានលឿន និងមានប្រសិទ្ធភាពដោយបង្កផលប៉ះពាល់តិចតួចបំផុតទៅលើកំណើន អាជ្ញាធរអាចពិចារណាដំឡើងអត្រាពន្ធអាករលើតម្លៃបន្ថែម ពីកម្រិតបច្ចុប្បន្ន និងធ្វើសនិទានកម្មនៃការលើកលែងពន្ធ និងការប្រើអត្រាពន្ធសូន្យក្នុងស្រុក (រូប S.17)។** អត្រាអាករលើតម្លៃបន្ថែម ១០ ភាគរយនៅកម្ពុជា គឺអាចប្រហាក់ប្រហែលក្នុងបណ្ដាប្រទេសអាស៊ាន ប៉ុន្តែទាបជាងប្រទេសដែលមានចំណូលមធ្យមកម្រិតទាបជាច្រើន។ ការធ្វើគំរូសាកល្បង (simulations) បង្ហាញថា ការដំឡើងអត្រាដល់ ១២ ភាគរយ ហើយកាត់បន្ថយការលើកលែងមួយចំនួន អាចបង្កើតចំណូលបានស្មើនឹង ១,៨ ភាគរយ នៃ ផ.ស.ស។ ផលប៉ះទង្គិចទៅលើភាពក្រី អាចប៉ះប៉ូវបានមកវិញតាមរយៈការផេរប្រាក់ចំគោលដៅ ដោយឈរលើបទពិសោធន៍ដែលបានអនុវត្តកន្លងមកក្នុងអំឡុងពេលមានជំងឺរាតត្បាត ដែលតាមការស្មាន មានទំហំមិនដល់ ២១ ភាគរយ ទេ នៃចំណូលដែលប្រមូលបានពេលនោះ។ កំណែទម្រង់បែបនេះនឹងធ្វើឱ្យការបែងចែកធនធានកាន់តែមានភាពប្រសើរឡើងវិញ និងលុបបំបាត់បានច្រើននូវផលប៉ះពាល់នៃគោលនយោបាយសារពើពន្ធទៅលើភាពក្រីក្រ។ សំខាន់នៅត្រង់ថា ការដំឡើងអត្រាអាករលើតម្លៃបន្ថែមណាមួយ គួរតែមានអមមកជាមួយនូវ

កំណែទម្រង់រដ្ឋបាល ដែលបង្កើនប្រសិទ្ធផលការងារ តម្លាភាព និងភាពត្រឹមត្រូវយុត្តិធម៌ ដើម្បីកុំឱ្យបញ្ហាប្រឈមពាក់ព័ន្ធអនុលោមភាពពន្ធដែលកំពុងមាន ក្លាយជាបញ្ហាហាកាន់តែធ្ងន់ធ្ងរទៅៗ ដូចបានពិភាក្សាខាងលើ។ ការកែលម្អផ្នែករដ្ឋបាលក៏អាចជួយសម្រាលផលជះមិនល្អ ពីការបង្កើនកម្រៃក្រៅផ្លូវការទៅលើអាករលើតម្លៃបន្ថែមផងដែរ។

**កម្ពុជាត្រូវរៀបចំបង្កើតប្រព័ន្ធពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗ (PIT) គ្រប់ជ្រុងជ្រោយមួយ ដើម្បីពង្រីកមូលដ្ឋានពន្ធ បង្កើនការប្រមូលចំណូល លើកកម្ពស់សមធម៌ និងពង្រឹងប្រសិទ្ធភាព និងភាពជឿទុកចិត្តបាននៃប្រព័ន្ធពន្ធដារ។** ការសាយភាយរបស់ការទូទាត់ក្រៅប្រព័ន្ធ បង្កបញ្ហាប្រឈមខ្លាំងដល់សេដ្ឋកិច្ច ដោយសារវារឹតត្បិតចំនួនបុគ្គលដែលត្រូវរួមចំណែកបង់ពន្ធលើប្រាក់ចំណូល។ ទោះយ៉ាងណា ជំហានកំណែទម្រង់សំខាន់ៗ ខាងក្រោមគួរយកទៅអនុវត្ត ដើម្បីពង្រឹងរដ្ឋបាលក្នុងរយៈពេលខ្លី និងមធ្យម សំដៅបង្កើនពន្ធលើចំណូលរបស់ពលរដ្ឋម្នាក់ៗដែលអាចប្រមូលបាន ឱ្យបានជាអតិបរមា ខណៈដែលប្រទេសកម្ពុជាបន្តអភិវឌ្ឍទៅមុខ ហើយកម្លាំងពលកម្មកាន់តែច្រើនកំពុងងាកទៅរកការងារក្នុងប្រព័ន្ធផ្លូវការមិនមែនកសិកម្មវិញ។

- ក្នុងរយៈពេលខ្លី ត្រូវកសាងមូលដ្ឋានគ្រឹះសម្រាប់ពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗឱ្យកាន់តែរឹងមាំ តាមរយៈការអភិវឌ្ឍ និងដាក់ឱ្យប្រើនូវប្រព័ន្ធអត្តលេខជាប់ពន្ធ (TIN) និងតម្រូវឱ្យមានការចុះបញ្ជីពីបុគ្គលទាំងអស់ដែលពាក់ព័ន្ធក្នុងប្រព័ន្ធពន្ធដារ។ ធ្វើការកែសម្រួលវចនាសម្ព័ន្ធអត្រាពន្ធលើប្រាក់ចំណូលដោយឈរលើការវិភាគលម្អិតអំពីការបែងចែកប្រាក់ចំណូល និងដោះស្រាយគម្លាតទិន្នន័យ តាមរយៈការពង្រីកលក្ខខណ្ឌតម្រូវសម្រាប់និយោជិតរាយការណ៍បង់ពន្ធ និងជំរុញការប្រើប្រាស់ប្រព័ន្ធដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីគាំទ្រដល់ការធ្វើសេចក្ដីសម្រេចចិត្តផ្នែកគោលនយោបាយដែលផ្អែកលើភស្តុតាង។
- ក្នុងរយៈពេលពីខ្លីទៅមធ្យម រដ្ឋាភិបាលគួរធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់ តាមរយៈការធ្វើវិសោធនកម្មច្បាប់ពន្ធដារ ដើម្បីកំណត់និយមន័យនៃប្រាក់ចំណូលរួម (Comprehensive Income) និងរៀបចំប្រភេទពន្ធ តាមរយៈការតាក់តែងច្បាប់ដោយឡែក។ ជាមួយគ្នានេះ រដ្ឋាភិបាលក៏គួរពិចារណាផងដែរ អំពីការតម្រឹមកម្រិតការលើកលែងពន្ធសម្រាប់អ្នកមានចំណូលទាប ឱ្យស្របជាមួយនឹងកម្រិតប្រាក់ចំណូលសម្រាប់ពលរដ្ឋម្នាក់ៗ ដើម្បីលើកកម្ពស់សមធម៌ ដោយត្រូវធ្វើការវាយតម្លៃយ៉ាងប្រុងប្រយ័ត្នទៅលើផលប៉ះពាល់ផ្នែកចំណូល និងការបែងចែកចំណូលឡើងវិញ។
- ក្នុងរយៈពេលមធ្យមទៅវែង រដ្ឋាភិបាលគួរមានគោលដៅដាក់ឱ្យប្រើប្រាស់ពន្ធលើប្រាក់ចំណូលរបស់ពលរដ្ឋម្នាក់ៗគ្រប់ជ្រុងជ្រោយមួយ ងាកចេញពីការលើកលែងពន្ធទៅប្រើយន្តការសម្រាលបន្ទុកពន្ធដែលមានគោលដៅជាក់លាក់ ហើយមុននឹងអនុវត្តពន្ធលើចំណេញមូលធន (capital gains tax) ត្រូវធ្វើការត្រួតពិនិត្យឱ្យបានហ្មត់ចត់លើក្របខ័ណ្ឌពន្ធអចលនទ្រព្យដែលមានស្រាប់ ដើម្បីវាយតម្លៃពីសមាហរណកម្ម និងសក្ដានុពលរួមចំណែករបស់វា ចំពោះការបង្កើតប្រព័ន្ធពន្ធដារទំនើប និងសមធម៌មួយ។

**កម្ពុជាត្រូវពង្រឹងក្របខ័ណ្ឌពន្ធលើប្រាក់ចំណូលក្រុមហ៊ុន (CIT) របស់ខ្លួន ដើម្បីពង្រឹងការប្រមូលចំណូលក្នុងស្រុក និងកាត់បន្ថយភាពស្មុគស្មាញនៅក្នុងការគ្រប់គ្រងកិច្ចការពន្ធ។** អត្រាពន្ធលើប្រាក់ចំណូលក្រុមហ៊ុន ការលើកទឹកចិត្តផ្នែកពន្ធនៅកម្ពុជា គួរត្រូវបានវាយតម្លៃរួមគ្នា ឱ្យប្រដំប្រសងទៅនឹងទម្លាប់អនុវត្តន៍អន្តរជាតិ ដែលអនុញ្ញាតឱ្យមានអភិក្រមសម្របសម្រួលមួយនៅក្នុងការលើកកម្ពស់ការវិនិយោគ និងកាតព្វកិច្ចអន្តរជាតិ។

- អាជ្ញាធរគួរអនុញ្ញាតឱ្យអាជីវកម្មទាំងអស់ ដោយមិនគិតពីទំហំ ឬសម្ព័ន្ធភាពបរទេស អាចដាក់ពាក្យសុំអនុវត្តឆ្នាំគណនេយ្យអាចបត់បែនបាន (flexible accounting years) ហើយធ្វើយ៉ាងណាឱ្យអត្រាការប្រាក់សម្រាប់ការទូទាត់ពន្ធយឺតយ៉ាវ មិនលើកទឹកចិត្តឱ្យប្រើការបង់ពន្ធយឺតយ៉ាវធ្វើជាឧបករណ៍ហិរញ្ញវត្ថុ ទេ។
- រាជរដ្ឋាភិបាលកម្ពុជា ក៏គួរពិចារណាដាក់ចេញក្របខ័ណ្ឌគោលនយោបាយដើម្បីត្រៀមខ្លួនសម្រាប់ស្តង់ដាពន្ធអប្បបរមាសកល ចូលរួមក្នុងគំនិតផ្ដួចផ្ដើមអន្តរជាតិស្ដីពីការយកពន្ធលើក្រុមហ៊ុនពហុជាតិ និងចាប់យកមកប្រើនូវលក្ខខណ្ឌវិនិច្ឆ័យមួយសាមញ្ញជាងមុនសម្រាប់ធ្វើចំណាត់ថ្នាក់អ្នកជាប់ពន្ធ ដោយផ្អែកលើចំណូល និងទម្រង់ច្បាប់។
- ដើម្បីជួយដល់សហគ្រាសខ្នាតតូច អាជ្ញាធរគួរអភិវឌ្ឍ និង អនុវត្តពន្ធរបបម៉ៅការផ្អែកលើចំណូល (turnover-based presumptive tax regime)។

**គួរតែធ្វើការវិភាគឱ្យបានគ្រប់ជ្រុងជ្រោយ និងកាន់តែស៊ីជម្រៅថែមទៀតលើចំណាយពន្ធ ដើម្បីវាយតម្លៃមើលថាតើអ្នកណាខ្លះដែលទទួលផលពីចំណូលដែលរឹបអូសបានរបស់កម្ពុជា និងថាតើខ្ទង់ចំណាយពន្ធមានប្រសិទ្ធភាពកម្រិតណាក្នុងការសម្រេចតាមគោលបំណងរបស់ខ្លួន។** វិធានការខាងក្រោមគួរតែត្រូវបានអនុវត្តដើម្បីដោះស្រាយចំណុចខ្សោយក្នុងការគ្រប់គ្រងការលើកទឹកចិត្តផ្នែកពន្ធ៖

- ក្នុងរយៈពេលខ្លី អាជ្ញាធរគួរកំណត់ ពន្យល់លម្អិតអំពីចំណាយពន្ធទាំងអស់ បង្កើតមូលទិន្នន័យអ្នកជាប់ពន្ធកណ្ដាលមួយដើម្បីជួយដល់ការសម្រេចចិត្តផ្អែកលើភស្តុតាង និងដាក់ចេញអវសានបញ្ញត្តិ (sunset clauses) និងការពិនិត្យឡើងវិញតាមកាលកំណត់សម្រាប់គ្រោងការណ៍លើកទឹកចិត្តផ្នែកពន្ធ។

- ផ្សព្វផ្សាយរបាយការណ៍ចំណាយពន្ធប្រចាំឆ្នាំ និងជំនួសការលើកទឹកចិត្តផ្អែកលើប្រាក់ចំណេញ ដោយប្រើបវិធានផ្អែកលើតម្លៃមានតម្លាភាពជាងមុន ដើម្បីពង្រឹងតម្លាភាពសារពើពន្ធថែមទៀត។
- ក្នុងរយៈពេលខ្លីទៅមធ្យម ធ្វើការពិនិត្យឡើងវិញ និងធ្វើសនិទានកម្មលើការអនុគ្រោះពន្ធ រួមជាមួយកំណែទម្រង់អត្រាពន្ធចំណូលក្រុមហ៊ុន ដើម្បីធានាថាប្រការលើកទឹកចិត្តមានប្រសិទ្ធភាពតម្លៃ និងស្របតាមគោលដៅគោលនយោបាយជាយុទ្ធសាស្ត្រ។
- ធ្វើមជ្ឈការអំណាចសម្រេចចិត្តលើការផ្ដល់ការអនុគ្រោះពន្ធ ក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបន្ទាប់មករដ្ឋបាលពន្ធដារត្រូវយកទៅអនុវត្ត និងពិនិត្យតាមដាន។

**កម្ពុជាត្រូវដោះស្រាយបន្ទុកអនុលោមភាពពន្ធ ភាពមិនប្រាកដប្រជា និងចំណុចខ្សោយរបស់សវនកម្ម។** អត្ថបទផ្ដោតពិសេសនេះ រំលេចឡើងនូវទិដ្ឋភាពផ្សេងៗនៃបន្ទុកអនុលោមភាពពន្ធ ដែលអាចបង្កវិការភាពក្នុងការប្រកួតប្រជែង រារាំងការចុះបញ្ជីអាជីវកម្មក្នុងប្រព័ន្ធផ្លូវការ និងធ្វើឱ្យក្រុមហ៊ុនវិនិយោគបាក់ទឹកចិត្ត។ ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានចេញនីតិវិធីប្រតិបត្តិការស្តង់ដា (SOP) ស្តីពីសវនកម្ម ដែលរួមមានគោលការណ៍ណែនាំសិទ្ធិ និងការទទួលខុសត្រូវរបស់សវនករ និងអ្នកជាប់ពន្ធក្នុងអំឡុងពេលដំណើរការសវនកម្ម។ នីតិវិធីប្រតិបត្តិការស្តង់ដាកំណត់ថាអ្នកជាប់ពន្ធ ក្នុងលក្ខខណ្ឌធម្មតា ត្រូវទទួលការធ្វើសវនកម្មតែម្តងគត់ក្នុងរយៈពេលបីឆ្នាំ។ អគ្គនាយកដ្ឋានពន្ធដារក៏បានអនុវត្តសេវាកម្មពន្ធតាមរយៈថ្នាលអេឡិចត្រូនិកដែរ ដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធបំពេញកាតព្វកិច្ចរបស់ខ្លួនដោយមិនចាំបាច់ជួបផ្ទាល់ជាមួយមន្ត្រីពន្ធដារ ហើយការបង់ពន្ធឥឡូវនេះក៏អាចធ្វើបានតាមរយៈប្រព័ន្ធធនាគារផងដែរ។ ជំហានសំខាន់ៗខាងលើអាចបំពេញបន្ថែមដោយរួមបញ្ចូលចំណុចខាងក្រោម រួមមាន៖

- ក្នុងរយៈពេលមធ្យម គួរចែងឱ្យបានច្បាស់ជាងមុនអំពីសិទ្ធិ និងការការពារអ្នកជាប់ពន្ធ នៅក្នុងច្បាប់ស្តីពីសារពើពន្ធ រួមទាំងចែងឱ្យបានជាក់លាក់អំពីកិច្ចការពារក្នុងពេលធ្វើសវនកម្ម ការវាយតម្លៃ និងដំណើរការដោះស្រាយវិវាទ ដើម្បីកាត់បន្ថយភាពមិនប្រាកដប្រជាផ្នែកច្បាប់។ កំណត់ពេលវេលាច្បាស់លាស់សម្រាប់ដោះស្រាយវិវាទ និងធានាថា គណៈកម្មការដោះស្រាយវិវាទពន្ធដារ មានឯករាជ្យភាពពីរដ្ឋបាលពន្ធដារ ដើម្បីផ្ដល់ការសម្រេចចិត្តប្រកបដោយត្រឹមត្រូវយុត្តិធម៌ និងមិនលម្អៀង។ ឧត្តមានុវត្តន៍ប្រព័ន្ធពន្ធអន្តរជាតិរួមបញ្ចូលនូវពេលវេលាច្បាស់លាស់សម្រាប់ដោះស្រាយវិវាទ (ឧទាហរណ៍ រយៈពេល ៣០ ទៅ ៦០ ថ្ងៃ) និងធានាឯករាជ្យភាពសម្រាប់អង្គភាពដោះស្រាយវិវាទ។ នៅចក្រភពអង់គ្លេស សហរដ្ឋអាមេរិក និងបណ្ដាប្រទេសសមាជិកអង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ផ្សេងទៀត ជាធម្មតា គេមានអង្គភាពអធិការកិច្ចពន្ធដារឯករាជ្យ (independent tax ombudsmen) ឬតុលាការ សម្រាប់ដោះស្រាយវិវាទពន្ធដារ។
- បង្កើតកម្មវិធីធានាគុណភាពសវនកម្មផ្លូវការ ដើម្បីពិនិត្យឡើងវិញ និងតាមដានសវនកម្មជាប្រចាំ និងវាយតម្លៃឥទ្ធិពលនៃការធ្វើសវនកម្មក្នុងការចាត់ការជាមួយទង្វើមិនអនុលោមតាមច្បាប់ពន្ធ។
- ប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ (Key Performance Indicators) ដើម្បីតាមដានលទ្ធផលនៃការដោះស្រាយវិវាទលើបញ្ហាជាក់លាក់សំខាន់ៗជាប្រចាំ។
- វិនិយោគលើការធ្វើឌីជីថលនៃប្រព័ន្ធគ្រប់គ្រងសវនកម្ម និងវិវាទ ដើម្បីកាត់បន្ថយពេលវេលាចំណាយលើការរុញឯកសារទៅមុខទៅក្រោយ កម្រិតចំណាយមិនចាំបាច់ និងបង្កើនតម្លាភាព និងភាពទស្សន៍ទាយបានសម្រាប់អ្នកបង់ពន្ធ ហើយទន្ទឹមគ្នានោះ មានយន្តការតាមដានពិនិត្យពីលើឱ្យបានស្វាហាប់ជាប្រចាំ។
- ជំរុញលើកទឹកចិត្តចុះបញ្ជីអាជីវកម្មក្នុងប្រព័ន្ធផ្លូវការបន្តិចម្ដងៗ តាមរយៈការធ្វើឱ្យរដ្ឋបាលមានភាពសាមញ្ញនៅតាមកម្រិតដំបូងដែលមានបន្ទុកពន្ធស្រាល (ឧទាហរណ៍ ពន្ធរបបម៉ៅការផ្អែកលើចំណូលសម្រាប់អាជីវកម្មខ្នាតតូច និងខ្នាតមីក្រូ) និងបង្កើនការផ្សព្វផ្សាយទៅដល់ក្រុមហ៊ុនក្រៅប្រព័ន្ធ។
- ធ្វើការស្ទង់មតិអំពីថ្លៃចំណាយលើអនុលោមភាពពន្ធ ដើម្បីវាស់វែង និងតាមដានជាប្រព័ន្ធ អំពីបន្ទុករដ្ឋបាលនៅតាមវិស័យ និងតាមទំហំក្រុមហ៊ុន ដោយប្រើប្រាស់លទ្ធផលសម្រាប់ដឹកនាំដំណើរការកែលម្អឱ្យសាមញ្ញបន្ថែមទៀត និងសម្រាប់ប្រមូលមតិយោបល់អំពីបទពិសោធន៍សវនកម្ម និងភាពវិជ្ជាជីវៈរបស់មន្ត្រីពន្ធដារ ហើយប្រើលទ្ធផលទាំងនោះធ្វើជាមូលដ្ឋានសម្រាប់ធ្វើការបណ្តុះបណ្តាល និងគ្រប់គ្រងការបំពេញកិច្ចពន្ធដារ។
- ធ្វើការវិភាគវិនិច្ឆ័យរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារ ដើម្បីគូសវាសផែនទីដំណើរការទូទាត់សងអាករលើតម្លៃបន្ថែម ពីដើមដល់ចប់ រកមើលកំណត់ឧបសគ្គផ្នែកប្រតិបត្តិការ និងបញ្ជាក់ពីតួនាទីនិងការទទួលខុសត្រូវឱ្យបានច្បាស់។ ផ្អែកលើលទ្ធផលដែលរកឃើញ សូមកំណត់គោលដៅទូទាត់សងឱ្យបានច្បាស់ កែលម្អការចែករំលែកទិន្នន័យ និងដាក់ឱ្យប្រើនូវប្រព័ន្ធឌីជីថលមួយ សម្រាប់តាមដានស្ថានភាពចុងក្រោយនៃការទូទាត់សងអាករលើតម្លៃបន្ថែម។

កម្ពុជាចាំបាច់ត្រូវធ្វើទំនើបកម្មប្រព័ន្ធពន្ធអាករពិសេសរបស់ខ្លួន ដើម្បីពង្រឹងការប្រមូលចំណូល និងលើកកម្ពស់សុខភាពឱ្យកាន់តែប្រសើរឡើង។ វិធានការដែលត្រូវអនុវត្តរួមមាន៖

**រូប S.18 ៖ គំនូសតាងអំពីចំណូលបានមកពីអាករលើបារី *២០១៧-២០២៨***




*ប្រភព៖ ការប៉ាន់ប្រមាណដោយបុគ្គលិកធនាគារពិភពលោក។*

*សម្គាល់៖ អាករក្នុងមួយកញ្ចប់តំណាងឱ្យជាមធ្យមទម្ងន់ក្នុងមួយកញ្ចប់។*

ការកើនឡើងខ្ពស់ក្នុងរយៈពេលពីរឆ្នាំដំបូងមានគោលបំណងពន្លឿនការបំពេញគម្លាតធំនៃការយកពន្ធអាករលើការជក់បារីរវាងប្រទេសកម្ពុជា និងប្រទេសប្រហាក់ប្រហែលគ្នា រួចហើយមកអាករនេះនឹងកើនឡើងកម្រិតមធ្យមថែមទៀតនៅក្នុងឆ្នាំបន្តបន្ទាប់ទៀត។ នៅក្នុងគំនូសតាង A ពន្ធជាក់លាក់ចំនួន ៥០០រៀលក្នុងមួយកញ្ចប់ក្នុងមួយឆ្នាំត្រូវបានបញ្ចូលទៅក្នុងពន្ធតាមតម្លៃ ដែលមានស្រាប់ក្នុងរយៈពេល ២ ឆ្នាំដំបូង និង ៣00 រៀលក្នុងមួយកញ្ចប់ក្នុងមួយឆ្នាំសម្រាប់រយៈពេល ៣ ឆ្នាំបន្ទាប់ សរុបពន្ធជាក់លាក់ ចំនួន ១ ៩០០ រៀលក្នុងមួយកញ្ចប់នៅឆ្នាំទី ៥ ។ នៅក្នុង គំនូសតាង B ពន្ធជាក់លាក់ ចំនួន ៨00 រៀលក្នុងឆ្នាំ ត្រូវបានបន្ថែមទៅលើពន្ធតាមតម្លៃដែលមានស្រាប់ ក្នុងឆ្នាំទី១; ៧០០រៀលក្នុងមួយកញ្ចប់នៅឆ្នាំទី២; និង ៦០០ រៀល; ៥០០ រៀល និង ៣៥០ រៀល ក្នុងមួយឆ្នាំ ក្នុងឆ្នាំបន្តបន្ទាប់ទៀត។

**រូប S.19 ៖ ផលចំណេញសម្រាប់ចំណូលសុទ្ធពីកំណែទម្រង់អាករលើថ្នាំជក់**




*ប្រភព៖ ការប៉ាន់ប្រមាណរបស់អ្នកនិពន្ធ* ដោយប្រើកម្រិតប្រែប្រួលថ្លៃ ៩៥ភាគរយ។

*សម្គាល់៖ ផលប៉ះពាល់សុទ្ធនៅក្នុងនេះគឺការប្រែប្រួលក្នុងការចំណាយលើថ្នាំជក់* + ចំណាយលើពេទ្យ + ចំនួនឆ្នាំនៃជីវិតធ្វើការដែលបានខាតបង់។ តម្រូវការថ្នាំជក់នឹងប្រែប្រួលអាស្រ័យលើការឡើងចុះថ្លៃរបស់វា។ ការឡើងចុះថ្លៃថ្នាំជក់ជាមធ្យមនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានពីកម្រិត -0,៣៨ ទៅ -0,៤២ (ការលោតឡើងមធ្យម)។ ការឡើងចុះថ្លៃខ្លាំងមានទៅលើជនក្រីក្រជាងអ្នកមាន។

- ក្នុងរយៈពេលខ្លី៖ កែទម្រង់រចនាសម្ព័ន្ធនៃការយកពន្ធអាករពិសេស ដោយប្តូរទៅប្រព័ន្ធពន្ធអាករពិសេសផ្អែកលើបរិមាណជាក់លាក់ (specific excise tax) ឬជាជម្រើសល្អបន្ទាប់ គឺប្តូរទៅប្រព័ន្ធចម្រុះដែលភាគច្រើនផ្អែកលើសមាសភាគពន្ធជាក់លាក់ ដើម្បីដោះស្រាយចំណុចខ្សោយដែលមាននៅក្នុងរចនាសម្ព័ន្ធពន្ធតាមថ្លៃ (ad valorem) បច្ចុប្បន្ន។
- ធ្វើសនិទានកម្មបញ្ជីមុខទំនិញជាប់អាករពិសេសដោយដកចេញនូវមុខទំនិញណាដែលមិនបង្កើតឱ្យមានកត្តាអវិជ្ជមានខាងក្រៅ (negative externalities) ចំណូល ឬអត្ថប្រយោជន៍ផ្អែកសមធម៌គួរឱ្យកត់សម្គាល់ណាមួយ។
- បង្កើតការបែងចែកប្រភេទផលិតផលឱ្យកាន់តែច្បាស់លាស់ សម្រាប់ការយកពន្ធលើគ្រឿងស្រវឹង ដោយកំណត់អត្រាខ្ពស់ជាងសម្រាប់ផលិតផលដែលមានកម្រិតជាតិអាល់កុលខ្ពស់ ដើម្បីបង្កើនប្រសិទ្ធភាព និងសមធម៌នៃពន្ធលើគ្រឿងស្រវឹង។
- បន្តិចម្តងៗ ប៉ុន្តែប្រកបដោយមហិច្ឆតា បង្កើនអត្រាពន្ធអាករពិសេសលើផលិតផលគ្រឿងស្រវឹង និងថ្នាំជក់ ដោយប្រៀបធៀបអត្រាពន្ធទៅនឹងប្រទេសប្រហាក់ប្រហែលដែលមានចំណូលមធ្យមកម្រិតទាប និងចំណូលមធ្យមកម្រិតខ្ពស់។ គួរតែដាក់ឱ្យមានការកែសម្រួលតាមកាលកំណត់ សម្រាប់អតិផរណា ដើម្បីរក្សាតម្លៃពិតនៃកំណើនពន្ធក្នុងរយៈពេលវែង។ ការធ្វើគំរូបានបង្ហាញថា ការដំឡើងអត្រាពន្ធលើបារី នឹងជួយបង្កើនចំណូលបានដល់ 0,៥ ភាគរយនៃ ផ.ស.ស (រូប S.18) បង្កើតចំណូលវិជ្ជមានសុទ្ធសម្រាប់គ្រួសារ (រូប S.19) កាត់បន្ថយអត្រាប្រេវ៉ាឡង់នៃការជក់បារី និងអាចបញ្ចៀសការស្លាប់បានរហូតដល់ ១២៨ ០០០ នាក់ ក្នុងរយៈពេលប្រាំឆ្នាំ។ នៅក្នុងរយៈពេលខ្លី ការកើនឡើងថ្លៃអាចបណ្តាលការចំណាយលើបារីកើនឡើង ជះផលអវិជ្ជមានលើចំណូលរបស់គ្រួសារក្រីក្រ ប៉ុន្តែការថយចុះនៃការជក់បារី និងនៃការចំណាយលើការព្យាបាល ព្រមទាំងការប្រែប្រួលនៃចំនួនឆ្នាំប្រកបការងារបាន ធ្វើឱ្យចំណូលកើនជាវិជ្ជមានសម្រាប់គ្រប់ក្រុមចំណូលទាំងអស់ ក្នុងរយៈពេលមធ្យម និងរយៈពេលវែង។

# ឧបសម្ព័ន្ធ៖ កម្ពុជា - សូចនាករសំខាន់ៗ

**កម្ពុជា**

| សូចនាករសំខាន់ៗ* | Avg. '10-19 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 E |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ប្រាក់ចំណូល និងកំណើនសេដ្ឋកិច្ច** | | | | | | | | | | | | | | | | |
| កំណើនផ.ស.ស(ប្រចាំឆ្នាំ %) | 7.6 | 5.1 | 7.3 | 7.7 | 7.9 | 8.0 | 7.2 | 7.9 | 8.1 | 8.8 | 7.9 | -3.6 | 3.1 | 5.1 | 5.0 | 6.0 |
| កំណើនផ.ស.ស សម្រាប់មនុស្សម្នាក់(ប្រចាំឆ្នាំ %, ពិត) | 6.1 | 3.5 | 5.7 | 6.0 | 6.3 | 6.4 | 5.7 | 6.3 | 6.6 | 7.4 | 6.6 | -5.0 | 1.6 | 3.7 | 3.7 | 4.7 |
| ផ.ស.ស សម្រាប់មនុស្សម្នាក់(US$, នាមករណ៍) | 1,554 | 985 | 1,101 | 1,193 | 1,306 | 1,434 | 1,564 | 1,675 | 1,821 | 2,029 | 2,221 | 2,090 | 2,167 | 2,298 | 2,455 | 2,657 |
| កំណើននៃការប្រើប្រាស់ឯកជន(ប្រចាំឆ្នាំ %) | 6.4 | 9.3 | 10.8 | 6.0 | 6.8 | 5.4 | 5.7 | 4.6 | 6.7 | 5.5 | 3.4 | -1.9 | -2.4 | 5.2 | -0.2 | 2.5 |
| ការវិនិយោគសរុប(% នៃផ.ស.ស នាមករណ៍) | 27.0 | 21.3 | 21.4 | 23.7 | 25.9 | 29.1 | 29.0 | 29.5 | 29.8 | 30.0 | 30.7 | 30.6 | 29.7 | 34.0 | 20.4 | 15.5 |
| ការវិនិយោគសរុប - សាធារណៈ (% នៃផ.ស.ស នាមករណ៍)[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| **ប្រាក់ និងតម្លៃ** | | | | | | | | | | | | | | | | |
| អតិផរណា, តម្លៃអ្នកប្រើប្រាស់(ប្រចាំឆ្នាំ%, EOP or MRV)[1] | 2.9 | 2.9 | 4.6 | 2.3 | 4.5 | 0.9 | 2.8 | 3.8 | 2.2 | 1.6 | 3.1 | 2.9 | 3.8 | 2.9 | 2.7 | 3.0 |
| អតិផរណា, តម្លៃអ្នកប្រើប្រាស់ (ប្រចាំឆ្នាំ%, រយៈពេលជាមធ្យម) | 2.9 | 2.6 | 5.5 | 3.0 | 2.9 | 3.9 | 1.2 | 3.0 | 2.9 | 2.5 | 1.9 | 2.9 | 2.8 | 5.5 | 2.1 | 2.2 |
| ប្រាក់មូលដ្ឋាន(% នៃផ.ស.ស) | 54.0 | 33.9 | 31.3 | 39.5 | 43.3 | 51.1 | 54.1 | 59.7 | 66.6 | 74.7 | 85.9 | 106.5 | 95.8 | 66.2 | 63.0 | 68.1 |
| ឥណទានក្នុងស្រុកដល់វិស័យឯកជន(% នៃផ.ស.ស.)[2] | 66.6 | 22.4 | 22.6 | 30.5 | 40.0 | 47.5 | 55.5 | 61.6 | 65.5 | 73.8 | 84.3 | 103.7 | 121.8 | 132.8 | 130.1 | 129.8 |
| អត្រាប្តូរប្រាក់នាមករណ៍ (រូបិយប័ណ្ណក្នុងស្រុកក្នុងមួយដុល្លារ) | 4,043 | 4,044 | 4,016 | 4,033 | 4,027 | 4,030 | 4,025 | 4,058 | 4,062 | 4,067 | 4,070 | 4,077 | 4,100 | 4,150 | 4,110 | 4,067 |
| សន្ទស្សន៍អត្រាប្តូរប្រាក់ពិត (2015=100) | 97.7 | 91.8 | 91.1 | 90.7 | 91.7 | 93.1 | 100.0 | 105.2 | 103.1 | 105.4 | 105.1 | 98.5 | 100.4 | 93.9 | 79.2 | 85.3 |
| **សារពើពន្ធ** | | | | | | | | | | | | | | | | |
| ចំណូល(% នៃផ.ស.ស) | 15.6 | 14.4 | 14.1 | 13.9 | 14.2 | 15.2 | 14.7 | 15.7 | 16.5 | 17.7 | 20.0 | 17.9 | 16.2 | 17.2 | 16.5 | 15.2 |
| ការចំណាយ (% នៃផ.ស.ស) | 17.0 | 17.1 | 18.0 | 17.1 | 16.7 | 16.6 | 15.1 | 15.9 | 17.1 | 17.4 | 18.8 | 21.3 | 21.3 | 20.4 | 21.8 | 18.2 |
| ការទូទាត់ការប្រាក់(% នៃផ.ស.ស) | 0.3 | 0.2 | 0.2 | 0.4 | 0.6 | 0.5 | 0.2 | 0.3 | 0.3 | 0.3 | 0.3 | 0.3 | 0.3 | 0.3 | 0.3 | 0.4 |
| ការចំណាយមិនមែនការប្រាក់ (% នៃផ.ស.ស) | 16.6 | 16.9 | 17.7 | 16.7 | 16.1 | 16.1 | 14.8 | 15.6 | 16.8 | 17.1 | 18.5 | 20.9 | 20.9 | 20.1 | 21.5 | 17.8 |
| សមតុល្យសារពើពន្ធសរុប(% នៃផ.ស.ស) | -1.3 | -2.7 | -3.9 | -3.2 | -2.5 | -1.3 | -0.3 | -0.2 | -0.6 | 0.3 | 1.1 | -3.4 | -5.1 | -3.2 | -5.3 | -3.0 |
| សមតុល្យសារពើពន្ធបឋម(% នៃផ.ស.ស) | -1.0 | -2.5 | -3.7 | -2.8 | -2.1 | -1.0 | -0.2 | 0.0 | -0.4 | 0.5 | 1.3 | -3.2 | -4.9 | -3.0 | -5.0 | -2.6 |
| បំណុលរដ្ឋាភិបាលទូទៅ(%នៃផ.ស.ស) | 23.1 | 23.4 | 23.8 | 24.9 | 24.4 | 24.2 | 23.3 | 22.0 | 22.9 | 21.3 | 20.8 | 25.2 | 25.6 | 24.9 | 26.5 | 25.9 |
| បំណុលសាធារណៈខាងក្រៅ(%នៃផ.ស.ស)[2] | 23.1 | 23.4 | 23.8 | 24.9 | 24.4 | 24.2 | 23.3 | 22.0 | 22.9 | 21.3 | 20.8 | 25.2 | 25.6 | 24.8 | 26.3 | 25.6 |
| **គណនីខាងក្រៅ** | | | | | | | | | | | | | | | | |
| កំណើនការនាំចេញ, G&S (US$ នាមករណ៍, ប្រចាំឆ្នាំ %) | 12.4 | 22.9 | 11.4 | 16.0 | 16.8 | 10.3 | 7.5 | 9.0 | 9.4 | 12.3 | 8.5 | 2.1 | 11.2 | 31.9 | 16.6 | 11.6 |
| កំណើននៃការនាំចូល, G&S (US$ នាមករណ៍, ប្រចាំឆ្នាំ %) | 12.2 | 19.1 | 11.4 | 14.2 | 16.9 | 8.8 | 7.6 | 9.0 | 7.8 | 9.3 | 17.4 | 9.7 | 47.8 | 37.2 | -19.8 | 6.3 |
| ការនាំចេញទំនិញ (% នៃ ផ.ស.ស) | 33.5 | 31.1 | 31.1 | 32.8 | 34.8 | 34.6 | 33.9 | 34.3 | 34.1 | 34.1 | 33.9 | 38.5 | 46.0 | 52.7 | 54.7 | 56.1 |
| ការនាំចូលទំនិញ (% នៃ ផ.ស.ស) | 42.1 | 41.1 | 40.4 | 42.3 | 44.9 | 43.7 | 42.8 | 42.9 | 42.0 | 40.9 | 40.3 | 48.9 | 67.7 | 68.6 | 54.8 | 57.5 |

# ឧបសម្ព័ន្ធ (គ)

## កម្ពុជា

| សូចនាករសំខាន់ៗ* | Avg. '10-19 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 E |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សេវាកម្ម,សុទ្ធ(% នៃផ.ស.ស) | 5.1 | 5.5 | 5.0 | 5.7 | 6.1 | 5.8 | 5.6 | 5.3 | 5.3 | 5.5 | 1.3 | 1.0 | -8.0 | -24.5 | -9.0 | -4.2 |
| សមតុល្យគណនីចរន្ត(បច្ចុប្បន្នគិតជាលានដុល្លារ US$) | -1602.1 | -1165.3 | -1309.3 | -1390.7 | -1489.3 | -1899.7 | -1680.6 | -1756.5 | -1634.4 | -1540.5 | -2155.0 | -1938.3 | -10711.1 | -7437.5 | 561.4 | -515.3 |
| សមតុល្យគណនីចរន្ត(%នៃផ.ស.ស) | -7.0 | -8.2 | -8.1 | -7.8 | -7.5 | -8.6 | -6.9 | -6.6 | -5.6 | -4.7 | -5.9 | -5.5 | -29.1 | -18.8 | 1.3 | -1.1 |
| ការវិនិយោគផ្ទាល់ពីបរទេស, លំហូរចូលសុទ្ធ (%នៃផ.ស.ស) | 9.3 | 9.6 | 9.4 | 11.0 | 10.1 | 8.0 | 7.1 | 9.0 | 9.1 | 9.4 | 9.7 | 10.0 | 9.2 | 8.7 | 8.5 | 8.7 |
| បំណុលពហុភាគី (%នៃបំណុលខាងក្រៅសរុប)[2] | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| **ប្រជាជន ការងារ និងភាពក្រីក្រ** | | | | | | | | | | | | | | | | |
| ចំនួនប្រជាជន, សរុប (គិតជាលាន) | 15.3 | 14.5 | 14.7 | 14.9 | 15.2 | 15.4 | 15.6 | 15.9 | 16.1 | 16.3 | 16.5 | 16.7 | 17.0 | 17.2 | 17.4 | 17.6 |
| កំណើនប្រជាជន (ប្រចាំឆ្នាំ %) | 1.4 | 1.6 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.5 | 1.4 | 1.3 | 1.3 | 1.5 | 1.5 | 1.3 | 1.3 | 1.2 |
| អត្រាគ្មានការងារធ្វើ[2] | 0.4 | 0.8 | 0.6 | 0.5 | 0.4 | 0.7 | 0.4 | 0.7 | 0.1 | 0.1 | 0.1 | 0.2 | 0.4 | 0.2 | 0.2 | .. |
| វិសមភាព - មេគុណជីនី2 (Gini) | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. | .. |
| អាយុកាល[2] | 69.6 | 67.7 | 68.4 | 68.9 | 69.3 | 69.7 | 69.9 | 70.2 | 70.5 | 70.6 | 70.7 | 70.4 | 69.6 | 69.9 | .. | .. |
| **ផ្សេងៗ** | | | | | | | | | | | | | | | | |
| ផ.ស.ស (LCU បច្ចុប្បន្ន, គិតជាលាន) | 97,180,276 | 57,788,147 | 65,068,396 | 71,894,423 | 79,768,285 | 88,992,411 | 98,334,482 | 107,784,906 | 118,907,473 | 134,279,541 | 148,984,697 | 142,502,829 | 150,792,683 | 164,059,089 | 175,822,580 | 190,629,514 |
| ផ.ស.ស (បច្ចុប្បន្ន US$, គិតជាលាន) | 24,010 | 14,290 | 16,202 | 17,827 | 19,808 | 22,082 | 24,431 | 26,561 | 29,273 | 33,017 | 36,606 | 34,949 | 36,779 | 39,532 | 42,779 | 46,872 |
| ផ.ស.សក្នុងមនុស្សម្នាក់ LCU (ពិត) | 6,140,283 | 4,561,703 | 4,820,349 | 5,111,863 | 5,431,708 | 5,779,940 | 6,106,676 | 6,494,022 | 6,922,106 | 7,436,541 | 7,926,068 | 7,532,643 | 7,651,555 | 7,935,721 | 8,226,266 | 8,614,880 |
| ចំណាត់ថ្នាក់សន្ទស្សន៍អភិវឌ្ឍន៍មនុស្ស[3] | 150.0 | 149 | 150 | 150 | 151 | 151 | 150 | 150 | 149 | 150 | 150 | 149 | 147 | 148 | .. | .. |
| CPIA (ការវាយតម្លៃសរុប)[2] | 3.4 | 3.4 | 3.4 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | 3.6 | 3.6 | .. |
| ការគ្រប់គ្រងសេដ្ឋកិច្ច[2] | 4.0 | 4.0 | 3.8 | 3.8 | 3.8 | 3.8 | 4.0 | 4.0 | 4.0 | 4.2 | 4.2 | 4.2 | 4.2 | 4.2 | 4.2 | .. |
| គោលនយោបាយរចនាសម្ព័ន្ធ[2] | 3.5 | 3.3 | 3.5 | 3.7 | 3.7 | 3.7 | 3.5 | 3.5 | 3.3 | 3.3 | 3.3 | 3.3 | 3.5 | 3.5 | 3.5 | .. |
| គោលនយោបាយសម្រាប់បរិយាបន្នសង្គម និងសមធម៌[2] | 3.4 | 3.4 | 3.5 | 3.5 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.4 | 3.5 | 3.5 | 3.6 | 3.8 | 3.8 | .. |
| ការគ្រប់គ្រងវិស័យសាធារណៈ និងស្ថាប័ន[2] | 2.7 | 2.7 | 2.8 | 2.8 | 2.8 | 2.8 | 2.7 | 2.7 | 2.7 | 2.6 | 2.6 | 2.7 | 2.8 | 2.8 | 2.8 | .. |

*ចំណាំ៖* “..” បង្ហាញថាមិនមានទេ។ E = ការប៉ាន់ស្មាន, F = ការព្យាករណ៍។ ទិន្នន័យពី MFMOD លើកលែងតែមានការកត់សម្គាល់ផ្សេង។

1/ មូលដ្ឋានទិន្នន័យវិភាគ Haver; MRV = តម្លៃចុងក្រោយបំផុត។

2/ មូលទិន្នន័យសូចនាករអភិវឌ្ឍន៍ពិភពលោក WDI និងការប៉ាន់ប្រមាណដោយបុគ្គលិកធនាគារពិភពលោក។

3/ ចំណាត់ថ្នាក់ HDI ក្នុងឆ្នាំ២០០១ គឺទាក់ទងទៅនឹង១៧៥ប្រទេស ហើយនៅក្នុងឆ្នាំ២០១០ ទាក់ទងទៅនឹង១៦៩ប្រទេស ។ ការកែលម្អវិធីសាស្ត្រក្នុងការគណនា HDI បានធ្វើឱ្យមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៅក្នុងចំណាត់ថ្នាក់របស់ប្រទេសទាំងនេះ។

*ប្រភព៖ មូលទិន្នន័យ* MFMOD, មូលទិន្នន័យ WDI របស់ធនាគារពិភពលោក និង មូលទិន្នន័យវិភាគ Haver, IMF។

# គន្ថនិទ្ទេស

**Andersen Global.** 2024. "New Tax Audit SOPs in Cambodia: What Businesses Need to Know."

**Angkor Enterprise.** 2025. "Monthly Revenue from Angkor Entrance Fees 2024." Angkor Enterprise, Phnom Penh. https://www.angkorenterprise.gov.kh/.

**"Global Monthly."** 2025. Development Economics, Prospects Group. World Bank, April 2025. https://thedocs.worldbank.org/en/doc/de57f32fdf177170d1fe413327b553dd-0050012025/related/Global-Monthly-April-2025.pdf.

**IHME (Institute for Health Metrics and Evaluation).** 2019. "Global Burden of Disease Study 2019." https://ghdx.healthdata.org/gbd-2019.

**IMF (International Monetary Fund).** 2018. "Cambodia Technical Assistance Report-Tax Administration Modernization Priorities 2019-23." https://www.elibrary.imf.org/view/journals/002/2018/305/article-A001-en.xml.

**International Monetary Fund.** 2025a. "A Critical Juncture Amid Policy Shifts." *World Economic Outlook*. https://www.imf.org/en/Publications/WEO/Issues/2025/04/22/world-economic-outlook-april-2025.

———**.** 2025b. "Cambodia: 2024 Article IV Consultation." Press Release and Staff Report. International Monetary Fund, Washington, DC. https://www.imf.org/en/Publications/CR/Issues/2025/01/27/Cambodia-2024-Article-IV-Consultation-Press-Release-Staff-Report-and-Statement-by-the-561261.

**Karamba, R.** Wendy, Michal Myck, Kajetan Wladyslaw Trzcinski, and Kimsun Tong. 2023. "Fiscal Policy Effects on Poverty and Inequality in Cambodia." Policy Research Working Paper Series 10570. Washington, DC: World Bank Group.

Ministry of Agriculture, Forestry and Fisheries. 2025. "Annual report for 2024 and target for 2025." Ministry of Agriculture, Forestry and Fisheries, Phnom Penh.

**Ministry of Economy and Finance.** 2025a. *Public Debt Statistical Bulletin*, Volume 25, 2025. Ministry of Economy and Finance, Phnom Penh. https://gdicdm.mef.gov.kh/en/2025/03/10/11295.html.

———**.** 2025b. Government Finance Statistics (GFS) and Tableau des Opérations Financières de l'Etat (TOFE). Ministry of Economy and Finance, Phnom Penh. https://mef.gov.kh/documents-category/publication/tofe/.

**Ministry of Planning.** 2014. Cambodia Socio-Economic Survey (CSES) 2014. National Institute of Statistics, Ministry of Planning, Phnom Penh. https://nis.gov.kh/index.php/km/.

———**.** 2019. Cambodia Socio-Economic Survey 2019. National Institute of Statistics, Ministry of Planning, Phnom Penh. https://nis.gov.kh/index.php/km/.

———. 2019/20. Cambodia Socio-Economic Survey Reports. 2019/20. https://nis.gov.kh/index.php/km/.

———**.** 2021. Cambodia Socio-Economic Survey 2021. National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2023. Cambodia Socio-Economic Survey 2023. National Institute of Statistics, Ministry of Planning, Phnom Penh.

———. 2025. Monthly Consumer Price Index 2024. Ministry of Planning, Phnom Penh.

Ministry of Tourism. 2024. "Cambodia Tourism Statistics Report, 2024." Ministry of Tourism, Phnom Penh.

———**.** 2025. "Monthly Cambodia Tourism Statistics Report," February 2025. Ministry of Tourism, Phnom Penh.

National Bank of Cambodia. 2025a. Monetary and Financial Statistics Data 2025. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/english/economic_research/monetary_and_financial_statistics_data.php.

———. 2025b. "Annual Report, 2024." National Bank of Cambodia, Phnom Penh. https://nbc.gov.kh/download_files/publication/annual_rep_kh/Annual_Report_2024_KHM.pdf.

———. 2025c. Cambodia Balance of Payments Fourth Quarter 2024. National Bank of Cambodia, Phnom Penh. https://www.nbc.gov.kh/economic_research/balance_of_payment_data.php.

**Royal Government of Cambodia.** 2025. The 2025 Annual Budget Law. Royal Government of Cambodia, Phnom Penh. https://mef.gov.kh/documents-category/law-and-regulation/.

**United States Federal Reserve.** 2024. "Federal Reserve issues FOMC statement," Press Release, November 7, Washington, DC. https://www.federalreserve.gov/newsevents/pressreleases/monetary20241107a.htm.

———. 2025. "Federal Reserve issues FOMC statement," Press Release, March 19, Washington, DC. https://www.federalreserve.gov/newsevents/pressreleases/monetary20250319a.htm.

**World Bank.** 2022. Cambodia Excise Tax Assessment: technical assistance report (unpublished)

———. 2023. "Cambodia Public Finance Review – From Spending More to Spending Better." World Bank, Washington, DC.

———. 2024a. *Business Ready 2024*. Washington, DC: World Bank. doi:10.1596/978-1-4648-2021-2. License: Creative Commons Attribution CC BY 3.0 IGO. https://openknowledge.worldbank.org/server/api/core/bitstreams/131b6383-30a1-44b3-8e66-f425d715503d/content.

———. 2024b. "Cambodia Economic Update December 2024." World Bank, Washington, DC.

———. 2024c. World Bank Enterprise Surveys: The Informal Sector Enterprise Surveys in Cities in Cambodia. World Bank, Washington, DC.

———. 2025a. *Global Economic Prospects, January 2025*. Washington, DC: World Bank. https://www.worldbank.org/en/publication/global-economic-prospects.

———. 2025b. *World Bank East Asia and Pacific Economic Update April 2025 – A Longer View*. Washington, DC: World Bank. https://www.worldbank.org/en/publication/east-asia-and-pacific-economic-update.

———. 2025c. *Commodity Markets Outlook*. Washington, DC: World Bank, April 25. https://www.worldbank.org/en/research/commodity-markets.

THE WORLD BANK
IBRD • IDA | WORLD BANK GROUP
East Asia & Pacific